សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការកំណត់បទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ស៊ឹង រីសា**

**ស៊ើ សុនិតា**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ដោយមាននាងខ្ញុំឈ្មោះ **ស៊ីង រីសា** និង **សឿ សុនិតា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា ២០១៨-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅ ចំពោះ៖

| | |
|---|---|
| លោកឪពុក **ស៊ីង សារិទ្ធ** | លោកឪពុក **សឿ ដារ៉ា** |
| អ្នកម្តាយ **យ៉ា នាង** | អ្នកម្តាយ **លឹម សុខលាភ** |

ដែលបានផ្តល់កំណើត និងខិតខំចិញ្ចឹមបីបាច់ថែរក្សារូបនាងខ្ញុំតាំងពីតូចរហូតដល់ធំដោយក្តីមេត្តាករុណា។ លោកអ្នកមានគុណទាំងពីរមិនដែលត្អូញត្អែរថាលំបាក ឬនឿយហត់ម្តងណាឡើយឱ្យតែគ្រួសារមានសុភមង្គលមានក្តីសុខ ទោះបីជាហត់នឿយយ៉ាងណាក៏លោកឪពុក និងអ្នកម្តាយតែងតែនៅជាមួយកូនផ្តល់ភាពកក់ក្តៅដល់កូននឹងគាំទ្រលើរូបកូនជានិច្ច។ នាងខ្ញុំបានមកដល់ចំណុចនេះ គឺលោកអ្នកមានគុណរួមចំណែកយ៉ាងធំក្នុងការខិតខំជម្រុញលើកទឹកចិត្ត និងឧបត្ថម្ភលើការចំណាយសព្វគ្រប់បែបយ៉ាងមិនថាជាសម្ភារៈសិក្សាការរៀនសូត្រ និងរបស់របរដែលជាតម្រូវការជាច្រើនទៀតតាំងពីថ្នាក់មតេយ្យ រហូតដល់ថ្នាក់បរិញ្ញាបត្រនេះអ្វីគ្រប់យ៉ាងដែរ។ អ្នកមានគុណទាំងពីរបានលះបង់នេះមិនអាចយករបស់អ្វីមកកាត់ថ្លៃប្រៀបផ្ទឹមនូវគុណបំណាច់ដ៏ថ្លៃថ្លានេះបានឡើយ។ ខ្ញុំគ្មានអ្វីតបស្នងលោកឪពុកអ្នកម្តាយឡើយ ក្រៅពីបំពេញកាតព្វកិច្ចជាកូនល្អសម្រាប់លោកអ្នកទាំងពីរអភិវឌ្ឍន៍ខ្លួនជាពលរដ្ឋល្អ និងប្រើប្រាស់សមត្ថភាពដែលនាងខ្ញុំមានទៅបម្រើជាផលប្រយោជន៍សង្គមជាតិនៅថ្ងៃអនាគត។

នាងខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពង់ និងជ្រាលជ្រៅជូនទៅដល់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន** ដែលបានលះបង់ដើម្បីរំដោះជាតិមាតុភូមិពីសង្គ្រាម បង្រួមជាតិតែមួយ និងអភិវឌ្ឍន៍ប្រទេសបានរីកចំរើនគ្រប់វិស័យរហូតដល់សព្វថ្ងៃនេះ។ ជាពិសេស នាងខ្ញុំក៏ទទួលបានឱកាសអាហារូបករណ៍របស់សម្តេចទាំងពីរតាមរយៈ **ឯកឧត្តម ហ៊ុន ម៉ាណែត**។ អាហារូបករណ៍របស់សម្តេចទាំងពីរបានជួយបន្ធូរបន្ទុកគ្រួសារនាងខ្ញុំបានច្រើន មិនតែប៉ុណ្ណោះជាមួយគ្នានេះដែរនាងខ្ញុំក៏បានចូលរួមក្នុងការងារស្ម័គ្រចិត្តមួយចំនួន តាមរយៈសមាគមន៍របស់និស្សិតអាហារូបករណ៍(**អ.ម.ត.**) ដែលជាការបង្រៀនខ្ញុំឱ្យស្គាល់ពីការធ្វើការងារជាក្រុមផងដែរ។

នាងខ្ញុំសូមថ្លែងអំណរគុណទៅដល់មូលនិធិហាប់ស្វែល (Harpswell Foundation) និងថ្នាក់ដឹកនាំទាំងអស់ដែលបានផ្តល់ជាអាហារូបករណ៍ជាកន្លែងស្នាក់នៅ អាហារហូបចុក ជាទីកន្លែងដែលបានផ្តល់នូវការអប់រំមួយដែលល្អដល់នាងខ្ញុំអស់រយៈពេល ៤ឆ្នាំ ជាមួយនឹងអាហារូបករណ៍សិក្សាថ្នាក់ឧត្តមសិក្សានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកនីតិសាស្ត្រ។

RWI ដែលបានផ្តល់ជាជំនួយអាហារូបករណ៍សម្រាប់នាងខ្ញុំរយៈពេល ៣ឆ្នាំ ផ្នែកនីតិសាស្ត្រ ជាភាសាអង់គ្លេសនៅ English Languages Based Bachelor Law Program (ELBBL) ព្រមទាំងអរគុណទៅដល់ Empowerment KPMG Scholarship ដែលបានផ្តល់អាហារូបករណ៍ក៏ដូចជាទឹកប្រាក់ឧបត្ថម្ភមួយចំនួនដល់នាងខ្ញុំសម្រាប់ចំណាយលើការទិញសម្ភារៈសិក្សាពេញមួយឆ្នាំ។

ចំពោះ **ឯកឧត្តម លុយ ចណ្ណា សាកវិទ្យាធិការ និងលោក លោកស្រី សាកវិទ្យាធិការរង ថ្នាក់ដឹកនាំ** ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យនៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់នូវចំណេះដឹង ការអប់រំ និងក្រមសីលធម៌ដល់នាងខ្ញុំក្នុងអំឡុងពេល ០៤ឆ្នាំកន្លងមកនេះ។

ចំពោះលោក **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ទោះបីជាលោកមានការងាររមមាញឹកយ៉ាងណាក្តីក៏លោកខិតខំជួយផ្តល់ជាគំនិតយោបល់ក្នុងការកែសម្រួល និងតម្រង់ទិសបំភ្លឺផ្លូវដល់ក្រុមនាងខ្ញុំកន្លងមករហូតបានដល់សម្រេចចងក្រងចេញជាស្នាដៃមួយនេះឡើង។

ជាចុងក្រោយនាងខ្ញុំសូមលើដៃប្រណម្យបួងសួងជូនដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងបុត្រាបុត្រី និងចៅប្រុសចៅស្រី** សូមបានជួបប្រទះតែពុទ្ធិពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ និង**លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លុយ ចណ្ណា សាកវិទ្យាធិការ និងលោក លោកស្រី សាកវិទ្យាធិការរង ថ្នាក់ដឹកនាំ** ព្រមទាំង លោក លោកស្រី សាស្ត្រាចារ្យនៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ព្រមទាំងសាស្ត្រាចារ្យណែនាំ **លោក ជួន ម៉ុនធី** ឱ្យបានជួបប្រទះសុខសុភមង្គល កម្លាំងខ្លាំងក្លា អាយុយឺនយូរ ប្រាជ្ញាវាងវៃ និងជោគជ័យគ្រប់ភារកិច្ច។

# **អារម្ភកថា**

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅក្នុងឆ្នាំសិក្សា ២០១៨-២០២២ អស់រយៈពេល ៤ឆ្នាំកន្លងមក។ យើងខ្ញុំទាំងពីរនាក់ មានការចាប់អារម្មណ៍ទៅលើមុខវិជ្ជានីតិព្រហ្មទណ្ឌនឹងចង់សិក្សាស្រាវជ្រាវបន្ថែមលើមុខវិជ្ជានេះ ដូច្នេះហើយ ទើប យើងខ្ញុំសម្រេចលើកយកប្រធានបទស្តីពី "**ការកំណត់បទល្មើសព្រហ្មទណ្ឌ**" មកសរសេរជាសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ។

ការសរសេរសារណាបញ្ចប់មួយនេះ យើងខ្ញុំខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការស្រាវជ្រាវរិះរកដកស្រង់ចំណុចសំខាន់ៗចេញពីអត្ថបទច្បាប់ និងឯកសារផ្សេងៗដែលកំពុងតែនៅមានជាធរមាន ព្រមទាំងមានការផ្តល់អនុសាសន៍ពីសំណាក់ **លោកគ្រូ ជួន ម៉ុនធី** ដែលលោកគ្រូបានលះបង់ពេលវេលាដ៏មានតម្លៃរបស់ខ្លួនជួយពន្យល់ ជម្រុញបន្ថែមឱ្យសារណាមួយនេះរឹតតែល្អ។

ទោះបីជាមានការព្យាយាម និងយកចិត្តទុកដាក់យ៉ាងណាក្តីក៏នៅតែមានកំហុសដោយអចេតនាបន្តិចបន្តួច ឬភាពខ្វះចន្លោះនៅផ្នែកណាមួយជាក់ជាមិនខាន។ ហេតុនេះយើងខ្ញុំរីករាយក្នុងការទទួលរាល់គំនិតរិះគន់ទាំងឡាយទុកជាការស្ថាបនានូវការស្រាវជ្រាវមួយនេះឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។ មួយវិញទៀតក៏សុំអភ័យទោសទុកជាមុននូវកំហុសដែលកើតមានឡើងចំពោះផ្នែកបច្ចេកទេស និងខ្លឹមសារមួយចំនួននៃអត្ថបទនេះផង។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថាប្រធានបទមួយនេះនឹងផ្តល់សារៈប្រយោជន៍ ចំពោះនិស្សិតជំនាន់ក្រោយព្រមទាំងអ្នកដែលសិក្សាសូមជូនពរទៅដល់មិត្តអ្នកអាន និងលោក លោកស្រីសាស្ត្រាចារ្យជួបប្រទះតែសេចក្តីសុខសុភមង្គល និងសុខភាពមាំមួន ដើម្បីតម្រង់ផ្លូវលើកស្ទួយនូវការសិក្សាស្វែងយល់ដល់និស្សិតជំនាន់ក្រោយឱ្យទទួលបានពុទ្ធិកាន់តែប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..... ០១

**ជំពូកទី១**

**សញ្ញាណទូទៅ**

**១.១. និយមន័យ** ..... ០៥

**១.២. លក្ខណៈវិនិច្ឆ័យនៃបទល្មើស** ..... ០៥

១.២.១. ចរិតគ្រោះថ្នាក់ដល់សង្គម ..... ០៥

១.២.២. ចរិតកំហុសនៃអំពើ ..... ០៥

១.២.៣. ចរិតផ្ទុយច្បាប់ ..... ០៥

១.២.៤. ចរិតទទួលទោសទណ្ឌ ..... ០៦

**១.៣. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្សេងទៀត** ..... ០៦

១.៣.១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី ..... ០៦

១.៣.២.ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងផ្នែកវិន័យ ..... ០៧

**ជំពូកទី២**

**ចំណាត់ថ្នាក់នៃបទល្មើស**

**២.១. ការបែងចែកបទល្មើសតាមច្បាប់** ..... ០៨

២.២.១. បទលហុ ..... ០៨

២.២.២. បទមជ្ឈិម ..... ០៨

២.២.៣. បទឧក្រិដ្ឋ ..... ០៩

**២.២. ផលប្រយោជន៍នៃការបែងចែក** ..... ០៩

២.២.១. ផលប្រយោជន៍ទាក់ទិននឹងអាជ្ញាយុកាល ..... ១០

២.២.១.១. អាជ្ញាយុកាលនៃបទល្មើស ..... ១០

២.២.១.២. អាជ្ញាយុកាលនៃទោស ..... ១១

២.២.២. ផលប្រយោជន៍នៃការអនុវត្តនីតិវិធី ..... ១១

២.២.៣. ផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ងត្រូវចាត់ថាមានទោស ..... ១២

**២.៣. ការបែងចែកទៅតាមប្រភេទផ្សេងៗទៀត** ..... ១២

២.៣.១. ការបែងចែកទៅតាមទម្រង់នៃអំពើប្រព្រឹត្ត ..... ១២

២.៣.១.១. បទល្មើសភ្លាមៗ ............ ១២
២.៣.១.២. បទល្មើសបន្តជាហូរហែ ............ ១៣
២.៣.១.៣. បទល្មើសអចិន្ត្រៃយ៍ ............ ១៣
២.៣.១.៤បទល្មើសប្រព្រឹត្តជាទម្លាប់ ............ ១៣
២.៣.១.៥. បទល្មើសមិនស្មុគស្មាញ ............ ១៤
២.៣.១.៦. បទល្មើសស្មុគស្មាញ ............ ១៤
២.៣.២. ការបែងចែកដោយផ្អែកលើធាតុសត្យានុម័ត ............ ១៥
២.៣.២.១. បទល្មើសសកម្ម និងបទល្មើសអកម្ម ............ ១៥
២.៣.២.២. បទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែង ............ ១៥
២.៣.២.៣. បទល្មើសសម្ភារៈ និងបទល្មើសរូបភាព ............ ១៦
២.៣.៣. ការបែងចែកដោយផ្អែកលើធាតុអត្តនោម័ត ............ ១៦
២.៣.៣.១. បទល្មើសដោយចេតនា ............ ១៧
២.៣.៣.២. បទល្មើសដោយអចេតនា ............ ១៧
**២.៤. ការបែងចែងដាច់ពីគ្នារវាងបទល្មើសយោធា នយោបាយ និងគ្រឿងញៀន** ............ ១៧
២.៤.១. បទល្មើសយោធា ............ ១៧
២.៤.២. បទល្មើសនយោបាយ ............ ១៨
២.៤.៣. បទល្មើសគ្រឿងញៀន ............ ១៩
**២.៥. ការបែងចែកបទល្មើសទាក់ទងនឹងសមត្ថកិច្ច** ............ ២០

**ជំពូកទី៣**

**ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ**

**៣.១. ធាតុនីត្យានុកូល (ធាតុច្បាប់)** ............ ២១
៣.១.១. គោលការណ៍នីត្យានុកូលភាព ............ ២១
៣.១.១.១. នីត្យានុកូលភាពនៃបទល្មើស ............ ២២
៣.១.១.២. នីត្យានុកូលភាពនៃទោស ............ ២៣
៣.១.២. ការបកស្រាយត្រឹមត្រូវតាមច្បាប់ព្រហ្មទណ្ឌ ............ ២៣
៣.១.៣.  ដែននៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ ............ ២៤
៣.១.២.១. វិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌតាមពេលវេលា ............ ២៤
ក. ការអនុវត្តច្បាប់ដែលបានលុបចោលបទល្មើស ............ ២៤

ខ. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង ..... ២៤
គ. គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាង ..... ២៥
៣.១.២.២. វិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ ..... ២៥
ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ..... ២៦
ខ. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ..... ២៧
**៣.២. ធាតុសត្យានុម័ត (ធាតុសម្ភារៈ)** ..... ២៨
៣.២.១. បទល្មើសបានសម្រេច ..... ២៨
៣.២.១.១. អំពើសកម្ម ..... ២៨
៣.២.១.២. អំពើអកម្ម ..... ២៩
៣.២.២. បទល្មើសមិនបានសម្រេច ឬអំពើប៉ុនប៉ង ..... ២៩
៣.២.២.១. លក្ខខណ្ឌនៃអំពើប៉ុនប៉ង ..... ៣០
ក. ការចាប់ផ្ដើមប្រព្រឹត្ត ..... ៣០
ខ. ការបញ្ឈប់រឹញក្រៅពីឆន្ទៈរបស់ជនល្មើស ..... ៣១
៣.២.២.២. ទណ្ឌកម្មនៃអំពើប៉ុនប៉ង ..... ៣២
៣.២.៣. ហេតុ បច្ច័យ ..... ៣៣
**៣.៣. ធាតុអត្តនោម័ត (ធាតុចិត្តសាស្ត្រ)** ..... ៣៤
៣.៣.១. កំហុសចេតនា ..... ៣៤
៣.៣.១.១. ចេតនាទុច្ចរិតទូទៅ ..... ៣៥
៣.៣.១.២. ចេតនាទុច្ចរិតពិសេស ..... ៣៥
៣.៣.១.៣. ចេតនាទុច្ចរិតធ្ងន់ធ្ងរ ..... ៣៥
៣.៣.១.៤. ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ ..... ៣៦
៣.៣.១.៥. ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់ ..... ៣៦
៣.៣.២. កំហុសអចេតនា ..... ៣៧
៣.៣.៣. ការវាយតម្លៃអំពីកំហុសចេតនា និងកំហុសអចេតនា ..... ៣៨
៣.៣.៣.១. ការភាន់ច្រឡំអំពីច្បាប់ ..... ៣៨
៣.៣.៣.២. ការភាន់ច្រឡំពីអំពើ ឬពីអង្គហេតុ ..... ៣៨
ក. ការភាន់ច្រឡំលើធាតុផ្សំសំខាន់នៃបទល្មើស ..... ៣៨
ខ. ការភាន់ច្រឡំដែលមិនអាចជៀសវាងបាន ..... ៣៩

## ជំពូកទី៤
## អំពីជនល្មើស

**៤.១. ប្រភេទនៃជនល្មើស** ........ ៤០
៤.១.១. ជនល្មើសជាចារី ........ ៤០
៤.១.២. សហចារី ........ ៤០
៤.១.៣. អ្នកផ្ដើមគំនិត ........ ៤១
៤.១.៤. អ្នកសមគំនិត ........ ៤១
**៤.២. មូលហេតុនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស** ........ ៤២
៤.២.១. មូលហេតុនៅក្នុងមជ្ឈដ្ឋានសង្គម ........ ៤២
៤.២.១.១. ឥទ្ធិពលនៃស្ថានភាពសេដ្ឋកិច្ច ........ ៤២
៤.២.១.២. ឥទ្ធិពលនៃរបបនយោបាយ ........ ៤៣
៤.២.១.៣. ឥទ្ធិពលនៃសង្គ្រាម ........ ៤៣
៤.២.១.៤. ឥទ្ធិពលនៃការគ្រប់គ្រងសេដ្ឋកិច្ចសង្គម ........ ៤៣
៤.២.១.៥. ឥទ្ធិពលនៃវប្បធម៌អប់រំ ........ ៤៤
៤.២.១.៦. ឥទ្ធិពលនៃប្រព័ន្ធច្បាប់ ........ ៤៤
៤.២.២. មូលហេតុផ្សេងៗទៀត ........ ៤៤
៤.២.២.១. ចិត្តសាស្ត្រ ........ ៤៥
៤.២.២.២. ការសិក្សាពីតំណពូជ ........ ៤៥
៤.២.២.៣. ចរិយាមាយាទរបស់បុគ្គល ........ ៤៥
៤.២.២.៤. ការវិវត្តន៍ស្ថានភាពជាក់ស្ដែង ........ ៤៦
៤.២.២.៥. កត្តាជនរងគ្រោះ ........ ៤៦
**សេចក្តីសន្និដ្ឋាន** ........ ៤៨
**អនុសាសន៍** ........ ៥០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មានចំនួន ៦៧២ មាត្រា។ ក្រមព្រហ្មទណ្ឌនេះបានចូលជាធរមាននៅរាជធានីភ្នំពេញ ១០ថ្ងៃ ក្រោយពេលប្រកាសឱ្យប្រើ គឺថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ និង២០ថ្ងៃ ក្រោយពេលប្រកាសឱ្យប្រើនៅទូទាំងប្រទេស គឺថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩។ តាមមាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ បទបញ្ញត្តិទូទៅនៃ គន្ថីទី១ នៃក្រមព្រហ្មទណ្ឌត្រូវយកមកអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ ចំណែកឯបទបញ្ញត្តិផ្សេងទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ឆ្នាំក្រោយការចូលជាធរមាននៃក្រម។ ដូច្នោះ ចាប់តាំងពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ បទបញ្ញត្តិទាំងអស់នៃក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តទូទាំងប្រទេសកម្ពុជារហូតមកដល់បច្ចុប្បន្ននេះ។ ក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិច្បាប់ដែលចែងអំពីបទល្មើស និងទោសដែលត្រូវអនុវត្តទៅលើបុគ្គលដែលប្រព្រឹត្តល្មើសច្បាប់ព្រហ្មទណ្ឌ។ ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសផ្សេងៗទៀតដែលត្រូវយកមកអនុវត្តទន្ទឹមនឹងគ្នាផងដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីរបបសារពត៌មាន ជាដើម។ ជារួមមក ច្បាប់ព្រហ្មទណ្ឌរមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវចំពោះបទល្មើស ហើយក្រមនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុង **ការបង្ក្រាប** បានន័យថាបង្ក្រាបរាល់អំពើផ្ទុយច្បាប់ព្រហ្មទណ្ឌ រឺឯ **ការបង្ការ** គឺបង្ការសម្រាប់ទណ្ឌិត និងសម្រាប់ជនដទៃទៀតផងព្រោះបើជនណាម្នាក់ហ៊ានប្រព្រឹត្តអំពើល្មើសជននោះនឹងត្រូវទទួលនឹងទណ្ឌកម្មផ្សេងៗ និង **ការអប់រំ** ធ្វើយ៉ាងណាឱ្យទណ្ឌិតចូលចុះក្នុងសង្គមវិញតាមរយៈវិធានការផ្សេងៗ។

ដូចបានជ្រាបច្បាស់ហើយថា បច្ចុប្បន្ននេះគ្រប់ប្រទេសទាំងអស់នៅលើពិភពលោកមានការអភិវឌ្ឍទៅរកភាពជឿនលឿនមិនថាវិស័យនយោបាយ វិស័យសេដ្ឋកិច្ច ព្រមទាំងវិស័យផ្សេងៗទៀតធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋរបស់ខ្លួនរស់នៅដោយប្រើប្រាស់សិទ្ធិសេរីភាពរបស់ពួកគេពេញលេញ។ លើសពីនេះទៅទៀត ការរស់នៅក្នុងសង្គមមួយមនុស្សម្នាក់ៗមិនអាចរស់នៅដោយមិនប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកនោះទេ។ ក្នុងការប្រាស្រ័យទាក់ទងគ្នាក៏តែងតែមានបញ្ហាមួយចំនួនកើតឡើងនោះ គឺជម្លោះនេះឯង។ ជម្លោះនេះហើយជាប្រភពដែលធ្វើឱ្យមានការរំលោភបំពានដល់សិទ្ធិផ្សេងៗរបស់បុគ្គល ឬអាចឈានដល់ការប្រព្រឹត្តបទល្មើសផ្សេងៗដែលបៀតបៀនទៅលើបុគ្គលដែលជាជនស្លូតត្រង់ផងដែរ។ បទល្មើសដែលបានកើតឡើងមិនថានៅទីក្រុងក្តី ឬទីប្រជុំជន ឬតំបន់ដែលដាច់ស្រយាលសុទ្ធតែផ្តល់ផលវិបាកដែលជះឥទ្ធិពលអាក្រក់ដល់សង្គមជាតិទាំងមូល។ ហេតុដូចនេះហើយប្រទេសជាច្រើនក៏ដូចជាប្រទេសកម្ពុជាបានខិតខំបង្កើតនូវក្រមព្រហ្មទណ្ឌរួមទាំងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធឡើងមក ដើម្បីការការពារដល់មនុស្សដែលបានរងនូវគ្រោះថ្នាក់

ដោយសារការរំលោភបំពានលើសិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ រួមទាំងទ្រព្យសម្បត្តិប្រជាពលរដ្ឋនៅក្នុងសង្គមពីសំណាក់ជនដែលប្រព្រឹត្តអំពើល្មើស។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំណុចសំខាន់ដែលមានការចោទសួរទៅលើការស្រាវជ្រាវ គឺពាក់ព័ន្ធនឹងចំណាត់ថ្នាក់នៃបទល្មើស និងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ។ យើងខ្ញុំសូមលើកយកនូវចំណោទបញ្ហាមួយចំនួនដែលមានដូចតទៅៈ

- តើអំពើល្មើសទាំងអស់សុទ្ធតែជាបទល្មើសព្រហ្មទណ្ឌ ឬយ៉ាងណា?
- ហេតុអ្វីបានជាគេចាំបាច់ចែកចំណាត់ថ្នាក់បទល្មើស?
- ដើម្បីកំណត់បទល្មើសព្រហ្មទណ្ឌបានត្រូវមានធាតុផ្សំនៃបទល្មើសអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទមួយនេះ មានគោលបំណងដោយសិក្សាកាន់តែល្អិតល្អន់រាល់បញ្ហាស្ថិតក្នុងមុខសញ្ញាសម្របសម្រួលនៃនីតិព្រហ្មទណ្ឌស្រាវជ្រាវ ដោយផ្អែកលើ បទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌដែលកំណត់អំពីបទល្មើស កត្តារួមផ្សំនៃបទល្មើសមូលដ្ឋាន ឬហៅម្យ៉ាងទៀតថាធាតុផ្សំនៃបទល្មើសរួមជាមួយនឹងផលប្រយោជន៍ផ្សេងៗសម្រាប់ស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ព្រមទាំងស្វែងរកនូវពិរុទ្ធិភាពរបស់ជនដែលបានប្រព្រឹត្តមកផ្តន្ទាទោសយ៉ាងពិតប្រាកដ។ សមិទ្ធផលនៃការស្រាវជ្រាវនេះ គឺជាផ្នែកមួយក្នុងការជួយលើកស្ទួយឱ្យមានភាពរីកចម្រើនលើវិស័យច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជាជំនួយសម្រាប់អ្នកច្បាប់ក៏ដូចជានិស្សិតច្បាប់ក្នុងការសិក្សា និងអនុវត្តលើផ្នែកច្បាប់ទៅមុខប្រកបដោយប្រសិទ្ធិភាពផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំទាំងពីរសូមលើកយកនូវសញ្ញាណទូទៅ ហើយក៏មានចំណាត់ថ្នាក់នៃបទល្មើសមកបំភ្លឺព្រោះថាបទល្មើសទាំងអស់មិនសុទ្ធតែជាអំពើធ្ងន់ធ្ងរទាំងអស់ ឬក៏ជាអំពើល្មើសស្រាលទាំងអស់នោះដែរ មូលហេតុនេះហើយដើម្បីឱ្យមានភាពយុត្តិធម៌ទើបគេធ្វើការកំណត់ចំណាត់ថ្នាក់នេះឡើង។ ចំណែកឯធាតុផ្សំនៃបទល្មើសក្នុងដែននៃការបកស្រាយរបស់យើងខ្ញុំ គឺជាលំអិតទៅលើធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពីបាន ធ្វើការស្រាវជ្រាវទៅលើប្រធានបទស្តីពី " **ការកំណត់បទល្មើសព្រហ្មទណ្ឌ** " នាំឱ្យនាងខ្ញុំទាំងពីរបានទទួលចំណេះដឹងបន្ថែមនឹងយល់ដឹងអំពីសារៈប្រយោជន៍ក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌដែលត្រឹមត្រូវ។ អស់រយៈពេល ៤ឆ្នាំ ដែលនាងខ្ញុំទាំងពីរនាក់បានធ្វើការសិក្សាផ្នែកនីតិសាស្ត្រនេះ មុខវិជ្ជាដែលយើងមានចំណាប់អារម្មណ៍នឹងចង់សិក្សាស្វែងយល់នោះគឺមុខវិជ្ជានីតិព្រហ្មទណ្ឌនេះ។ យើងខ្ញុំទាំងពីរនាក់យល់

ឃើញថាការសិក្សាទាក់ទងពីបទល្មើសនៅមានលក្ខណៈស្មុគស្មាញ ដែលតម្រូវឱ្យមានចំណាយពេលវេលាក្នុងការស្រាវជ្រាវជាច្រើនទៅលើវា ហើយបទល្មើសនីមួយៗមានលក្ខណៈខុសគ្នាទៅតាមអង្គហេតុជាក់ស្តែង។ ចំពោះឯកសារស្នាដៃនេះក៏ជាប្រភពព័ត៌មានដែលជំនួយទៅដល់និស្សិតជំនាន់ក្រោយ មិត្តនិស្សិត ព្រមទាំងសាធារណៈជនដែលមានបំណងចង់យល់ដឹងទៅលើរបៀបនៃការកំណត់បទល្មើសនេះជាដើម។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីជម្រុញឱ្យការស្រាវជ្រាវមួយនេះទទួលបានសមិទ្ធផល គឺចាំបាច់ទាមទារការចំណាយពេលវេលាក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធជាច្រើន និងប្រមូលព័ត៌មានទាំងអស់ដែលយើងគិតថាទាក់ទងនឹងប្រធានបទស្រាវជ្រាវខាងលើ។ ប្រសិនបើមានភាពស្រពិចស្រពិលទៅលើឯកសារដែលរកបានមក យើងអាចសាកសួរយោបល់ពីសាស្ត្រាចារ្យណែនាំជាមុន ជៀសវាងការដាក់ឯកសារខុស ឬឯកសារដែលមិនផ្តល់ជាប្រយោជន៍។ ការស្រាវជ្រាវនេះត្រូវបានបែងចែកប្រភពជាពីរគឺ៖ ប្រភពចម្បង និងប្រភពបន្ទាប់បន្សំ។ តាមលទ្ធភាពនៃការសិក្សាស្រាវជ្រាវជាក់ស្តែង វិធីប្រមូលព័ត៌មាន ត្រូវបានរៀបរាប់ដូចតទៅ៖

- **ប្រភពចម្បង**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
  - អនុសញ្ញា កាតិកាសញ្ញាអន្តរជាតិ ផ្សេងៗដែលពាក់ព័ន្ធ
  - ក្រមព្រហ្មទណ្ឌ អន្តរកាល និងក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
  - ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- **ប្រភពបន្ទាប់បន្សំ**
  - ឯកសារដែលបានមកពីមេរៀនដែលធ្លាប់បានសិក្សាជាមួយលោកគ្រូ និងអ្នកគ្រូកន្លងមក
  - សៀវភៅស្នាដៃរបស់សាស្ត្រចារ្យឯកទេសខាងវិស័យច្បាប់ព្រហ្មទណ្ឌ
  - ឯកសារដែលបានមកពីក្រមព្រហ្មទណ្ឌទូទៅ
  - ការស្រាវជ្រាវឯកសារតាមប្រព័ន្ធអ៊ិនធឺណែត
  - ការស្រាវជ្រាវនូវឯកសារនៅបណ្ណាល័យផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ឯកសារដែលបានមកពីការណែនាំរបស់លោកសាស្ត្រាចារ្យដឹកនាំ
  - ឯកសារដែលបានមកពីការណែនាំរបស់សិស្សច្បង ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវចែកចេញជា ៤ ជំពូកដូចជា៖

- **សេចក្តីផ្តើម**
- **ជំពូកទី១ ៖ សញ្ញាណទូទៅ**
- **ជំពូកទី២ ៖ ចំណាត់ថ្នាក់នៃបទល្មើស**
- **ជំពូកទី៣ ៖ ធាតុផ្សំនៃបទល្មើស**
- **ជំពូកទី៤ ៖ អំពីជនល្មើស**
- **សេចក្តីសន្និដ្ឋាន**
- **អនុសាសន៍**
- **ឯកសារយោង**
- **ឧបសម្ព័ន្ធ។**

# ជំពូកទី១

# សញ្ញាណទូទៅ

# ជំពូកទី១

# សញ្ញាណទូទៅនៃបទល្មើស

## ១.១. និយមន័យ

បទល្មើសព្រហ្មទណ្ឌ ត្រូវបានគេឱ្យនិយមន័យថាជាអំពីដែលប្រព្រឹត្តដោយចេតនាក្ដី និងអចេតនាក្ដីដែលវាបង្កគ្រោះថ្នាក់ដល់សង្គម ត្រូវផ្ដន្ទាទោសតាមការកំណត់ទុកជាមុននៃច្បាប់ព្រហ្មទណ្ឌ ឬនិយាយសាមញ្ញថាជាអំពើបំពានច្បាប់ព្រហ្មទណ្ឌ។

## ១.២. លក្ខណៈសំគាល់នៃបទល្មើស

បទល្មើសដែលបានកើតឡើង ត្រូវតែមានព្យសនកម្មពិតប្រាកដមួយដល់សណ្ដាប់ធ្នាប់សង្គម។ លក្ខណៈសម្គាល់នៃបទល្មើស គឺមានចរិតគ្រោះថ្នាក់ដល់សង្គម (**១.២.១.**) ចរិតកំហុសនៃអំពើ (**១.២.២.**) ចរិតផ្ទុយច្បាប់ (**១.២.៣.**) និងចរិតទទួលទោសទណ្ឌ (**១.២.៤.**)។

### ១.២.១. ចរិតគ្រោះថ្នាក់ដល់សង្គម

ចរិតគ្រោះថ្នាក់ដល់សង្គមនៃបទល្មើស ស្ដែងឡើងត្រង់ចំណុចថាអំពើនោះបានបង្កនូវការអន្ដរាយដល់បណ្ដាទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌបានការពារ។ ដោយអំពើនោះបានជះឥទ្ធិពលដល់ការធានាឱ្យមានការរីកចំរើនរបស់សង្គម។ នៅពេលដែលអំពើល្មើសរបស់បុគ្គលណាម្នាក់បានធ្វើឱ្យមានការអន្ដរាយដល់ទំនាក់ទំនងសង្គម ពោលគឺប្រសិនបើមិនមានការរារាំងណាមួយនោះទេវាអាចបង្កឱ្យមានមហន្ដរាយ។ម្យ៉ាងទៀតវាជាការសំអាងសម្រាប់ពិចារណា និងសម្រេចអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងពេលដោះស្រាយបញ្ហាកំណត់កម្រិតទោសដែលត្រូវអនុវត្តទៅលើបុគ្គលណាដែលបានប្រព្រឹត្តបទល្មើស។

### ១.២.២. ចរិតកំហុសនៃអំពើ

រាល់ការប្រព្រឹត្តអំពើណាមួយដែលជាការគ្រោះថ្នាក់ដល់សង្គមដោយចេតនា ឬអចេតនាត្រូវបានចាត់ទុកថាជាអំពើដែលមានកំហុស។ ប្រសិនបើសកម្មភាពនោះអាចជាលទ្ធផលដែលជននោះបានជ្រើសរើស និងសម្រេចដោយខ្លួនឯងក្នុងស្ថានភាពដែលខ្លួនអាចជ្រើសរើស និងសម្រេចប្រព្រឹត្តនៅអំពើណាមួយផ្សេងទៀតបានដើម្បីស្របនឹងផលប្រយោជន៍ដែលបានកំណត់ទុករបស់សង្គម ឬច្បាប់។

### ១.២.៣. ចរិតផ្ទុយច្បាប់

ចរិតផ្ទុយច្បាប់នៃអំពើល្មើស គឺជាសញ្ញាសំគាល់មួយនៃបទល្មើសដែលបដិសេធប្រហាក់ប្រហែលនៃច្បាប់ព្រហ្មទណ្ឌដែលកន្លងមកប្រទេសមួយចំនួនបានអនុវត្តគោលការណ៍នេះ។ ការចោទប្រកាន់លើអំពើល្មើសណាមួយលុះត្រាតែមានច្បាប់ចែង តែបើមិនមានការចែងថាអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌទេ គេមិនអាចធ្វើការចោទប្រកាន់បានទេ។ ដូចនេះហើយរាល់អំពើដែលបង្កឱ្យមានអន្ដរាយដល់សង្គមត្រូវតែបានបង្ក្រាបដោយ

វិធានការព្រហ្មទណ្ឌ ប៉ុន្តែការដោះស្រាយ និងវិនិច្ឆ័យរឿងក្តីព្រហ្មទណ្ឌត្រូវពឹងផ្អែកលើមូលដ្ឋានមានច្បាប់បញ្ញត្តិតែប៉ុណ្ណោះ។

### ១.២.៤. ចរិតទទួលទោសទណ្ឌ

ការចាប់បង្ខំឱ្យជនដែលបានប្រព្រឹត្តនូវអំពើដែលគ្រោះថ្នាក់ដល់សង្គមឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាវិធានដែលតឹងតែងបំផុតរបស់រដ្ឋ។ ក្នុងបណ្តាបទល្មើសដែលជាអំពើរំលោភបំពានច្បាប់ទាំងអស់ គឺមានតែបទល្មើសទេទើបនាំមកនូវបច្ច័យគតិយុត្តនាំឱ្យជនល្មើសត្រូវទទួលរងនូវទោសទណ្ឌ។ ផ្ទុយទៅវិញ មិនសុទ្ធតែគ្រប់ជនដែលប្រព្រឹត្តបទល្មើសទាំងអស់សុទ្ធតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

## ១.៣. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្សេងទៀត

ជាទូទៅបទល្មើសជាអំពើខុសនឹងសីលធម៌សង្គម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងបង្កព្យសនកម្មគួរឱ្យកត់សម្គាល់មកលើសង្គមទាំងមូល។ ដោយឡែក បច្ចុប្បន្ននេះបទល្មើសដែលបានកើតមានឡើងវាមានលក្ខណៈច្របូកច្របល់អំពើខ្លះអាចមិនបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គមនោះទេ ហើយការទទួលខុសត្រូវទៅលើកំហុសនោះក៏មានលក្ខណៈខុសពីគ្នាទៅតាមលទ្ធផលដែលកើតចេញពីអំពើនោះដែរ។ ហេតុដូច្នេះចាំបាច់ណាស់ដែលត្រូវតែពិនិត្យមើលពីភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសដទៃទៀត។ យើងនឹងមកធ្វើការយល់ឱ្យបានកាន់តែច្បាស់ពីភាពខុសគ្នារវាបទល្មើសព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី (**១.៣.១.**) និងភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងអំពើល្មើសផ្នែកវិន័យ (**១.៣.២.**)។

### ១.៣.១. ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី

អំពើល្មើសជាបទល្មើសព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណីមានលក្ខណៈខុសប្លែកពីគ្នា ដោយអំពើជាបទល្មើសព្រហ្មទណ្ឌ អាចចាត់ថាជាបទល្មើសបានលុះត្រាតែមានចែងច្បាស់លាស់ថាជាបទល្មើសព្រហ្មទណ្ឌតាមគោលការណ៍នីត្យានុកូលភាព។[1] អំពើល្មើសផ្នែករដ្ឋប្បវេណីកំណត់ថាបុគ្គលដែលបំពានខុសច្បាប់នូវសិទ្ធិ ឬផលប្រយោជន៍របស់ជនដទៃដោយកំហុសចេតនា ឬដោយអចេតនា ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតឡើងដោយអំពើនោះ។[2] ចំពោះផ្នែករដ្ឋប្បវេណី អាចឱ្យតុលាការដាក់ទណ្ឌកម្មបានលុះត្រាតែមានព្យសនកម្ម ប៉ុន្តែការដាក់ទណ្ឌកម្មរដ្ឋប្បវេណីគ្រាន់តែបង់សំណងជម្ងឺចិត្តសម្រាប់ប្រគល់ឱ្យជនរងគ្រោះខុសពីការបង្កើតបទល្មើសព្រហ្មទណ្ឌពុំសុទ្ធតែមានព្យសនកម្មទេដូចជា ការបើកបរក្នុងល្បឿនលឿនខុសច្បាប់ជាដើម។ម្យ៉ាងទៀតក្នុងការបង់សំណង់ជម្ងឺចិត្តដែលជាទណ្ឌកម្មរដ្ឋប្បវេណីនោះ ត្រូវបង់ទៅឱ្យជនរងគ្រោះព្រោះថាប្រាក់សំណង់ជម្ងឺចិត្តមានគោលដៅត្រឹមជួសជុលការខូចខាត ដែលផ្ទុយពីទោសដែលជាទោសព្រហ្មទណ្ឌមានគោល

[1] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[2] មាត្រា ៧៤៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដៅការពារសង្គមនឹងមិនត្រូវបានជាប្រយោជន៍ដល់ជនរងគ្រោះទេ ពោលគឺប្រាក់ពិន័យនោះទុកជាថវិការបស់រដ្ឋ។[3] ពេលខ្លះអំពើល្មើសជាបទល្មើសព្រហ្មទណ្ឌតែពុំមែនជាអំពើល្មើសផ្នែករដ្ឋប្បវេណីទេដូចជា ការជួញដូរគ្រឿងញៀន ការមិនគោរពភ្លើងស្តុបជាដើម។ ផ្ទុយទៅវិញ អំពើមួយអាចត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌផង និងផ្នែករដ្ឋប្បវេណីផងដែរ ដូចជាបទហិង្សាដោយចេតនាចំពោះអ្នកដទៃជាដើម។ ក្នុងករណីបែបនេះ អំពើល្មើសអាចនាំឱ្យមានបណ្តឹងពីរគឺ បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីដោយបណ្តឹងទាំងពីរនេះអាចធ្វើឡើងចំពោះមុខតុលាការព្រហ្មទណ្ឌតែមួយ ឬក៏ចំពោះមុខតុលាការព្រហ្មទណ្ឌផង និងតុលាការរដ្ឋប្បវេណីផងក៏បានដែរ។

### ១.៣.២.ភាពខុសគ្នារវាងបទល្មើសព្រហ្មទណ្ឌ និងផ្នែកវិន័យ

អំពើល្មើសខាងវិន័យ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជាសមូហភាពនៃក្រុមសង្គមណាមួយ (រួមមាន ពេទ្យ មេធាវី និស្សិតជាដើម) ហើយអំពើនោះមិនត្រូវបានកំណត់ឱ្យច្បាស់លាស់ទូទៅទេ។ យ៉ាងណាមិញបទល្មើសព្រហ្មទណ្ឌ ទោះបីជាមានចំនួនច្រើនក៏ពិតមែនប៉ុន្តែច្បាប់បានកំណត់ច្បាស់លាស់ជាមុនរួចស្រេចអស់ទៅហើយ មានន័យថាអំពើណាដែលមានច្បាប់កំណត់ថាជាបទល្មើសត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ។[4] ជាលទ្ធផលអំពើល្មើសផ្នែកវិន័យធ្វើឱ្យប៉ះពាល់ផ្នែកណាមួយនៃសង្គមតែប៉ុណ្ណោះ ពោលគឺក្រុមសង្គមដែលជនប្រព្រឹត្តស្ថិតនៅ។ ដោយឡែកបើសិនជាបទល្មើសព្រហ្មទណ្ឌវិញ ជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សង្គមជាទូទៅ ឬនិយាយម្យ៉ាងទៀតថាបទល្មើសព្រហ្មទណ្ឌធ្វើឱ្យប៉ះពាល់ដល់សង្គមមនុស្សច្រើនជាងអំពើល្មើសផ្នែកវិន័យទៅទៀត។ ចំពោះទណ្ឌកម្មទៅលើអំពើល្មើសផ្នែកវិន័យត្រូវធ្វើដោយស្ថាប័នពិសេសសម្រាប់ក្រុមសង្គមណាមួយ ចំណែកឯការដាក់ទណ្ឌកម្មព្រហ្មទណ្ឌវិញជាសមត្ថកិច្ចរបស់សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយទណ្ឌកម្មអាចមានលក្ខណៈធ្ងន់ធ្ងររហូតដល់ការដាក់ពន្ធនាគារអស់មួយជីវិតទៀតផង។ ម្យ៉ាងវិញទៀតគេសង្កេតឃើញថាមានអំពើមួយចំនួនដែលត្រូវចាត់ចូលជាអំពើល្មើសផ្នែកវិន័យផង និងជាបទល្មើសព្រហ្មទណ្ឌផង។ ឧទាហរណ៍ : នៅពេលដែលអតិថិជនម្នាក់មកពិនិត្យព្យាបាលជម្ងឺនៅក្នុងគ្លីនិកក៏ស្រាប់តែកើតការឈ្លោះប្រកែកគ្នាជាមួយវេជ្ជបណ្ឌិតដែលពិនិត្យព្យាបាល ហើយក៏បណ្តាលឱ្យវេជ្ជបណ្ឌិតនោះជ្រុលដៃសម្លាប់អតិថិជនរបស់ខ្លួនស្លាប់ទៅ។ ហេតុដូច្នេះហើយ អំពើរបស់វេជ្ជបណ្ឌិតខាងលើគឺជាបទឃាតកម្មផង (បទល្មើសព្រហ្មទណ្ឌ) និងជាអំពើល្មើសផ្នែកវិន័យផងដែរ។

[3] មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[4] គោលការណ៍នីត្យានុកូលភាព (Principle of legality)

# ជំពូកទី២

# ចំណាត់ថ្នាក់នៃបទល្មើស

# ជំពូកទី២
# ចំណាត់ថ្នាក់នៃបទល្មើស

## ២.១. ការបែងចែកបទល្មើសតាមច្បាប់

ច្បាប់ព្រហ្មទណ្ឌបានធ្វើការកំណត់បទល្មើស ដើម្បីដាក់ទណ្ឌកម្មទៅលើជនល្មើសដោយផ្អែកលើអំពើប្រព្រឹត្តដែលបណ្ដាលឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម ឬប៉ះពាល់ដល់សិទ្ធិសេរីភាព សេចក្ដីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងទ្រព្យសម្បត្តិផងដែរ។ ចំណាត់ថ្នាក់បទល្មើសព្រហ្មទណ្ឌចែកចេញជា ៣ ប្រភេទ ដោយផ្អែកទៅតាមទម្ងន់របស់វាដោយបានចាត់ថ្នាក់ជាបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ស្រប ទៅតាមទម្ងន់បទល្មើស។[5] ស្ថានទម្ងន់នៃទោសទៅតាមបទល្មើសនីមួយៗខាងលើ អាចនឹងត្រូវពិន័យជាពីរប្រភេទគឺ ទោសពន្ធនាគារ និងពិន័យជាប្រាក់។ គួរបញ្ជាក់ដែរថា ចំពោះប្រាក់នៃការពិន័យទាំងនោះនឹងត្រូវដាក់ចូលជាថវិការដ្ឋ។[6]

### ២.១.១. បទលហុ

បទលហុ ជាប្រភេទនៃបទល្មើសដែលមានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើនឹង ៦ថ្ងៃ ឬតម្រូវពិន័យជាប្រាក់បន្ថែមលើទោសពន្ធនាគារ ចំពោះប្រភេទនៃបទល្មើសនេះផងដែរ អាចត្រឹមតែទទួលរងពិន័យត្រឹមតែជាប្រាក់ប៉ុណ្ណោះ។[7] បទល្មើសដែលចាត់ជាបទល្មើសក្នុងបទលហុមានដូចជា បទបរិហារកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថជាសាធារណៈ បទធ្វើឱ្យមានការខូចខាត បទប្រមាថចំពោះព្រះសង្ឃ ដូនជី និងតាជីជាដើម។[8]

### ២.១.២. បទមជ្ឈិម

បទមជ្ឈិម ជាប្រភេទបទល្មើសទាំងឡាយណាដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ។ បន្ថែមពីនេះទៅទៀត ទោសដាក់ពន្ធនាគារបុគ្គលដែលការប្រព្រឹត្តអំពើទាំងឡាយណាដែលចាត់ចូលជាបទមជ្ឈិមអាចប្រឈមនឹងការទទួលរងពិន័យជាប្រាក់ផងដែរ[9] ហើយចំពោះបទមជ្ឈិមអាចជាបទល្មើសដូចជា បទហិង្សាដោយចេតនា បទល្មើសធ្វើឱ្យខូចខាតដោយចេតនា ការកាន់កាប់អាវុធដោយគ្មានការអនុញ្ញាតជាដើម។

[5] មាត្រា ២ វាក្យខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[6] មាត្រា ៥២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[7] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[8] មាត្រា ៥១៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[9] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ២.១.៣. បទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តអំពើបណ្ដាលឱ្យគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គម ហើយទណ្ឌកម្មទៀតសោតក៏មានទម្ងន់ធ្ងន់ធ្ងរផងដែរ។ បទល្មើសនេះដែលមានអតិបរិមានៃទោសដាក់ពន្ធនាគារដែលមានរយៈពេលអាចពន្ធនាគារអស់មួយជីវិត ឬពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬស្មើ ៣០ឆ្នាំ ក្នុងទោសនេះអាចនឹងត្រូវពិន័យបន្ថែមជាមួយនឹងទោសពិន័យជាសាច់ប្រាក់។ បទល្មើសដែលជាបទឧក្រិដ្ឋ មានដូចជា : បទឃាតកម្ម បទរំលោភសេពសន្ថវៈជាដើម (ដែលការទទួលទណ្ឌកម្មមិនមែនជាទណ្ឌមួយជីវិតនោះទេ)។

**<u>តារាងសង្ខេបសម្គាល់នូវចំណាត់ថ្នាក់នៃបទល្មើសនិងទោសកំណត់តាមមាត្រា៤៦ មាត្រា៤៧ និងមាត្រា៤៨</u>**

| លរ | ចំណាត់ថ្នាក់នៃបទល្មើស | លក្ខណៈវិនិច្ឆ័យទី ១ | លក្ខណៈវិនិច្ឆ័យទី ២ |
|---|---|---|---|
| ១ | បទលហុ | ពិន័យជាប្រាក់សុទ្ធសាធ | ជាប់ពន្ធនាគារក្រោមឬស្មើ ៦ ថ្ងៃ |
| ២ | បទមជ្ឈិម | គ្មានការដាក់ពន្ធនាគារអស់មួយជីវិតទេ | ជាប់ពន្ធនាគារពី ៦ថ្ងៃ និងក្រោមឬស្មើ ៥ឆ្នាំ |
| ៣ | បទឧក្រិដ្ឋ | ដាក់ពន្ធនាគារអស់មួយជីវិត | ជាប់ពន្ធនាគារពី ៥ឆ្នាំ និងក្រោមឬស្មើ ១៥ឆ្នាំ |
| ចំណុចរួម ៖ ទោសដាក់គុក អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ | | | |

## ២.២. ផលប្រយោជន៍ពីការបែងចែក

ជាការពិតណាស់ក្នុងការបែងចែកបទល្មើសព្រហ្មទណ្ឌនេះវាបានផ្ដល់ផលប្រយោជន៍ជាច្រើន ចំពោះអ្នកអនុវត្តច្បាប់ក្នុងការកំណត់នៅស្ថាននៃទម្ងន់ទោសដែលបុគ្គលណាម្នាក់បានប្រព្រឹត្តដោយចេតនៈ ឬអចេតនៈក្ដី។ ផលប្រយោជន៍ដែលបានពីការបែងចែកបទល្មើសទាំងនោះរួមមាន ផលប្រយោជន៍ទាក់ទិននឹងអាជ្ញាយុកាល (**២.២.១.**) ផលប្រយោជន៍នៃការអនុវត្តនីតិវិធី (**២.២.២.**) និងផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ង (**២.២.៣.**)។

### ២.២.១. ផលប្រយោជន៍ទាក់ទិននឹងអាជ្ញាយុកាល

អាជ្ញាយុកាលជារយៈពេលមួយក្នុងការកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះបុគ្គលម្នាក់អាចបាត់បង់សិទ្ធិណាមួយដែលខ្លួនមាន ឬអាចធ្វើការទាមទារសិទ្ធិណាមួយដែលជាប្រយោជន៍របស់ខ្លួន។ គួរបញ្ជាក់ដែរថាអាជ្ញាយុកាលនេះដែរត្រូវបានបែងចែងជាពីរប្រភេទរួមមានអាជ្ញាយុកាលនៃបទល្មើស ឬហៅម្យ៉ាងទៀតថាអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា (**២.២.១.១.**) និងអាជ្ញាយុកាលនៃទោស (**២.២.១.២**)។

#### ២.២.១.១. អាជ្ញាយុកាលនៃបទល្មើស

អាជ្ញាយុកាលនៃបទល្មើស គឺជារយៈពេលកំណត់ដោយច្បាប់កាលបើផុតរយៈពេលកំណត់នេះព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ទៅលើជនសង្ស័យណាមួយបានឡើយ ឬនិយាយសាមញ្ញគឺព្រះរាជអាជ្ញាពុំអាចធ្វើបណ្ដឹងអាជ្ញាឱ្យមានចលនាឡើយ។ ក្នុងគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអាជ្ញាយុកាលនៃបទល្មើស គឺគិតចាប់ពីពេលដែលចារីបានប្រព្រឹត្តបទល្មើសតទៅ និងមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើសនីមួយៗ។ អាជ្ញាយុកាលនៃបទល្មើស មានថិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញានោះមានដូចជា ចំពោះបទឧក្រិដ្ឋមានរយៈពេល**១៥ឆ្នាំ** ចំពោះបទមជ្ឈិមមានរយៈពេល**៥ឆ្នាំ** និងបទលហុមានរយៈពេល**១ឆ្នាំ**។[10] អាជ្ញាយុកាលលើបណ្ដឹងអាជ្ញាដែលដាក់ដោយព្រះរាជអាជ្ញាខាងលើត្រូវបាន លើកលែងតែក្នុងឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលរួមមាន បទឧក្រិដ្ឋប្រល័យពូជសាសន៍[11] បទល្មើសប្រឆាំងមនុស្សជាតិ[12] និងបទក្រិដ្ឋកម្មសង្គ្រាម[13] ដែលក្នុងបទល្មើសនេះតាមច្បាប់ពុំមានការកំណត់អាជ្ញាយុកាលនៃបទល្មើសឡើយ មានន័យថាបុគ្គលណាដែលប្រព្រឹត្តបទល្មើសទាំងនេះហើយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការដាក់បណ្ដឹងអាជ្ញាជានិច្ចហើយនៅពេលណាក៏បាន។[14]

**តារាងនៃអាជ្ញាយុកាលនៃបទល្មើសនីមួយៗបន្ថែមៈ**

| ល.រ | ចំណាត់ថ្នាក់នៃបទល្មើស | ច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ន | ច្បាប់អន្តរកាល |
|---|---|---|---|
| ១ | បទលហុ | ១ ឆ្នាំ | គ្មាន |
| ២ | បទមជ្ឈិម | ៥ ឆ្នាំ | ៣ ឆ្នាំ |
| ៣ | បទឧក្រិដ្ឋ | ១៥ ឆ្នាំ | ១៣ ឆ្នាំ |

[10] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[11] មាត្រា ១៨៣ និង ១៨៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[12] មាត្រា ១៨៨ និង ១៨៩ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[13] មាត្រា ១៩៣ និង ១៩៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[14] មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងមាត្រា ៩ នៃច្បាប់ស្ដីពីការប្រឆាំងនឹងភេរវកម្ម ឆ្នាំ២០០៧

#### ២.២.១.២. អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលនៃទោស ជារយៈពេលកំណត់ដោយច្បាប់មួយហើយកាលបើអាជ្ញាយុកាលនៃទោសត្រូវបានផុតរំលត់ហើយនោះទោសមិនអាចយកទៅអនុវត្តបានឡើយ។ រយៈពេលអាជ្ញាយុកាលនៃទោសដូចតទៅ នេះទោសទាំងឡាយណាដែលបានប្រកាសជាបទឧក្រិដ្ឋមានអាជ្ញាយុកាល**២០ឆ្នាំ** ទោសដែលបានប្រកាសជាបទមជ្ឈិមមានអាជ្ញាយុកាល**៥ឆ្នាំ** និងទោសដែលបានប្រកាសជាបទលហុមានអាជ្ញាយុកាល**១ឆ្នាំ**។[15]គួរបញ្ជាក់បន្ថែមថាអាជ្ញាយុកាលនៃទោសនេះ គឺគិតចាប់ពីពេលដែលតុលាការសម្រេចទោសចូលជាស្ថាពរ។

**តារាងនៃអាជ្ញាយុកាលនៃទោសនីមួយៗបន្ថែមះ**

| ល.រ | ចំណាត់ថ្នាក់នៃបទល្មើស | ច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ន |
|---|---|---|
| ១ | បទលហុ | ១ ឆ្នាំ |
| ២ | បទមជ្ឈិម | ៥ ឆ្នាំ |
| ៣ | បទឧក្រិដ្ឋ | ២០ ឆ្នាំ |

#### ២.២.២. ផលប្រយោជន៍នៃការអនុវត្តនីតិវិធី

មិនត្រឹមតែបានកំណត់ពី ការបែងចែកលើបទល្មើសនោះទេច្បាប់នៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់ពីនីតិវិធីក្នុងការអនុវត្តលើបញ្ញត្តិទោសនៃក្រមព្រហ្មទណ្ឌ ដែលជាច្បាប់សារជាតុដោយការកំណត់អំពីនីតិវិធីទាំងនេះវាបានផ្តល់ផលជាវិជ្ជមាន និងមានភាពងាយស្រួលទៅដល់អ្នកអនុវត្តច្បាប់ក្នុងការកំណត់ឱ្យច្បាស់លាស់ពីនីតិវិធីនៃបទទាំងឡាយណា ដែលចាត់ជាបទល្មើសព្រហ្មទណ្ឌដោយផ្អែកលើប្រភេទនៃបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ ជាក់ស្តែងដូចមានកំណត់នៅក្រមនីតិវិធីព្រហ្មទណ្ឌដែលករណីមានអំពើមួយជាបទឧក្រិដ្ឋបានកើតមានឡើងនោះ ព្រះរាជអាជ្ញាមានសិទ្ធិក្នុងការសុំចៅក្រមស៊ើបសួរត្រូវធ្វើការបើកការស៊ើបសួរដោយធ្វើការចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[16] ផ្ទុយទៅវិញបើជាបទលហុវិញនោះព្រះរាជអាជ្ញាមានសិទ្ធិធ្វើការកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅចំពោះមុខតុលាការជំនុំជម្រះដោយផ្ទាល់។[17] ក្នុងករណីជាបទឧក្រិដ្ឋ ការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយចៅក្រមបីរូបដែលសម្រេចសេចក្តីជាសមូហភាព ឬហៅថាក្រុមប្រឹក្សាជំនុំជម្រះដោយមានការចូលរួមរបស់តំណាងអយ្យការមួយរូប។ រីឯបទមជ្ឈិម និងបទលហុ ក្នុងនីតិវិធីនៃសាលាដំបូងការជំនុំជម្រះក្តីធ្វើឡើងដោយចៅក្រមទោល។[18]

[15] មាត្រា ១៤៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[16] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ២៨៩ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

#### ២.២.៣. ផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ងត្រូវចាត់ថាមានទោស

បទល្មើសប៉ុនប៉ង កំណត់តាមរយៈសកម្មភាពដែលចារីបានចាប់ផ្តើមអនុវត្តបទល្មើសដោយចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស ហើយចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែបែរជាត្រូវរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។ ទាក់ទងទៅនឹងបទល្មើសប៉ុនប៉ងត្រូវបានទោសដូចជា បទល្មើសនៃប៉ុនប៉ងក្នុងបទឧក្រិដ្ឋត្រូវបានកំណត់ថាមានទោស ទោះបីជាបទល្មើសនោះពុំទាន់អនុវត្តឱ្យឃើញជាក់ស្តែងឡើយ។[19] ចំពោះអំពើប៉ុនប៉ងជាបទមជ្ឈិមត្រូវបានចាត់ថាមានទោសដូចគ្នា ប៉ុន្តែការប៉ុនប៉ងនៅក្នុងបទលហុមិនត្រូវបានផ្តន្ទាទោសឡើយ។

### ២.៣. ការបែងចែកតាមប្រភេទផ្សេងៗទៀត

បទល្មើសដែលកើតឡើងទាំងអស់មិនមែនសុទ្ធតែមានទម្រង់ដូចគ្នានោះទេ។ យើងសង្កេតឃើញថានៅមានទម្រង់ផ្សេងនៃបទល្មើសដែលមាន ការបែងចែកទៅតាមទម្រង់នៃអំពើប្រព្រឹត្ត (**២.៣.១.**) ការបែងចែកដោយផ្អែកទៅតាមធាតុសត្យានុម័ត (**២.៣.២.**) និងការបែងចែកទៅតាមធាតុអត្តនោម័ត (**២.៣.៣.**)។

#### ២.៣.១. ការបែងចែកនៅតាមទម្រង់នៃអំពើប្រព្រឹត្ត

ក្នុងការប្រព្រឹត្តបទល្មើសដោយផ្អែកទៅតាមធាតុសត្យានុម័ត គេវាយតម្លៃថាបទល្មើសទាំងអស់នេះកើតឡើង គឺវាកំណត់បានដោយអាស្រ័យទៅតាមអាកប្បកិរិយាដែលបទប្បញ្ញត្តិនៃច្បាប់បានចែងទុកថាវាជាបទល្មើស តែផ្ទុយទៅវិញវាមិនអាស្រ័យទៅតាមការវាយតម្លៃទៅលើស្ថានភាពដែលបានកើតឡើងដោយជាក់ស្តែងនោះទេ។ ជាក់ស្តែងបទល្មើសព្រហ្មទណ្ឌដល់បានកំណត់យ៉ាងច្បាស់លាស់ដោយច្បាប់ យោងតាមអំពើប្រព្រឹត្តនៃទម្រង់ផ្សេងៗដែលជនល្មើសបានប្រព្រឹត្តមានដូចជា បទល្មើសភ្លាមៗ(**២.៣.១.១.**) បទល្មើសបន្តជាហូរហែរ (**២.៣.១.២.**) បទល្មើសអចិន្ត្រៃយ៍(**២.៣.១.៣.**) បទល្មើសប្រព្រឹត្តជាទម្លាប់(**២.៣.១.៤.**) បទល្មើសមិនស្មុគស្មាញ ឬហៅម្យ៉ាងទៀតថាបទល្មើសធម្មតា(**២.៣.១.៥.**) និងបទល្មើសស្មុគស្មាញ(**២.៣.១.៦.**)។

##### ២.៣.១.១. បទល្មើសភ្លាមៗ

បទល្មើសភ្លាមៗ ជាបទល្មើសដែលការប្រព្រឹត្តមិនអូសបន្លាយពេលយូរនោះទេគឺវាកើតឡើងភ្លាមៗហើយចប់សព្វគ្រប់ភ្លាមដែរ។ ឧទាហរណ៍ :

- បទឃាតកម្ម ជាបទល្មើសនេះសម្រេចភ្លាមៗនៅខណៈជនរងគ្រោះបានស្លាប់។
- បទដេញថ្លៃមិនត្រឹមត្រូវ ចាត់ទុកថាជាបទល្មើសភ្លាមៗព្រោះថាបទល្មើសនេះកើតឡើងពេលដែលជនណាម្នាក់យល់ព្រមទទួលអំណោយអ្វីជាថ្នូរទៅនឹងមិនចូលរួមដេញថ្លៃជាហេតុនាំឱ្យខូចខាតការដេញថ្លៃ។

[19] មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

- បទផ្តល់សក្ខីកម្មក្លែងក្លាយ ក៏ត្រូវបានចាត់ទុកថាជាបទល្មើសភ្លាមៗព្រោះបទល្មើសនេះសម្រេចផលពេលជននោះធ្វើការផ្តល់សក្ខីកម្មដោយកុហកក្រោយធ្វើការស្បថហើយ។[20]

### ២.៣.១.២. បទល្មើសបន្តជាហូរហែរ

បទល្មើសបន្តជាហូរហែរ គឺជាប្រភេទបទល្មើសដែលជនល្មើសបានបន្តប្រព្រឹត្តជាហូរហែរដោយមិនបញ្ចប់។ បទល្មើសនេះជាប្រភេទនៃបទល្មើសដែលអំពើជាសម្ភារៈប្រព្រឹត្តឡើងបន្តគ្នាជាហូរហែរ និងស៊ីសង្វាក់គ្នានៅពេលណាមួយដោយបានបង្ហាញពីចេតនាទុច្ចរិតដែលស្ថិតនៅជាដរាប។ ដើម្បីចាត់ទុកជាបទល្មើសបន្តជាហូរហែរគេត្រូវធ្វើការពិនិត្យលើសកម្មភាពនោះកើតឡើងដោយទាមទារឱ្យតាមរយៈពេលណាមួយ ឬកើតឡើងភ្លាមៗ។ សម្រាប់អាជ្ញាយុកាលនៃបទល្មើសបន្តហូរហែរ ត្រូវចាប់ផ្តើមគិតពីពេលដែលអំពើល្មើសបានបញ្ចប់ដោយមិនគិតពីពេលចាប់ផ្តើមនៃអំពើល្មើសនោះទេ។ ជាក់ស្តែងបទល្មើសទទួលផលចោរកម្មអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលទទួលផលចោរកម្មលែងបន្តកាន់កាប់ ឬរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃបទល្មើសតទៅទៀតដោយមិនមែនគិតពីពេលដែលអ្នកទទួលផលចោរកម្មទទួលវត្ថុដែលជាកម្មវត្ថុនៃបទល្មើសឡើយ។ ឧទាហរណ៍: ការរក្សាទុកផលចោរកម្ម ការបង្ខាំងមនុស្សដោយខុសច្បាប់ និងការកាន់កាប់ ឬរក្សាទុកអាវុធដោយខុសច្បាប់។

### ២.៣.១.៣. បទល្មើសអចិន្ត្រៃយ៍

បទល្មើសអចិន្ត្រៃយ៍ ជាប្រភេទបទល្មើសដែលជនល្មើសប្រព្រឹត្តចេញជារូបរាងរួចហើយតែលទ្ធផលនៃបទល្មើសនោះនៅតែបន្តហូតដោយមិនចាំបាច់ប្រព្រឹត្តជាថ្មីទៀត។ បទល្មើសប្រភេទនេះជាបទល្មើសដែលអាចបង្កគ្រោះថ្នាក់ដល់សង្គមស្តែងឡើងជាប់ជាហូរហែរគ្មានអាក់ខានឡើយក្នុងរយៈពេលណាមួយ។ ម្យ៉ាងវិញទៀតបទល្មើសអចិន្ត្រៃយ៍ សំដៅដល់បទល្មើសដែលបង្កើតឡើងដោយបណ្តាអំពើជាច្រើនប្រហាក់ប្រហែលគ្នាដោយអំពើនីមួយៗត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌដែរ ក៏ប៉ុន្តែដោយសារឯកភាពនៃសេចក្តីសម្រេចចិត្តគោលដៅនៃជនល្មើស និងភាពដូចគ្នានៃច្បាប់ដែលជនល្មើសបានបំពានអំពើច្រើនប្រហាក់ប្រហែលគ្នានោះគួរតែចាត់ទុកថាជាបទល្មើសតែមួយប៉ុណ្ណោះ។ ឧទាហរណ៍ : បទទ្វេពន្ធភាព ព្រោះអានុភាពនៃបទល្មើសនេះត្រូវបានអូសបន្លាយនៅក្នុងរយៈពេលណាមួយ ដោយបទល្មើសនេះបានបង្កើតលទ្ធផលសម្ភារៈខុសច្បាប់ដែលស្ថិតនៅជានិច្ច។

### ២.៣.១.៤. បទល្មើសប្រព្រឹត្តជាទម្លាប់

បទល្មើសប្រព្រឹត្តជាទម្លាប់ ជាបទល្មើសដែលកើតឡើងដោយសារអំពើជាច្រើនរួមផ្សំគ្នា ប៉ុន្តែអំពើនីមួយៗដាច់ដោយឡែកពីគ្នាមិនត្រូវបានចាត់ទុកថាជាបទល្មើសទេ តែផ្ទុយទៅវិញប្រសិនការប្រព្រឹត្តកើតមានម្តងហើយ

[20] មាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ : ចែងថារាល់ការផ្តល់ជាសក្ខីកម្មក្លែងក្លាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤លានរៀល ទៅ ១០លានរៀល។

ម្តងទៀតនោះនឹងមានបទល្មើសកើតមាន។ បទល្មើសនេះកើតបានដោយសារទម្លាប់ ពោលគឺអំពើជាទម្លាប់ដដែលៗយ៉ាងហោចណាស់ចំនួនពីរលើកទើបអាចកើតជាបទល្មើសបាន។ ឧទាហរណ៍ : ការគំរាមកំហែងថានឹងសម្លាប់នោះជនល្មើសអាចធ្វើសកម្មភាពឡើងម្តងហើយម្តងទៀតទៅលើជនរងគ្រោះ។

### ២.៣.១.៥. បទល្មើសមិនស្មុគស្មាញ

បទល្មើសមិនស្មុគស្មាញ ជាបទល្មើសដែលកើតចេញ និងបានសម្រេចឡើងដោយអំពើសត្យានុម័តតែមួយគត់ប៉ុណ្ណោះ។ យោងតាមសេចក្តីនេះ ករណីបទល្មើសលួចត្រូវបានចាត់ទុកថាបទល្មើសមិនស្មុគស្មាញ ព្រោះយើងឃើញថាបទល្មើសលួចបានសម្រេចឡើងដោយយោងតាមអំពើសត្យានុម័តតែមួយគត់នោះ គឺការដកហូតយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកជារបស់ខ្លួន។ បើយើងសង្កេតមើលពីរបបគតិយុត្តនៃតុលាការវិញនោះ បទល្មើសមិនស្មុគស្មាញមានតុលាការសមត្ថកិច្ចមានតែមួយគត់ ដោយសារអំពើសត្យានុម័តក៏មានតែមួយដែរ។ ចំពោះអាជ្ញាយុកាលនៃបទល្មើសត្រូវរាប់ចាប់ពីពេលនៃការប្រព្រឹត្តអំពើតែម្តង។ លើសពីនេះទៅទៀត បទល្មើសមិនស្មុគស្មាញមិនអនុវត្តតាមវិធានគោលការណ៍នីត្យានុកូលភាពនោះឡើយ។[21]

### ២.៣.១.៦. បទល្មើសស្មុគស្មាញ

បទល្មើសស្មុគស្មាញ ជាបទល្មើសដែលបានសម្រេចឡើងដោយមានអំពើសត្យានុម័តច្រើនផ្សំចូលគ្នាដែលអាស្រ័យទៅតាមខ្លឹមសារនៃច្បាប់ពាក់ព័ន្ធទៅនឹងបទល្មើសនីមួយៗ។ ជាធម្មតាបទល្មើសនេះជាបទល្មើសបន្តបន្ទាប់ និងកើតឡើងភ្លាមៗ។ អាជ្ញាយុកាលនៃបទល្មើសត្រូវបានរាប់ពីការសម្រេចចុងក្រោយដោយសារតែបទល្មើសនឹងសម្រេចទាំងស្រុង នៅពេលចុងក្រោយនៃអំពើកើតមានឡើងដោយពុំគិតពីអំពើសត្យានុម័តលើកទីមួយនៃបទល្មើសឡើយ។ ឧទាហរណ៍ : បទល្មើសឆបោកត្រូវបានគេចាត់ទុកថាជាបទល្មើសស្មុគស្មាញព្រោះបទល្មើសនេះកើតឡើងពីអំពើសត្យានុម័តចំនួនពីរគឺល្បិចកិច្ចកលរបស់ចារី និងការប្រគល់ជាមូលនិធិ តម្លៃ ទ្រព្យសម្បត្តិ ឬការផ្គត់ផ្គង់សេវា ឬការធ្វើលិខិតដែលមានតម្លៃជាកាតព្វកិច្ច ឬជាការឱ្យរួចពីកាតព្វកិច្ចជាដើមដែលអំពើទាំងនេះនាំឱ្យខូចប្រយោជន៍របស់ជនរងគ្រោះ។

ចំពោះសមត្ថកិច្ចតុលាការរបបគតិយុត្តវិញ យើងឃើញថាអាចមានច្រើនពេលណាដែលអំពើសត្យានុម័តនៃបទល្មើសបានកើតឡើងនៅកន្លែងខុសៗគ្នា។ ចំណែកឯច្បាប់ដែលយកមកអនុវត្តលើបទល្មើសស្មុគស្មាញជាច្បាប់ដែលបានចូលជាធរមាននៅខណៈពេលដែលអំពើចុងក្រោយនៃបទល្មើសបានប្រព្រឹត្ត ទោះបីជាច្បាប់ថ្មីនេះបានចូលជាធរមានក្រោយថ្ងៃដែលអំពើសត្យានុម័តទីមួយនៃបទល្មើសបានប្រព្រឹត្តក៏ដោយ។

[21] មាត្រា ៣ វាក្យខណ្ឌទី ១ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ កំណត់ចែងថា មានតែអំពើបង្កើតជាបទល្មើស នៅពេលដែលអំពើ នោះចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។

### ២.៣.២. ការបែងចែកផ្អែកលើធាតុសត្យានុម័ត

យោងទៅតាមអំពើជាសត្យានុម័តនៃបទល្មើសនីមួយៗ គេអាចបែងចែកបទល្មើសទៅតាមប្រភេទនៃអំពើជាបទល្មើសសកម្ម និងបទល្មើសអកម្ម (**២.៣.២.១.**) បទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែង (**២.៣.២.២.**) បទល្មើសសម្ភារៈ និងបទល្មើសរូបភាព (**២.៣.២.៣.**)។

#### ២.៣.២.១. បទល្មើសសកម្ម និងបទល្មើសអកម្ម

បទល្មើសសកម្ម ជាបទល្មើសដែលជនប្រព្រឹត្តបានធ្វើសកម្មភាពបំពានទៅលើទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌការពារ ឬ បទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តផ្ទុយពីច្បាប់ព្រហ្មទណ្ឌ។ ជាក់ស្តែង បទល្មើសនេះតែងតែកើតមានឡើងជាញឹកញាប់ដូចជា អំពើមនុស្សឃាត ចោរកម្ម បង្ករបួសស្នាម។ ក្នុងន័យនេះផងដែរ ព្យសនកម្មមិនមែនជាលក្ខខណ្ឌក្នុងការចាំបាច់សម្រាប់ការបង្កើតជាបទល្មើសមួយនោះទេ ដូចជាករណីមួយចំនួន ការជួញដូរគ្រឿងញៀន កាលបើបញ្ច្រាស់ផ្លូវឬហួសល្បឿនកំណត់ ព្រមទាំងករណីមួយចំនួនទៀត ព្យសនកម្មគឺជាលក្ខខណ្ឌចាំបាច់ព្រោះបើគ្មានព្យសនកម្មទេពុំមានបទល្មើសកើតឡើងឡើយដូចជា បទឃាតកម្ម បទរំលោភសេពសន្ថវៈ បទហិង្សាដោយចេតនា។

បទល្មើសអកម្ម ជាបទល្មើសមួយដែលកើតចេញពីការមិនបំពេញកាតព្វកិច្ចរបស់ជនណាម្នាក់ ឬច្រើននាក់ ទោះជាការមិនបំពេញនេះកើតចេញពីការភ្លេច ឬការបំភ្លេចក៏ដោយកំណត់តែថាជននោះមិនបានបំពេញតាមច្បាប់ទោះខ្លួនបានលទ្ធភាពឬសមត្ថភាពគ្រប់គ្រាន់ ឬបទល្មើសដែលជនណាម្នាក់មិនបានអនុវត្តកាតព្វកិច្ចដែលច្បាប់បានកំណត់។ ការមិនបំពេញកាតព្វកិច្ចតាមបញ្ញត្តិច្បាប់កើតចេញពីកត្តាជាច្រើនដូចជា ការបំភ្លេច ឬការរឹងទទឹងមិនបំពេញកាតព្វកិច្ច និងការភ្លេចសុទ្ធសាធ។ ការបំភ្លេច ឬការរឹងទទឹងមិនបំពេញកាតព្វកិច្ច សំដៅដល់ជនល្មើសបានដឹង និងចាំបានពីកាតព្វកិច្ចរបស់ខ្លួនថាត្រូវបំពេញទៅតាមច្បាប់ ប៉ុន្តែជននោះបែរជាមិនអើពើដោយបានបំភ្លេច ឬរឹងទទឹងមិនបំពេញកាតព្វកិច្ចតែម្តង។ បទល្មើសអកម្មទាំងនោះអាចជាបទមិនព្រមព្យាបាលរបួសអ្នកជម្ងឺរហូតដល់ហួរឈាមស្លាប់ ការមិនប្តឹងចុះកំណើតកូន ការមិនបង់អាហារកិច្ចចិញ្ចឹមកូន ការមិនជួយមនុស្សលង់ទឹក ឬមនុស្សកំពុងធ្វើអត្តឃាត ការមិនប្តឹងបើកមុខឧក្រិដ្ឋជន ការមិនប្តឹងចុះពាណិជ្ជកម្ម ការមិនព្រមជំនុំជម្រះពីសំណាក់ចៅក្រម និងការមិនព្រមផ្តល់សក្ខីភាពដល់តុលាការ។

#### ២.៣.២.២. បទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែង

ពិតប្រាកដណាស់ការប្រព្រឹត្តបទល្មើសខ្លះជាបទល្មើសជាក់ស្តែង និងខ្លះទៀតជាបទល្មើសមិនជាក់ស្តែងផងដែរ។ តើបទល្មើសទាំងពីរនេះមានអត្ថន័យដូចម្តេច?

ការចាត់ទុកថាបទល្មើសជាក់ស្តែង កាលបើបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងនោះគឺ : **បទល្មើសដែលកំពុងប្រព្រឹត្ត** ឬ **បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម**។ ចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

- ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភីង។
- បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។[22]

ដោយឡែកបទល្មើសមិនជាក់ស្តែង គឺជាបទល្មើសទាំងឡាយណាដែលជនល្មើសបានប្រព្រឹត្តចប់សព្វគ្រប់ហើយ ប៉ុន្តែការប្រព្រឹត្តនោះមិនត្រូវបានជនរងគ្រោះ ឬអាជ្ញាធរមានសមត្ថកិច្ចឃើញទាន់ដើម្បីធ្វើការចាប់ខ្លួនជនសង្ស័យនោះ ឬពុំមានជនរងគ្រោះ ឬសាក្សីណាម្នាក់ចង្អុលបង្ហាញនៅនឹងកន្លែងប្រព្រឹត្តបទល្មើសនោះ ឬយើងនិយាយថាបទល្មើសមិនជាក់ស្តែង គឺជាបទល្មើសដែលមិនមានកំណត់នៅក្នុងលក្ខខណ្ឌរបស់បទល្មើសជាក់ស្តែងនោះទេឡើយ។

**២.៣.២.៣. បទល្មើសសម្ភារៈ និងបទល្មើសរូបភាព**

បទល្មើសមួយ គឺជាបទល្មើសសម្ភារៈនៅពេលដែលច្បាប់តម្រូវឱ្យមានភស្តុតាងអំពីលទ្ធផលណាមួយជាកំណត់ ដើម្បីអាចឱ្យចាត់ទុកថាជាបទល្មើសបានសម្រេចផល។ ដូច្នេះលទ្ធផលនៃអំពើល្មើសជាធាតុផ្សំមួយនៃបទល្មើស ហើយបទល្មើសអាចបានសម្រេចផលនៅពេលដែលលទ្ធផលបានទទួល ឬនិយាយម្យ៉ាងទៀតថាជនរងគ្រោះទទួលរងនូវព្យសនកម្មពិតប្រាកដដែលចារីបានគ្រោងទុកជាមុន។ ឧទាហរណ៍ : បទឆបោកបានសម្រេចផល នៅពេលដែលជនរងគ្រោះបានប្រគល់ទ្រព្យសម្បត្តិណាមួយទៅឱ្យជនល្មើស។ ជាការចាំបាច់ណាស់ត្រូវតែរកឱ្យឃើញនូវចំណងហេតុផលរវាងអំពើ និងបច្ច័យហើយលទ្ធផលជាព្យសនកម្មត្រូវតែជាផលវិបាកនៃអំពើដែលបានប្រព្រឹត្តពោលគឺចំណងហេតុផលត្រូវតែមានលក្ខណៈច្បាស់លាស់។

ផ្ទុយពីបទល្មើសសម្ភារៈ បទល្មើសរូបភាព ក៏អាចត្រូវផ្តន្ទាទោសបានដែរដោយមិនអាស្រ័យទៅលើលទ្ធផលនៃបទល្មើសឡើយ ពោលគឺបទល្មើសបានសម្រេច ទោះបីជាលទ្ធផលដែលជនល្មើសប្រាថ្នាចង់បានបែរជាមិនបានទទួលក៏ដោយ។ ឧទាហរណ៍ : បទស៊ីសំណូក ជាបទល្មើសរូបភាពព្រោះថាគ្រាន់តែជនល្មើសធ្វើការទទូចសុំក៏បទល្មើសបានសម្រេចផលទៅហើយ ទោះបីជាមានការយល់ព្រមទៅនឹងការទទូចសុំ ឬក៏ពុំមានការយល់ព្រមទៅនឹងការទទូចសុំនេះក៏ដោយ។[23]

**២.៣.៣. ការបែងចែកផ្អែកលើធាតុអត្តនោម័ត**

ជាគោលការណ៍ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្តតែទោះបីជាយ៉ាងណាក្តីក្នុងករណីដែលច្បាប់ពុំមានចែងទុកជាមុនបទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយជាដើម។ យោងតាមការបែងចែកបទល្មើសដោយផ្អែកទៅតាមធាតុ

[22] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23] មាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

អគ្គនោម័តត្រូវបានចែកចេញជាពីរពោលគឺ បទល្មើសដោយចេតនា (**២.៣.៣.១.**) និងបទល្មើសដោយអចេតនា (**២.៣.៣.២.**)។

**២.៣.៣.១. បទល្មើសដោយចេតនា**

បទល្មើសដោយចេតនា ជាបទល្មើសទាំងឡាយណាដែលចារីមានបំណងក្នុងការប្រព្រឹត្ត និងអាចស្មានទុកជាមុនពីផលដែលនឹងកើតមានឡើងតាមរយៈសកម្មភាពដែលខ្លួនកំពុងតែនឹងធ្វើ។ បទល្មើសនេះ ដែលគេកំណត់បាន ដោយផ្តោតលើឆន្ទៈរបស់អ្នកប្រព្រឹត្តពិតជាមានបំណងបង្កជាផលវិបាកដល់សង្គមកើតមានឡើង។ យោងតាមសេចក្តីខាងលើ សបញ្ជាក់បានថាប្រសិនបើពុំមានភស្តុតាងបញ្ជាក់ពីចេតនាប្រព្រឹត្តរបស់ចារីទេ គឺពុំមានបទល្មើសណាមួយកើតឡើងឡើយ។ ឧទាហរណ៍ : ជនល្មើសធ្វើការគំរាមកំហែងលើជនរងគ្រោះដោយចេតនាទុច្ចរិត ព្រោះចង់បានទ្រព្យសម្បត្តិពីជនរងគ្រោះ។

**២.៣.៣.២. បទល្មើសដោយអចេតនា**

បទល្មើសដោយអចេតនា ជាប្រភេទនៃបទល្មើសទាំងឡាយណាដែលកើតមានឡើង ទោះបីជាចារីពុំមានបំណងក្នុងការប្រព្រឹត្ត។ បទល្មើសនេះជនល្មើសគ្មានចេតនាបង្កឱ្យមានជាព្យសនកម្មកើតមានឡើងទៅលើជនរងគ្រោះនោះទេ តែច្បាប់តម្រូវឱ្យជនល្មើសទទួលទោសដោយសារតែអំពើខ្ជីខ្ជា ធ្វេសប្រហែស ឬការមិនគោរពបទបញ្ជាជាដើម។[24] ភាពសុច្ចរិតរបស់ចារីពុំមានជាធាតុផ្សំនៃបទល្មើសទេបានសេចក្តីថា ទោះបីចារីពុំមានចេតនាទុច្ចរិតក៏បទល្មើសនៅតែកើតមានដដែល។ ឧទាហរណ៍ : បទល្មើសបង្ករបួសស្នាមដោយអចេតនាកំណត់ថាជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជាដែលបង្កឱ្យមានអសមត្ថភាពក្នុងការធ្វើការងារស្មើ ឬលើសពី៨ថ្ងៃ[25] ហើយការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។

## ២.៤. ការបែងចែងដាច់ពីគ្នារវាងបទល្មើសយោធា នយោបាយ និងគ្រឿងញៀន

ក្រៅពីបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ក៏មានបទល្មើសដែលចែងក្នុងបញ្ញត្តិពិសេសដែលដាច់ដោយឡែក។ បំណែងចែកនេះតម្រូវឱ្យមានការសិក្សាបន្ថែមព្រមទាំងស្វែងយល់បន្ថែមទៅលើបទល្មើសយោធា(**២.៤.១.**) បទល្មើសនយោបាយ(**២.៤.២.**) និងបទល្មើសគ្រឿងញៀន (**២.៤.៣.**)។

**២.៤.១. បទល្មើសយោធា**

បទល្មើសយោធា ជាបទល្មើសពិសេសដោយមានកំណត់និយមន័យដោយឡែក។ បទល្មើសយោធាជាបទល្មើសដែលប្រព្រឹត្តដោយយោធិននៅក្នុងជួរកងទ័ព ហើយមានពាក់ព័ន្ធនឹងវិន័យកងទ័ព ឬប៉ះពាល់ដល់ទ្រព្យ

[24] មាត្រា ៤ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[25] មាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

សម្បត្តិរបស់កម្លាំងប្រដាប់អាវុធ។[26] បទល្មើសនេះក៏មានកំណត់និយមន័យនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលរបស់កម្ពុជាដោយកំណត់បទល្មើសយោធាថាជាបទល្មើសដែលទាក់ទិនដល់ យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធាជាដើម។[27]

គួរបញ្ជាក់ផងដែរថា រាល់បទល្មើសទាំងឡាយណាដែលប្រព្រឹត្តដោយយោធិនពុំសុទ្ធសឹងតែចាត់ទុកជាបទល្មើសយោធាទេ មានន័យថាប្រសិនបើបទល្មើសសាមញ្ញមួយប្រព្រឹត្តដោយយោធិនមិនត្រូវចាត់ជាបទល្មើសយោធាឡើយ។[28]

បើប្រៀបធៀបទៅនឹងបទល្មើសសាមញ្ញលក្ខណៈពិសេសរបស់បទល្មើសយោធារួមមាន៖

- ប្រធានរបស់បទល្មើសជាយោធិន
- អំពើល្មើសគឺទាក់ទងទៅនឹងវិន័យកងទ័ព ឬទ្រព្យសម្បត្តិរបស់កងទ័ព។

### ២.៤.២. បទល្មើសនយោបាយ

បទល្មើសនយោបាយ ដោយយោងទៅតាមវចនានុក្រមអង់គ្លេសខ្មែរ បោះពុម្ពផ្សាយនៅឆ្នាំ១៩៩៧ ដោយអង្គការមូលនិធិអាស៊ីបានកំណត់នូវនិយមន័យថាជាអំពើមួយដែលធ្វើឡើងក្នុងគោលបំណងនយោបាយ ឬមកពីមូលហេតុនយោបាយ។ ទោះបីជាសញ្ញាណនៃពាក្យបទល្មើសនយោបាយ ត្រូវបានច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយកមកប្រើប្រាស់ច្រើនផងនោះ ប៉ុន្តែក្នុងច្បាប់ទាំងអស់ដែលមានបញ្ញត្តិនោះពុំបានកំណត់ច្បាស់លាស់ឡើយស្ដីពីនិយមន័យរបស់បទល្មើសនយោបាយឡើយ។ ពោលគឺគ្រាន់តែកំណត់ជាឧទាហរណ៍ថា អំពើល្មើសណាដែលមិនចាត់ទុកជាបទល្មើសនយោបាយ។[29] ជាក់ស្ដែងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀនមិនបានចាត់ទុកជាបទល្មើសនយោបាយ ឬក៏ជាបទល្មើសដែលមានមូលហេតុនយោបាយឡើយ ចំណែកក្រមនីតិវិធីព្រហ្មទណ្ឌក៏មិនបានចាត់ទុកជាបទល្មើសនយោបាយដែរ ចំពោះអំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិតដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពរបស់បុគ្គល។ បើពិនិត្យទៅលើសន្ធិសញ្ញា និងកិច្ចព្រមព្រៀងស្ដីពីបត្យាប័នរវាងព្រះរាជណាចក្រកម្ពុជាជាមួយបណ្ដាប្រទេសមួយចំនួនរួមមាន៖ ប្រទេសចិន[30] ប្រទេសថៃ[31]

[26] មាត្រា ៩ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្ដីនៃរដ្ឋកម្ពុជាចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣

[27] មាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលកម្ពុជា ឆ្នាំ១៩៩២

[28] មាត្រា ១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលកម្ពុជា ឆ្នាំ១៩៩២

[29] មាត្រា ១០១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២ និងមាត្រា ៥៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[30] សន្ធិសញ្ញាស្ដីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិនប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧០០/០៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០

[31] សន្ធិសញ្ញាស្ដីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៧៩៩/០៨ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

ប្រទេសឡាវ[32] និងប្រទេសកូរ៉េ[33] មិនបានកំណត់ពីនិយមន័យនៃបទល្មើសនយោបាយដូចគ្នាដោយគ្រាន់កំណត់ពីបទល្មើសណាមិនមែនជាបទល្មើសនយោបាយ ចំពោះការធ្វើឃាត ឬការបំពានលើរូបរាងកាយរបស់ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ឬសមាជិកគ្រួសារនៃវីរជនទាំងនោះ។ សរុបជារួមបទល្មើសនយោបាយ ជាសញ្ញាណមួយដែលមានលក្ខណៈមិនសូវច្បាស់លាស់ ហើយយុត្តិសាស្ត្ររបស់តុលាការកម្ពុជានឹងធ្វើការកំណត់អំពើលក្ខណៈវិនិច្ឆ័យនៃបទល្មើសនយោបាយទៅតាមករណីនីមួយៗនៅពេលក្រោយៗ។

### ២.៤.៣. បទល្មើសគ្រឿងញៀន

បទល្មើសគ្រឿងញៀន ផ្តល់បានជាន័យទូលំទូលាយដែលគ្របដណ្តប់គ្រប់បទល្មើសទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងការចាត់ចែងសារធាតុញៀនណាដែលច្បាប់បានហាមឃាត់។ ចំណាត់ថ្នាក់គ្រឿងញៀនចែកចេញជា៤តារាង[34]៖

- **តារាង១** ៖ រុក្ខជាតិ និងសារធាតុបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ។
- **តារាង២** ៖ រុក្ខជាតិ និងសារធាតុបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយមានផលប្រយោជន៍ខាងវេជ្ជសាស្ត្ររួមមាន កូការអ៊ីន អាភៀន ទឹកកំហាប់ដើមអាភៀន ម័រហ្វីន មេតំហ្វេតាមីន។
- **តារាង៣** ៖ រុក្ខជាតិ និងសារធាតុបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្ររួមមាន៖ កេតាមីន ហ្វង់ទែរមីន ឡេហ្វេតាមីន។
- **តារាង៤** ៖ សារធាតុផ្សំទាំងឡាយ ចាត់ក្នុងថ្នាក់អនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់។

សកម្មភាពខ្លះៗដែលចាត់ទុកថាជាបទល្មើសគ្រឿងញៀន៖

- **បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ៖ ត្រូវបានកំណត់និយមន័យដូចដែលមានចែង ការរក្សាទុកសំដៅដល់ការកាន់កាប់ ការលាក់ទុក សន្និធិ ការស្តុកទុក និងសកម្មភាពដែលមានលក្ខណៈប្រហាក់ប្រហែល។ ការដឹកជញ្ជូន ជាការបញ្ជូនតាមគ្រប់រូប

---

[32] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ នៃព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៦ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៥

[33] សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ នៃព្រះរាជក្រមលេខ នស/រកម/០១១១/០០១ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១

[34] មាត្រា ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

ភាពដែលនាំឱ្យមានការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយតាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ។ ការជួញដូរជាការផ្តល់ស្រាប់លក់ ការទិញដើម្បីលក់ ឬដោះដូរ។[35]

- **បទសម្រួលឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ៖ អំពើនៃការជួលទីកន្លែងផ្តល់ទីកន្លែង ឬអំពើផ្សេងដែលបង្កលក្ខណៈងាយស្រួលដល់ការប្រើប្រាស់ ដោយខុសច្បាប់នូវសារធាតុញៀនត្រូវបានចាត់ទុកជាការសម្រួលឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពី១ឆ្នាំ ដល់១០ឆ្នាំ និងទទួលរងទោសបន្ថែមលើការពិន័យជាប្រាក់ពី២លានរៀល ទៅ១០លានរៀល។[36]
- **បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ៖ ចំពោះជនទាំងឡាយណាដែលបានប្រើប្រាស់សារធាតុញៀនដោយខុសច្បាប់តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ៦ខែ និងអាចត្រូវពិន័យជាប្រាក់ពី១សែនរៀល ទៅ១លានរៀល។[37] លើសពីនេះទៅទៀតករណីដែលអ្នកប្រព្រឹត្តមិនរាងចាលនៅអំពើរបស់ខ្លួននោះទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ខែ ទៅ១ឆ្នាំ និងអាចត្រូវពិន័យជាប្រាក់ពី១លានរៀល ទៅ២លានរៀល។

ម្យ៉ាងវិញទៀត ចំពោះបទល្មើសខាងលើនេះព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរត្រូវចាត់គ្រូពេទ្យឱ្យមកពិនិត្យជនឃាត់ខ្លួន២៤ម៉ោងម្តង។ ចំណែកឯបទល្មើសាមញ្ញវិញ នីតិវិធីបែបនេះពុំឃើញមានចែងឡើយ។

## ២.៥. ការបែងចែកបទល្មើសទាក់ទងនឹងសមត្ថកិច្ច

សមត្ថកិច្ចក៏ត្រូវធ្វើការបែងចែកផងដែរ ដោយមានការបែងចែកសមត្ថកិច្ចជាបីយ៉ាង៖

- សមត្ថកិច្ចតាមបទល្មើស គឺសមត្ថកិច្ចមួយដែលគេកំណត់តាមប្រភេទបទល្មើស។
- សមត្ថកិច្ចតាមជនល្មើស គឺជាសមត្ថកិច្ចដែលគេជំនុំជម្រះតាមប្រភេទអ្នកប្រព្រឹត្តបទល្មើស។
- សមត្ថកិច្ចតាមដែនដី គឺត្រូវបានបែងចែកជាបីផ្នែកទៀតនោះគឺ៖
  - ទីកន្លែងជាក់លាក់ដែលជនល្មើសបានប្រព្រឹត្តបទល្មើស គឺសមត្ថកិច្ចតុលាការនៅទីនោះ។
  - ទីកន្លែងដែលជាទីស្នាក់នៅបណ្តោះអាសន្ន មានន័យថាជនល្មើសពួននៅទីណាសមត្ថកិច្ចរបស់តុលាការនៅទីកន្លែងនោះ។
  - ទីកន្លែងដែលនគរបាលយុត្តិធម៌ចាប់ជនល្មើសបាន មានន័យថានៅពេលគេដេញតាមចាប់ជនល្មើសបាននៅកន្លែងណាគេកំណត់យកសមត្ថកិច្ចតុលាការនៅកន្លែងតែម្តង។

---

[35] មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

[36] មាត្រា ៤៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

[37] មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២

# ជំពូកទី៣

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

# ជំពូកទី៣

# ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ

ដើម្បីកំណត់ជាបទល្មើសព្រហ្មទណ្ឌបានត្រូវមានធាតុផ្សំទាំងបីនេះរួមបញ្ចូលគ្នា គឺធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ មានមតិខ្លះបានលើកឡើងថាធាតុផ្សំនៃបទល្មើសមានតែពីរប៉ុណ្ណោះពោលគឺ ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ចំណែកឯធាតុនីត្យានុកូល គឺស្ថិតនៅក្រៅបទល្មើស។ ច្បាប់ពុំមែនជាធាតុផ្សំនៃបទល្មើសទេមានតែអង្គហេតុ និងចេតនារបស់ចារីទៅវិញទេដែលរួមផ្សំបង្កើតជាបទល្មើស។ ទោះជាយ៉ាងណាក្តីយើងនៅតែកំណត់ថាបទល្មើសមានធាតុផ្សំបីរួមផ្សំគ្នា គឺធាតុនីត្យានុកូល ឬធាតុច្បាប់(**៣.១.**) ធាតុសត្យានុម័ត ឬធាតុសម្ភារៈ(**៣.២.**) និងធាតុអត្តនោម័ត ឬធាតុចិត្តសាស្ត្រ(**៣.៣.**)។

## ៣.១. ធាតុនីត្យានុកូល (ធាតុច្បាប់)

តាមគោលការណ៍គ្រប់បទល្មើសទាំងអស់ គឺចាំបាច់ត្រូវតែមានប្រភពចេញមកពីច្បាប់ដែលបង្កើតឡើងដោយស្ថាប័ននីតិបញ្ញត្តិ ប៉ុន្តែបទលហុពេលខ្លះយើងអាចឃើញមានប្រភពចេញមកពីអំណាចនីតិប្រតិបត្តិ ឬមកពីអាជ្ញាធរសាធារណៈផងដែរ។ ពាក់ព័ន្ធនឹងធាតុនីត្យានុកូលនេះយើងនឹងសិក្សាលំអិតអំពីគោលការណ៍នីត្យានុកូលភាព(**៣.១.១.**) ការបកស្រាយត្រឹមត្រូវតាមច្បាប់ព្រហ្មទណ្ឌ(**៣.១.២**) និងដែននៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ(**៣.១.៣.**)។

### ៣.១.១. គោលការណ៍នីត្យានុកូលភាព

ច្បាប់ គឺជាកត្តាចាំបាច់បំផុតនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ មូលដ្ឋាននៃគោលការណ៍នីត្យានុកូលភាពដែលត្រូវបានបង្កើតឡើង ដើម្បីការពារសិទ្ធិសេរីភាពរបស់បុគ្គលក្នុងការប្រព្រឹត្តអំពើផ្សេងៗ។ អំពើមួយដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។[38] មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះទើបអាចត្រូវប្រកាសបាន។

ក្រៅពីនេះ គោលការណ៍នីត្យានុកូលភាពក៏ត្រូវបានទទួលស្គាល់ដោយលិខិតុបករណ៍អន្តរជាតិដែលមានតម្លៃជារដ្ឋធម្មនុញ្ញផងដែរ។[39] មួយវិញទៀតគ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌមាននៅក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅខណៈពេលដែលអំពើនោះបានប្រព្រឹត្ត។[40] យោងតាមគោលការណ៍ខាងលើ ដើម្បីអាចឱ្យគេចាត់ទុកថាអំពើ

[38] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[39] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[40] មាត្រា ១៥ កថាខណ្ឌទី១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦

ណាមួយជាបទល្មើសហើយត្រូវផ្តន្ទាទោសបាន លុះត្រាតែមានអត្ថបទច្បាប់បានចែងថាអំពើនោះជាបទល្មើសហើយត្រូវទទួលទណ្ឌកម្មដែលច្បាប់កំណត់។ ដូច្នេះរាល់ការចោទប្រកាន់ និងការដាក់ទោសទាំងអស់ត្រូវតែផ្អែកទៅលើច្បាប់(គ្មានច្បាប់ចែង គ្មានបទល្មើស គ្មានទោស)។

ច្បាប់ដែលលើកឡើងខាងលើនេះជាច្បាប់ក្នុងន័យទូលាយ។ ច្បាប់ក្នុងន័យទូលាយគឺជាច្បាប់ដែលតាក់តែងឡើងដោយអាជ្ញាធរសាធារណៈ ឬរាល់ស្ថាប័នមានអំណាចច្បាប់។ ទស្សនទាននេះខុសប្លែកពីទស្សនទាននៃច្បាប់ក្នុងន័យចង្អៀតដែលសំដៅតែទៅលើច្បាប់អនុម័តដោយសភាទាំងពីរថ្នាក់ និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រតែប៉ុណ្ណោះ។ ទន្ទឹមនឹងនេះក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឱ្យអង្គការនីតិប្រតិបត្តិអាចចេញបាននូវលិខិតបទដ្ឋានគតិយុត្តដែលចែងពីបទលហុ ក្នុងលក្ខខណ្ឌដែលបទលហុនោះត្រូវផ្តន្ទាទោសត្រឹមការពិន័យជាប្រាក់ប៉ុណ្ណោះ។ ការអនុវត្តនូវគោលការណ៍នីត្យានុកូលឱ្យបានល្អត្រូវដាច់ខាតឱ្យបទល្មើសត្រូវតែមានយ៉ាងច្បាស់លាស់នៅក្នុងច្បាប់។ ការកំណត់បទល្មើសក្នុងលក្ខណៈទូលំទូលាយខ្លាំងពេកមិនអាចធានាបាននូវការគោរពសិទ្ធិសេរីភាពរបស់បុគ្គលឡើយ ព្រោះថាយ៉ាងដូច្នេះអាចឱ្យគេចោទប្រកាន់យ៉ាងងាយស្រួលលើជនទាំងឡាយណាដែលគេពុំសូវពេញចិត្ត។ ជាក់ស្តែងការកំណត់បទល្មើសក្នុងលក្ខណៈពេកគឺក្រមព្រហ្មទណ្ឌសូវៀតឆ្នាំ១៩២៦ ដែលបានបញ្ញត្តិថាវិធានការគំហាត់សង្គមត្រូវអនុវត្តចំពោះជនទាំងឡាយណាដែលបង្ហាញនូវភាពគ្រោះថ្នាក់ដោយសារតែជននោះភ្ជាប់ខ្លួននឹងបរិស្ថានដែលមានគ្រោះថ្នាក់ ឬដោយសារតែអតីតភាពរបស់ជននោះ។

### ៣.១.១.១. នីត្យានុកូលភាពនៃបទល្មើស

នីត្យានុកូលភាពនៃបទល្មើស គឺអាចធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសជនណាម្នាក់បានកាលបើអំពើរបស់ជននោះមានចែងក្នុងមាត្រាណាមួយនៃច្បាប់ព្រហ្មទណ្ឌដែលកំពុងចូលជាធរមាន។ ទោះបីជាការប្រព្រឹត្តអំពើណាមួយមានគ្រោះថ្នាក់ធំប៉ុណ្ណាក៏ដោយដល់សង្គម ប៉ុន្តែបើគ្មានច្បាប់ចែងថាជាបទល្មើសទេនោះអាជ្ញាធរមានសមត្ថកិច្ច (អាជ្ញាធរសាធារណៈ ឬ ចៅក្រម) មិនអាចធ្វើការចោទប្រកាន់ ឬផ្តន្ទាទោសជនដែលប្រព្រឹត្តនោះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតឱ្យខ្លី គឺ **គ្មានបទល្មើស បើគ្មានច្បាប់ចែង**។ ឧទាហរណ៍ លោក **ក** បានឃើញមនុស្សកំពុងលង់ទឹកនៅចំពោះមុខ តែគាត់មិនបានជួយមនុស្សម្នាក់នោះទេដោយគាត់អង្គុយមើលរហូតដល់អ្នកលង់ទឹកនោះស្លាប់។ ក្នុងករណីរបស់លោក **ក** មិនអាចចោទប្រកាន់ ឬផ្តន្ទាទោសបានទេព្រោះថាច្បាប់ព្រហ្មទណ្ឌមិនទាន់បានចាត់ទុកជាបទល្មើសនៅឡើយ។ ចំពោះអ្នកអនុវត្តច្បាប់ ឬអ្នកសិក្សាច្បាប់មានការលំបាកក្នុងការស្រាវជ្រាវនូវបទល្មើសនេះ ក៏ព្រោះតែក្រមព្រហ្មទណ្ឌមិនទាន់មានការចងក្រងគ្រប់បទល្មើសទាំងអស់នោះទេ ផ្ទុយទៅវិញយើងឃើញមានបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀតជាច្រើនត្រូវបានចងក្រងនៅក្នុងច្បាប់ដោយឡែកផ្សេងទៀត។

### ៣.១.១.២. នីត្យានុកូលភាពនៃទោស

នីត្យានុកូលភាពនៃទោស មានន័យថាអំពើណាមួយដែលគេចាត់ទុកថាជាបទល្មើស លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូច្នោះទេគេមិនអាចអនុវត្តទោសទៅលើបុគ្គលនោះបានឡើយ។ ហេតុនេះហើយបានជាគេឃើញមានគោលការណ៍មួយទៀតចែងថា គ្មានទោសដែលច្បាប់មិនបានចែងឡើយ។ គោលការណ៍នេះធានាមិនឱ្យមានការចោទប្រកាន់ ឬដាក់ទោសទៅលើអំពើដែលច្បាប់មិនបានចែង ក៏ប៉ុន្តែគោលការណ៍នេះបានផ្តល់ឱកាសឱ្យជនខិលខូចមួយចំនួន ក្នុងការប្រព្រឹត្តអំពើប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយពួកគេដឹងថាមិនមានច្បាប់ណាអាចដាក់ទោសគេបាន។ នៅរមណីយដ្ឋានមានបញ្ហាមួយចំនួនដែលកើតមាននៅប្រទេសកម្ពុជា មានការបន្លំផ្នែកជញ្ជីង ឬការជម្រិតទារថ្លៃអាហារថ្លៃហួសហេតុពីថ្លៃធម្មតាដោយមិនប្រាប់តម្លៃមុន ហើយក៏នៅមានអំពើប៉ះពាល់ដល់សង្គមជាច្រើនទៀតដែលជនប្រព្រឹត្តមិនត្រូវបានទទួលទណ្ឌកម្មដោយសារអំពើទាំងនោះមិនចាត់ទុកជាបទល្មើសនៅក្នុងច្បាប់។ ដូច្នោះហើយ ដើម្បីទប់ស្កាត់ រារាំង និងបង្ក្រាប់នូវអំពើទាំងនោះ លុះត្រាតែរដ្ឋសភាធ្វើការអនុម័តច្បាប់ ដើម្បីផ្តន្ទាទោសនូវគ្រប់អំពើដែលគិតថានាំឱ្យប៉ះពាល់ ខូចខាតសណ្តាប់ធ្នាប់ ឬគ្រោះថ្នាក់ដល់សង្គមនោះ។

### ៣.១.២. ការបកស្រាយត្រឹមត្រូវតាមច្បាប់ព្រហ្មទណ្ឌ

គោលការណ៍នេះមាន គោលបំណងឱ្យអ្នកអនុវត្តច្បាប់ជាពិសេសចៅក្រមត្រូវអនុវត្តឱ្យបានត្រឹមត្រូវបំផុតទៅតាមស្មារតីរបស់ច្បាប់ ឬទៅតាមឆន្ទៈរបស់អ្នកធ្វើច្បាប់ពោលគឺនៅក្នុងការផ្តន្ទាទោសទៅលើជនណាមួយចៅក្រមត្រូវផ្អែកលើច្បាប់ ដែលបានចូលជាធរមានដែលមានបញ្ជាក់អត្ថន័យច្បាស់លាស់ ពោលគឺចៅក្រមមិនត្រូវផ្តន្ទាទោសទៅតាមការនឹកឃើញ ឬការបកស្រាយដោយមិនសមហេតុផលខុសពីគោលគំនិតពិតប្រាកដរបស់ច្បាប់ឡើយ។ ឧទាហរណ៍ : ដូចជាអំពើចោរកម្មក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលបានបញ្ញត្តិថាគ្រប់ជនដែលលួច ឬប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវផ្តន្ទាទោសពីបទចោរកម្ម ប៉ុន្តែមាត្រាដែលកំណត់ពីបទលួចពុំបានកំណត់ថាចរន្តអគ្គីសនី គឺជាទ្រព្យសម្បត្តិនោះទេ។ ដូច្នេះបើជនណាម្នាក់លួចតចរន្តអគ្គីសនីដោយមិនបង់ថ្លៃក៏ដោយក៏ចៅក្រម មិនអាចបកស្រាយថាជននោះបានលួចទ្រព្យសម្បត្តិហើយធ្វើការផ្តន្ទាទោសដោយផ្អែកលើច្បាប់ព្រហ្មទណ្ឌអន្តរកាលនេះឡើយ។ ក្នុងករណីដែលមានជនដែលទទួលបានការខូចខាតអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជួសជុលការខូចខាតទៅតុលាការរដ្ឋប្បវេណីវិញ។

ទោះបីជាច្បាប់បានចែងជាលាយលក្ខណ៍អក្សរ ដែលអ្នកធ្វើច្បាប់យល់ថាមានលក្ខណៈច្បាស់លាស់ហើយក៏ដោយក៏ច្បាប់ទាំងនោះមិនប្រាកដថាមានសុក្រិតភាពគ្រប់គ្រាន់នោះដែរ មានន័យថាពេលខ្លះច្បាប់មានលក្ខណៈទូលំទូលាយពេក ឬក៏ពាក្យណាមួយមានភាពមិនច្បាស់លាស់ ឬជួនកាលចន្លោះប្រហោង ដោយសារមូលហេតុនោះហើយបានជាតម្រូវឱ្យមានការបកស្រាយជាចាំបាច់។ នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថា

ការបកស្រាយច្បាប់មិនទាន់មានភាពរលូនដូចគ្នាជាទូទៅក្នុងចំណោមចៅក្រមទាំងអស់នោះទេ មានន័យថា អត្ថបទ ឬមាត្រាមួយចំនួនត្រូវបានចៅក្រមបកស្រាយខុសៗគ្នា។ បើទោះបីជាចៅក្រមមានការបកស្រាយខុសគ្នាយ៉ាងណាក៏ដោយ ក៏ត្រូវគោរពនូវគោលការណ៍នៃការបកស្រាយឱ្យបានត្រឹមត្រូវបំផុតតាមស្មារតីនៃច្បាប់។

### ៣.១.៣. ដែននៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌ គឺជាការសម្តែងប្រតិកម្មរបស់សង្គមដែលមានប្រតិកម្មឆ្លើយតបទៅនឹងអំពើរបស់ជនល្មើស។ ហេតុដូចនេះ ដែននៃការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវបានចែកជា : វិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌតាមពេលវេលា(**៣.១.៣.១.**) និងវិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ(**៣.១.៣.២.**)។

#### ៣.១.៣.១. វិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌតាមពេលវេលា

**ក. ការអនុវត្តច្បាប់ដែលបានលុបចោលបទល្មើស**

ចំពោះការនិរាករណ៍របស់ច្បាប់ កាលបើច្បាប់ថ្មីកើតឡើងហើយច្បាប់ថ្មីនេះមានបញ្ញត្តិមួយចំនួនដូចនឹងច្បាប់ចាស់ ឬទាំងស្រុងផ្ទុយពីច្បាប់ចាស់នាំឱ្យច្បាប់ចាស់ត្រូវឈប់ប្រើ ឬលុបចោល[41] ដែលការនិរាករណ៍មានពីរបែបគឺៈ

- **និរាករណ៍ដោយជាក់ច្បាស់** ៖ មានន័យថាបទប្បញ្ញត្តិនៃច្បាប់ថ្មីបានចង្អុលបង្ហាញច្បាស់លាស់ទៅលើបទបញ្ញត្តិ ឬច្បាប់ចាស់ណាមួយថាត្រូវកែប្រែ ឬត្រូវលុបចោល។
- **និរាករណ៍ដោយតុណ្ហីភាព** ៖ មានន័យថាច្បាប់ចាស់ត្រូវបានឈប់ប្រើទៀតហើយទោះបីជាច្បាប់ថ្មីមិនបានចង្អុលច្បាស់ថាមាត្រា ឬច្បាប់ចាស់ណាមួយត្រូវទុកជានិរាករណ៍ក៏ដោយ។ ការនិរាករណ៍ដោយសារថាមាត្រាណាមួយ ឬទាំងអស់នៃច្បាប់ចាស់មានលក្ខណៈ ឬស្មារតីផ្ទុយគ្នាពីច្បាប់ថ្មី។

**ខ. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង**

តាមគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង ករណីដែលច្បាប់ថ្មីគ្មានអានុភាពអនុវត្តថយក្រោយនោះទេ មានន័យថាបទល្មើសនោះត្រូវតែផ្តន្ទាទោសទៅតាមកម្រិតទណ្ឌកម្មនៅក្នុងច្បាប់ចាស់។ ច្បាប់ថ្មីអាចអនុវត្តបានតែចំពោះអំពើដែលបានប្រព្រឹត្តចាប់ពីថ្ងៃដែលច្បាប់ថ្មីចូលជាធរមានតែប៉ុណ្ណោះ។ ចំណែកឯអំពើដែលបានប្រព្រឹត្តមុនពេលនេះរួមទាំងអំពើដែលពុំទាន់បានជំនុំជម្រះជាស្ថាពរនៅឡើយ ច្បាប់ថ្មីគ្មានអានុភាពអនុវត្តទេ។ និយាយម្យ៉ាងទៀត មិនត្រូវឱ្យមានការដាក់ទោសធ្ងន់ជាងទោសដែលបានកំណត់នៅខណៈពេលដែលបទល្មើសព្រហ្មទណ្ឌបានប្រព្រឹត្តនោះឡើយ។ ពេលណាដែលការចូលជាធរមានរបស់ច្បាប់ថ្មីបានកំណត់ពីការផ្តន្ទាទោសទៅលើបទល្មើសដែលដូចគ្នាទៅនឹងច្បាប់ចាស់ ប៉ុន្តែបានផ្តន្ទាទោសធ្ងន់ជាងច្បាប់ចាស់នោះ តុលាការត្រូវផ្តន្ទាទោសតាមច្បាប់ចាស់ដោយសារច្បាប់ចាស់មានទណ្ឌកម្មស្រាលជាង។

---

[41] មាត្រា ៩ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### គ. គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាង

ការប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាងមានអានុភាពអនុវត្ត ចំពោះអំពើទាំងឡាយណាដែលបានកើតឡើងមុនពេលដែលច្បាប់ថ្មីចូលជាធរមានហើយពុំទាន់ត្រូវបានវិនិច្ឆ័យជាស្ថាពរឡើយ។ ប្រសិនបើមានសាលក្រម ឬសាលដីកាស្ថាពរ ហើយគេពុំអាចសើរើកែប្រែបានឡើយលើកលែងតែទណ្ឌិតត្រូវបានដាក់ទោសដោយហេតុផលថាបានប្រព្រឹត្តអំពើណាមួយដែលច្បាប់ថ្មីពុំបានចាត់ទុកថាជាបទល្មើស។ ម្យ៉ាងទៀតការចាត់ទុកជាច្បាប់ថ្មីណាមួយដែលស្រាលជាងត្រូវតែផ្អែកលើលក្ខណៈវិនិច្ឆ័យដូចបានរៀបរាប់ខាងលើ ពីករណីច្បាប់ថ្មីធ្ងន់ជាង។ បញ្ហាមួយអាចនឹងចោទឡើងនៅពេលដែលច្បាប់ថ្មីមានបទបញ្ញត្តិខ្លះធ្ងន់ជាង ហើយខ្លះទៀតស្រាលជាង ក៏ប៉ុន្តែបទបញ្ញត្តិទាំងនោះអាចកាត់ផ្តាច់ចេញពីគ្នាបាន។ ករណីដែលចាត់ទុកថាច្បាប់ថ្មីស្រាលជាងច្បាប់ចាស់មានជាអាទិ៍ដូចជា៖

- ការលុបចោលនូវបទល្មើសដែលមានចែងនៅក្នុងច្បាប់ចាស់
- ការលុបចោលនូវទោសប្រហារជីវិត
- ការបន្ថយកម្រិតទណ្ឌកម្ម
- ការបន្ថយអាជ្ញាយុកាល
- ការយកទណ្ឌកម្មពិន័យមកជំនួសទណ្ឌកម្មដាក់ពន្ធនាគារ ជាដើម។

ឧទាហរណ៍ ៈ ក្នុងករណីដែលច្បាប់ព្រហ្មទណ្ឌរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានចែងទៅលើទោសដែលធ្ងន់ជាងគេ គឺទោសប្រហារជីវិត ប៉ុន្តែក្រោយមកច្បាប់ព្រហ្មទណ្ឌអន្តរកាលបានលុបចោលនូវទោសប្រហារជីវិតនៅប្រទេសកម្ពុជា។ ដូច្នេះបើមានបទល្មើសណាមួយដែលបានប្រព្រឹត្ត ហើយត្រូវបានតុលាការមិនទាន់អនុវត្តទោសនោះរហូតដល់ច្បាប់ថ្មីចូលជាធរមាន នោះត្រូវយកច្បាប់ថ្មីមកអនុវត្តភ្លាមហើយមានអានុភាពប្រតិសកម្មទៅលើបទល្មើសប្រហារជីវិតនៅក្នុងច្បាប់ចាស់ ពោលគឺជនល្មើសមិនត្រូវបានអនុវត្តទោសប្រហារជីវិតនៅក្នុងច្បាប់ចាស់ទេ។

### ៣.១.៣.២. វិសាលភាពនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ

ប្រទេសនីមួយៗ តែងតែមានកំណត់យ៉ាងច្បាស់លាស់ពីដែនសមត្ថកិច្ចនៃបទល្មើសដោយកំណត់តាមការអនុវត្តកំណត់តាមសមត្ថកិច្ចនៃបទល្មើសណាមួយដែលបានប្រព្រឹត្ត។ នៅក្នុងប្រទេសកម្ពុជាក៏មានចែងពីការកំណត់បទល្មើសណាខ្លះដែលទាក់ទងទៅនឹងសមត្ថកិច្ចនេះផងដែរ។ ផ្អែកទៅតាមក្រមព្រហ្មទណ្ឌកម្ពុជា ចំពោះការកំណត់បទល្មើសទាក់ទងទៅនឹងសមត្ថកិច្ចនេះត្រូវបានកំណត់ចែងចេញជាពីរ ដោយកំណត់តាមដែនដីនៃអំពើដែលបានប្រព្រឹត្តបទល្មើសមានដូចជា បទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងបទល្មើសដែលលបានប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

### ក. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

បទល្មើសទាំងឡាយណា ដែលគេចាត់ទុកថាជាបទល្មើសដែលបានប្រព្រឹត្តក្នុងសមត្ថកិច្ចដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺសំដៅទៅដល់អំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[42] ចំពោះពាក្យថា "ដែនដី" ត្រូវបានកំណត់ជាក់លាក់ថាជាដែនទាំងឡាយណាដែលរួមមានលំហរអាកាស និងសមុទ្រដែលមានចំណងភ្ជាប់ជាមួយនឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។[43] បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា[44]ដែលមានសញ្ជាតិខ្មែរ ជាហេតុដែលនាំឱ្យអំពើល្មើសណាដែលកើតមានឡើងនៅលើនាវារបស់កម្ពុជានោះច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានអានុភាពក្នុងការអនុវត្តទៅលើបទល្មើសដែលបានកើតមានឡើងនោះ ដោយមិនប្រកាន់ពីសញ្ជាតិនៃអ្នកប្រព្រឹត្តបទល្មើស ឬទីតាំងនៃនាវាស្ថិតនៅទីណា។ ផ្ទុយពីនេះចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើនាវាបរទេស[45] ដែនសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងមានអានុភាពក្នុងការអនុវត្តបាន លុះត្រាតែអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតក្នុងការឱ្យពិនិត្យ ឬចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ។ ករណីផ្សេងពីនេះដែលយើងអាចពិចារណាបានមានបទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា[46]ស្របតាមក្រមព្រហ្មទណ្ឌកម្ពុជា ទោះបីជាអាកាសយានមានទីតាំងស្ថិតនៅទីណាក៏ដោយ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលធ្វើការចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា។ ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល[47] រាល់បទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តដោយនីតិបុគ្គលមិនថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុទេនោះរូបវន្តបុគ្គលជាអ្នកទទួលរងទណ្ឌកម្មនៃការប្រព្រឹត្តអំពើល្មើសនោះ។ ចុងក្រោយករណីលើការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្ដើមប្រព្រឹត្តនៅកម្ពុជា មានអានុភាពអនុវត្តទៅលើជនគ្រប់រូបដែលជាអ្នកផ្ដើមគំនិត ឬអ្នកសមគំនិតដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តនៅបរទេសដោយលក្ខខណ្ឌចំនួន២ ត្រូវបានបំពេញគឺ : (១) បទល្មើសដែលត្រូវផ្ដន្ទាទោសតាមច្បាប់កម្ពុជាផង និងច្បាប់បរទេសផង និង(២) អត្ថិភាពនៃបទល្មើសត្រូវបានបញ្ជាក់ដោយសេចក្ដីសម្រេចជាស្ថាពររបស់តុលាការបរទេស។ ក្នុងករណីបទឆបោកជនល្មើសមានចេតនាទុច្ចរិតឆបោកប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែត្រូវប្រគល់វត្ថុណាមួយនៅបរទេស។ លើសពីនេះទៅទៀតដូចជា បទល្មើសទទួលផលចោរកម្មដែលអំពើល្មើសប្រព្រឹត្តនៅកម្ពុជាហើយអ្នករក្សាទុកផលចោរកម្មនោះប្រព្រឹត្តនៅឯបរទេស។ ទោះបីជាយ៉ាងណាក្ដីយើងក៏ឃើញមានករណីមួយចំនួនដែលច្បាប់កម្ពុជា

---

[42] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[43] មាត្រា ១២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[44] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[45] មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[46] មាត្រា ១៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[47] មាត្រា ១៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

មិនអាចអនុវត្តបានដោយផ្អែកលើរឿងអភ័យឯកសិទ្ធិដែលទទួលស្គាល់ដោយ សន្ធិសញ្ញាអន្តរជាតិដូចជា ប្រមុខការបទេស ឬប្រមុខបេសកកម្មការទូត។ ផ្ទុយទៅវិញចំពោះជនណាដែលជាជនជាតិខ្មែរ ទោះបីជាមាន អភ័យឯកសិទ្ធិដែលទទួលស្គាល់ដោយបរទេសប្រសិនបើជននោះបានប្រព្រឹត្តផ្ទុយពីច្បាប់ចែងនៅក្នុងប្រទេស កម្ពុជាក្នុងរយៈពេលស្នាក់នៅមួយរយៈ ឬធ្វើដំណើរនោះត្រូវទទួលខុសត្រូវតាមច្បាប់ព្រហ្មទណ្ឌកម្ពុជា។

**ខ. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ក្រៅពីបទល្មើសដែលបានប្រព្រឹត្តក្នុងដែនដីនៃព្រះរាជណាចក្រកម្ពុជាក៏មាន បទល្មើសមួយចំនួនដែល កើតមាននៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាហើយច្បាប់កម្ពុជាមានអានុភាពក្នុងការអនុវត្តទោសលើករណី មួយចំនួនរួមមានដូចខាងក្រោម៖

- **អ្នកប្រព្រឹត្តបទល្មើសជាជនជាតិខ្មែរ៖** ចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមនៅក្នុងរឿងព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយជនជាតិខ្មែរនោះច្បាប់កម្ពុជាមានអានុភាពអនុវត្តន៍បាន ទោះបីជាបទល្មើស បានកើតឡើងក្រៅដែនដីកម្ពុជាក៏ដោយ។ ករណីពិសេសលើបទល្មើសមជ្ឈិម ច្បាប់កម្ពុជាមាន អានុភាពក្នុងការអនុវត្ត លុះត្រាតែអំពើនៃបទមជ្ឈិមនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេស នោះ។
- **ករណីជនរងគ្រោះជាជនជាតិខ្មែរ៖** នោះច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងអាចអនុវត្តបានទៅលើបទ ឧក្រិដ្ឋដែលកើតលើជនជាតិខ្មែរ។ ក្នុងករណីនេះផងដែរគេមិនគិតទេថាជនប្រព្រឹត្តជាជនជាតិខ្មែរ ឬជនបរទេស។
- **ចំពោះការធ្វើបណ្តឹងចោទប្រកាន់៖**
  - លើការធ្វើបណ្តឹងចោទប្រកាន់ ករណីពលរដ្ឋខ្មែរបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម នៅឯបរទេស ឬក្នុងករណីដែលជនរងគ្រោះជាជនជាតិខ្មែរទទួលរងអំពើនៃបទឧក្រិដ្ឋ នោះបណ្តឹងអាចធ្វើទៅបានលុះត្រាតែមាននូវបណ្តឹងរបស់ជនរងគ្រោះ ឬសិទ្ធិវន្ត ឬមាន បណ្តឹងជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាកន្លែងប្រព្រឹត្តបទល្មើស។
  - ចំណែកការចោទប្រកាន់ទៅលើជនដែលបានប្រព្រឹត្តបទល្មើស អាចកើតមានបានតាម រយៈបណ្តឹងរបស់តំណាងស្ថាប័នអយ្យការប៉ុណ្ណោះ។
- **ចំពោះសមត្ថកិច្ចដោយឡែកផ្សេងទៀត** ច្បាប់កម្ពុជាអាចអនុវត្តទៅលើគ្រប់បទល្មើសឧក្រិដ្ឋ ទាំងឡាយណារួមមាន៖
  - បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា
  - បទល្មើសក្លែងត្រានៃព្រះរាជាណាចក្រកម្ពុជា

- បទល្មើសរូបិយវត្ថុជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា
- បទល្មើសដែលប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា
- បទល្មើសប្រឆាំងនឹងទីកន្លែងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

### ៣.២. **ធាតុសត្យានុម័ត** (**ធាតុសម្ភារៈ**)

ជាទូទៅអំពើមួយតែងផុសចេញពីគំនិតជាមុនដោយមានការរៀបចំប្រុងប្រៀបប្រព្រឹត្តបទល្មើស ឬការចាប់ផ្តើមប្រព្រឹត្ត ប៉ុន្តែរាល់គំនិត ឬបំណង ពេលខ្លះមនុស្សដែលកំពុងគិតពីរឿងល្អអាចប្តូរទៅជាការគិតអាក្រក់ ហើយពេលខ្លះកំពុងគិតរឿងអាក្រក់ក៏អាចប្តូរទៅជាគិតរឿងល្អបានភ្លាមដែរ ហេតុនេះក្នុងការប្រព្រឹត្តបទល្មើសមិននាំឱ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌឡើយព្រោះថាវាមិនមានភាពជាក់លាក់អាចឱ្យយើងដឹងបានតាមការសម្តែងចេញតាមរយៈអាការៈខាងក្រៅដែរ។ យើងអាចកត់សម្គាល់អំពើដែលស្តែងឱ្យឃើញយ៉ាងពិតប្រាកដពីបំណងក្នុងការប្រព្រឹត្តបទល្មើសរួមមាន កាយវិការ សំដី សំណេរ ឬអាកប្បកិរិយាសាមញ្ញណាមួយផ្សេងទៀត។

#### ៣.២.១. **បទល្មើសបានសម្រេច**

បទល្មើសបានសម្រេច គឺជាបទល្មើសមួយដែលជនប្រព្រឹត្តបានសម្រេចដល់គោលបំណងរបស់ខ្លួនដែលចង់បាន ឬជាបទល្មើសដែលលេចចេញជារូបរាងឡើងដោយការខកខានមិនបានប្រព្រឹត្ត ឬមិនអើពើដែលអាការៈនៃអំពើបែបនេះធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈរបៀបរៀបរយសន្តិសុខសង្គម ឬធ្វើឱ្យគ្រោះថ្នាក់ដល់សង្គមនោះ។ ក្នុងចំណុចនេះ យើងនឹងធ្វើការបែងចែកជាអំពើសកម្ម(**៣.២.១.១.**) និងអំពើអកម្ម (**៣.២.១.២.**)។

##### ៣.២.១.១. **អំពើសកម្ម**

បទល្មើសសកម្ម គឺជាបទល្មើសដែលជនប្រព្រឹត្តបានធ្វើសកម្មភាពបំពានទៅលើទំនាក់ទំនងសង្គមដែលច្បាប់ព្រហ្មទណ្ឌការពារ ឬអាចនិយាយថាជាអំពើប្រព្រឹត្តដោយវិជ្ជមាន។ យើងអាចនិយាយតាមអត្ថន័យដូចគ្នាម្យ៉ាងទៀតថាបទល្មើសសកម្ម ជាបទល្មើសដែលជនល្មើសប្រព្រឹត្តផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌមានន័យថាច្បាប់ព្រហ្មទណ្ឌហាមមិនឱ្យប្រព្រឹត្តជនល្មើសបែរជាប្រព្រឹត្ត។ ឧទាហរណ៍ យើងឃើញជាញឹកញាប់ទាក់ទងនឹងការប្រព្រឹត្តបទល្មើសសកម្មដូចជា :

- បទជេរប្រមាថ គឺជនល្មើសបានប្រើពាក្យជេរប្រមាថធ្ងន់ ឬពាក្យមើលងាយផ្សេងសំដៅទៅលើជនណាម្នាក់ ឬច្រើននាក់។
- បទឆបោក គឺជនល្មើសបានធ្វើឱ្យជនរងគ្រោះឱ្យទៅខ្លួននូវទ្រព្យសម្បត្តិណាមួយដោយជនរងគ្រោះជឿតាមអំណាច ឬដោយធ្វើឱ្យជនរងគ្រោះខ្លាច ឬសង្ឃឹមលើព្រឹត្តិការណ៍អ្វីមួយ។

- បទរំលោភសេពសន្ថវៈ គឺជនល្មើសបានបញ្ចូលអង្គជាតិ ឬមធ្យោបាយផ្សេងទៀតដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។ល។

តាមរយៈឧទាហរណ៍ខាងលើ សបញ្ជាក់ឱ្យឃើញថាគ្រប់អំពើប្រព្រឹត្តជនល្មើសសុទ្ធតែបានដល់គោលបំណងរបស់ខ្លួន ហេតុនេះហើយទើបយើងចាត់ទុកអំពើទាំងនេះជាបទល្មើសបានសម្រេចដោយសកម្ម។

**៣.២.១.២. អំពើអកម្ម**

បទល្មើសមួយដែលអ្នកនីតិបញ្ញត្តិរមែងតែងតែទុកសកម្មភាពល្មើសណាមួយថាជាបទល្មើស ប៉ុន្តែការមិនបំពេញកាតព្វកិច្ចរបស់ជនណាម្នាក់ ឬច្រើននាក់ ទោះបីជាការមិនបំពេញនេះកើតចេញពីការភ្លេច ឬការបំភ្លេចក៏ដោយឱ្យតែអំពើនោះជនប្រព្រឹត្តមានលទ្ធភាពគ្រប់គ្រាន់ការបំពេញតែជននោះ មិនបានបំពេញទៅតាមច្បាប់។ យើងអាចនិយាយឱ្យកាន់តែងាយយល់ថែមទៀតថាបទល្មើសអកម្ម គឺជាអំពើមួយដែលច្បាប់តម្រូវឱ្យប្រព្រឹត្តតែជនដែលមានកាតព្វកិច្ចនោះមិនព្រមប្រព្រឹត្ត។

ឧទាហរណ៍ :

- ជនបទល្មើសចំពោះការមិនប្តឹងបរិហារបទឧក្រិដ្ឋ ដោយបានចែងថារាល់បុគ្គលណាដែលមិនដឹងពីបទឧក្រិដ្ឋដែលអាចនឹងបង្ការ ឬបន្ថយអានុភាពរបស់បទល្មើសបាន ហើយមិនប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀតត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១សែនរៀល ទៅ២លានរៀល[48]។
- បទមិនព្រមប្រគល់អនីតិជន ចំពោះអំពើប្រព្រឹត្តដោយគំនិតទុច្ចរិតមិនព្រមប្រគល់អនីតិជនឱ្យទៅបុគ្គលដែលមានសិទ្ធិទាមទារនោះ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែ ទៅ១ឆ្នាំ និងពិន័យជាប្រាក់ពី១សែនរៀល ទៅ២លានរៀល។[49]

**៣.២.២. បទល្មើសមិនបានសម្រេច ឬអំពើប៉ុនប៉ង**

ពេលខ្លះដើម្បីឱ្យអំពើល្មើសមួយ អាចផ្តន្ទាទោសច្បាប់មិនតម្រូវឱ្យរង់ចាំរហូតដល់លទ្ធផលបានសម្រេចនោះទេ។ ដំណាក់កាលនៃការប្រព្រឹត្តបទល្មើសមានពីរយ៉ាងសំខាន់ៗគឺ៖

- **ដំណាក់កាលខាងក្នុង** : សំដៅលើគំនិតប្រព្រឹត្តល្មើសចំណង់ប្រព្រឹត្តល្មើស និងការសម្រេចថាប្រព្រឹត្ត ឬអាចនិយាយម្យ៉ាងទៀតថាជាការសម្រេចចិត្តដែលនឹងធ្វើឱ្យគំនិតរបស់ខ្លួនបានទទួលផ្លែផ្កា។

[48] មាត្រា ៥២៩ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[49] មាត្រា ៣២៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

- **ដំណាក់កាលខាងក្រៅ** : ជាដំបូងចាប់ផ្តើមដោយការរៀបចំដូចជាការសិក្សាទៅលើទីកន្លែងប្រព្រឹត្ត ឬការទិញអាវុធ បន្ទាប់មកឈានដល់ការប្រតិបត្តិអំពើល្មើស ឬការប្រព្រឹត្ត និងចុងក្រោយបំផុតគឺលទ្ធផលជាព្យសនកម្មដែលចារីប្រាថ្នាចង់បាន។

យើងសម្គាល់ទៅលើថា បើការប្រព្រឹត្តបទល្មើសឈានរហូតដល់ដំណាក់កាលចុងក្រោយជាបទល្មើសសម្រេចផល ហើយបើការប្រព្រឹត្តត្រូវអាក់ខានទៅវិញជាការប៉ុនប៉ង។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់យ៉ាងច្បាស់លាស់ពីលក្ខខណ្ឌនៃការប៉ុនប៉ង(**៣.២.២.១.**) និងទណ្ឌកម្មនៃអំពើប៉ុនប៉ង(**៣.២.២.២.**)។

### ៣.២.២.១. លក្ខខណ្ឌនៃអំពើប៉ុនប៉ង

ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងករណីដែលច្បាប់បានចែងទុកចំពោះបទមជ្ឈិម។[50] ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋទាំងអស់ត្រូវទទួលផ្តន្ទាទោស ចំណែកការប៉ុនប៉ងក្នុងបទមជ្ឈិមវិញត្រូវទទួលការផ្តន្ទាទោសកាលបើច្បាប់បានចែងទុក ហើយការប៉ុនប៉ងក្នុងបទលហុពុំទទួលបានការផ្តន្ទាទោសនោះទេ។ ការប៉ុនប៉ងមានទោសត្រូវមានលក្ខខណ្ឌទាំងពីរយ៉ាងនេះរួមបញ្ចូល ការចាប់ផ្តើមប្រព្រឹត្ត (**ក**) និងការបញ្ឈប់វិញក្រៅពីឆន្ទៈរបស់ជនល្មើស (**ខ**)

#### ក. ការចាប់ផ្តើមប្រព្រឹត្ត

ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស។ ការចាប់ផ្តើមអនុវត្តស្តែងឡើងតាមរយៈអំពើជាសម្ភារៈរួមជាមួយនឹងការគិត ឬគំនិតអាក្រក់ដែលវាជាបំណងដ៏ពិតប្រាកដរបស់ជនល្មើសក្នុងការប្រព្រឹត្តបទល្មើស។ ការប្រព្រឹត្តបទល្មើស រមែងតែងតែបានចាប់ផ្តើមឡើងដោយសារតែការសម្រេចចិត្តនៅក្នុងគំនិត ហើយបើទោះជាមានកិច្ចរៀបចំប្រព្រឹត្តបទល្មើសនៅក្នុងដំណាក់កាលនេះមិនទាន់អាចត្រូវផ្តន្ទាទោសតាមផ្លូវច្បាប់បានឡើយ។[51] ឧទាហរណ៍ : ការយកអាវុធតាមខ្លួនដោយពុំមានច្បាប់អនុញ្ញាតអាចជាការត្រៀមបម្រុងប្រព្រឹត្តបទល្មើសឃាតកម្ម។ ទន្ទឹមនឹងនេះការយកអាវុធតាមខ្លួនក៏នៅតែជាបទល្មើស កាលណាមិនមានការអនុញ្ញាតត្រឹមត្រូវ។ គួរបញ្ជាក់ផងដែរក្នុងករណីមួយចំនួនដែលច្បាប់បញ្ញត្តិថា អំពើខ្លះទោះជាមិនទាន់បានចាប់ផ្តើមប្រព្រឹត្តបទល្មើសដែលជាកម្មវត្ថុនៃការរៀបចំក៏ដោយក៏តម្រូវឱ្យមានទោសដែរ។ ឧទាហរណ៍ : បទល្មើសគំរាមកំហែង ជនល្មើសនឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គលដោយហេតុផលថាអំពើនេះ ធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គមធ្វើឱ្យជនរងគ្រោះព្រួយបារម្ភ និងការអនុវត្តការគំរាមកំហែងដោយជនល្មើស។

---

[50] មាត្រា ២៥ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[51] មាត្រា ២៧ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ចែងថា : អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ។

ដំណាក់កាលចុងក្រោយ ជាដំណាក់កាលអនុវត្ត។ នៅពេលដែលចារីឈានចូលដល់ដំណាក់នេះហើយ អំពើទាំងឡាយរបស់ចារីសុទ្ធតែអាចផ្តន្ទាទោសបានទាំងអស់ ទោះបីជាចារីពុំទាន់បានសម្រេចគោលដៅចុងក្រោយសមស្របតាមបំណងប្រាថ្នារបស់ខ្លួនក៏ដោយ។ ក្នុងករណីបែបនេះគេសង្កេតឃើញមានការលំបាកយ៉ាងខ្លាំងក្នុងការញែកឱ្យដាច់រវាងអំពើត្រៀមបម្រុង និងការចាប់ផ្តើមអនុវត្តដែលត្រូវតែផ្តន្ទាទោសជាការប៉ុនប៉ង។ អំពើត្រៀមបម្រុង ឬការរៀបចំ មានភាពមិនច្បាស់លាស់នៅឡើយតែការចាប់ផ្តើមអនុវត្ត គឺជាអំពើមួយដែលអាចស្រាយបំភ្លឺបានថាគឺការឈានទៅរកការប្រព្រឹត្តបទល្មើស ពោលគឺបង្ហាញយ៉ាងច្បាស់នូវចេតនាទុច្ចរិតដាច់ខាតរបស់ជនល្មើស។ ឧទាហរណ៍ : យើងអាចធ្វើការបែងចែកបានលើការទិញកាំបិតមកទុកគ្រាន់តែជាអំពើត្រៀមបម្រុងដោយអាចបកស្រាយបានជាច្រើនសណ្ឋានដូចជា ការទិញកាំបិតយកទៅកាប់សាច់សម្រាប់ធ្វើម្ហូប ឬយកមកសម្លាប់មនុស្ស ឬក៏យកទៅសម្លុតគំរាមមនុស្សជាដើម។ ដូចនេះហើយប្រសិនបើបុគ្គលណាម្នាក់យកកាំបិតដែលបានទិញមកនោះទៅលបរង់ចាំឆ្មក់ជនរងគ្រោះតាមផ្លូវ ដែលជនរងគ្រោះតែងតែធ្វើដំណើរជារៀងរាល់ថ្ងៃត្រឡប់ទៅផ្ទះវិញនោះយើងសម្គាល់បានថាជាការចាប់ផ្តើមអនុវត្តបទល្មើសយ៉ាងពិតប្រាកដ។

ឧទាហរណ៍មួយចំនួនទៀតដូចខាងក្រោម :

- អំពើរបស់ជនម្នាក់ដែលមានអាវុធ ហើយបានឱនទៅរកកេះប្រាក់របស់បេឡា។[52]
- ការចរចាជាមួយនឹងជនណាម្នាក់ ដើម្បីទិញគ្រឿងញៀន(**ការទិញលក់គ្រឿងញៀនខុសច្បាប់**)។
- ការប្រាប់ដល់ក្រុមហ៊ុនធានារ៉ាប់រងថាវត្ថុដែលត្រូវបានធានារ៉ាប់រងបានទទួលរងនូវការខូចខាត ក៏ប៉ុន្តែតាមការពិត ការខូចខាតនោះបណ្តាលមកពីការបំផ្លិចបំផ្លាញដោយចេតនារបស់ខ្លួន (**បទឆបោក**)។

ជារួមមកការបែងចែករវាងអំពើត្រៀមបម្រុង និងការចាប់ផ្តើមអនុវត្តស្ថិតនៅត្រង់គោលបំណងប្រព្រឹត្តបទល្មើស បានសេចក្តីថាអំពើណាក៏ដោយដែលស្តែងឱ្យឃើញច្បាស់ពីគោលបំណងក្នុងការប្រព្រឹត្តបទល្មើសនោះគឺជាការចាប់ផ្តើមអនុវត្តហើយ។

### ខ. ការបញ្ឈប់វិញក្រៅពីឆន្ទៈរបស់ជនល្មើស

ការប្រព្រឹត្តបទល្មើសរបស់ជនល្មើសត្រូវតែមានឆន្ទៈ ឬមានបំណងធ្វើយ៉ាងណាឱ្យអំពើរបស់ខ្លួនបានសម្រេច។ ដោយឡែកមិនគ្រប់បទល្មើស ឬការប៉ុនប៉ងសុទ្ធតែសម្រេចផលនោះទេ ជួនពេលខ្លះសកម្មភាពរបស់ជនល្មើសអាចនឹងមានការអាក់ខានមិនបានសម្រេចបទល្មើសផងដែរ។ តើមានលក្ខខណ្ឌអ្វីខ្លះដែលធ្វើឱ្យមានការបញ្ឈប់ដោយអឆន្ទៈរបស់ជនល្មើស?

[52] មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ជាទូទៅការបញ្ឈប់ទៅវិញនូវឆន្ទៈរបស់ជនល្មើសពុំត្រូវទទួលទោសពីការប៉ុនប៉ងនោះទេ ព្រោះវាជាការកើតចេញពីឆន្ទៈរបស់ជនល្មើសផ្ទាល់តែម្តង ហើយឆន្ទៈសុចរិតទាំងអស់នោះមានដូចជាការភ័យខ្លាចទទួលរងនូវទណ្ឌកម្ម ការយល់ដឹងអំពីព្យសនកម្មដល់សង្គមដោយសារអំពើប្រព្រឹត្តរបស់ខ្លួន ការអាណិតអាសូរដល់ជនរងគ្រោះ មានការទូន្មានក្រើនរំលឹកដោយតតិយជនណាមួយ ឬខ្លាចទទួលទណ្ឌកម្មខាងផ្លូវសាសនា (ខ្លាចបាប) ជាដើម។ ឧទាហរណ៍ : នៅពេលលើកកាំភ្លើងតម្រង់ទៅលើជនរងគ្រោះ ស្រាប់តែភ្លាមនោះជនប្រព្រឹត្តបានបាញ់ដោយបង្វែរកាណុងឡើងលើវិញ ដោយសារខ្លួនមានការអាណិតអាសូរទៅលើជនល្មើសពេក។ ផ្ទុយទៅវិញបើសិនការអាក់ខានបណ្តាលមកពីព្រឹត្តិការណ៍ខាងក្រៅឆន្ទៈរបស់ចារីនោះការប៉ុនប៉ងត្រូវមានទោស។ ឧទាហរណ៍ ថាពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើស ស្រាប់តែអាជ្ញាធរមានសមត្ថកិច្ចបានមកទាន់។ នៅពេលដែលអំពើល្មើសកំពុងតែចាប់ផ្តើមប្រព្រឹត្ត និងហៀបតែបានសម្រេចផលទៅហើយស្រាប់តែអាក់ខានទៅវិញដោយសារតែចារីមានភាពឆ្គាំឆ្គង ករណីនេះហៅថា **បរាជ័យនៃអំពើល្មើស**។ ឧទាហរណ៍ : ចារីបានយកកាំបិតចាក់សំដៅទៅលើជនរងគ្រោះ ប៉ុន្តែបែរជាមិនត្រូវជនរងគ្រោះដោយសារតែជនរងគ្រោះបានគេចផុត។ ម្យ៉ាងទៀតបទល្មើសខ្លះពុំអាចកើតឡើង ដោយហេតុថាកម្មវត្ថុនៃបទល្មើសពុំមានឡើយនៅពេលដែលចារីបានប្រព្រឹតបទល្មើសពោលគឺបទល្មើសត្រូវបានអាក់ខានមិនបានសម្រេចផលដោយសារតែអវត្តមាននៃកម្មវត្ថុបទល្មើស ឬក៏ព្រោះតែឧបករណ៍ប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសពុំមានប្រសិទ្ធភាពដូចជា ក្នុងករណីដែលចារីបានលួចយកប្រាក់ក្នុងហោប៉ៅខោជនរងគ្រោះតែជាអកុសលហោប៉ៅនោះបែរជាមិនមានប្រាក់។ ដើម្បីដឹងថាមូលហេតុចម្បងដែលជម្រុញឱ្យមានការអាក់ខាននៃបទល្មើសបាន គេត្រូវពិនិត្យទៅតាមរឿងក្តីនីមួយៗហើយវាក៏ជាការលំបាកផងដែរនៃការវិនិច្ឆ័យទៅលើចេតនា ឬអចេតនាពេលប្រព្រឹត្តអំពើណាមួយដែលជាបទល្មើស។

**៣.២.២.២. ទណ្ឌកម្មនៃអំពើប៉ុនប៉ង**

ក្រមព្រហ្មទណ្ឌបានចែងអំពីប៉ុនប៉ង ត្រូវផ្តន្ទាទោសមិនខុសប្លែកពីការផ្តន្ទាទោសលើបទល្មើសដែលសម្រេចផលឡើយ កាលបើលក្ខខណ្ឌនៃការប៉ុនប៉ងមានទោសត្រូវបានពិនិត្យឃើញថាមានគ្រប់គ្រាន់។[53] ក្នុងច្បាប់ព្រហ្មទណ្ឌចាស់គេចែងផ្តន្ទាទោសបទល្មើសបានសម្រេចផល និងការប៉ុនប៉ងប្រព្រឹត្តបទល្មើសតាមបទបញ្ញត្តិនីមួយៗផ្ទាល់តែម្តង។ ទណ្ឌកម្មនៃការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ មានទោសស្មើនឹងបទល្មើសដែលសម្រេចផល តែក្នុងបទមជ្ឈិមវិញការប៉ុនប៉ងប្រព្រឹត្តបទល្មើសអាចទទួលបានការផ្តន្ទាទោសបាន លុះត្រាតែមានច្បាប់ចែងទុកជាមុនថាការប៉ុនប៉ងសម្រាប់បទមជ្ឈិមណាមួយនោះត្រូវទទួលការផ្តន្ទាទោស។ ដោយឡែកការប៉ុនប៉ងប្រព្រឹត្តបទល្មើសក្នុងបទលហុច្បាប់មិនបានកំណត់អំពីទណ្ឌកម្មនៃការប៉ុនប៉ងទេ។ ជាក់ស្តែងក្នុងការអនុវត្តដោយសារការប៉ុនប៉ងមិនទាន់បានបង្កព្យសនកម្មសម្រាប់សង្គមនៅឡើយ ចៅក្រមមិនដាក់ទោសលើចារីនៃការ

[53] មាត្រា២៥ និង២៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ប៉ុនប៉ងធ្ងន់ធ្ងរដូចទៅនឹងបទល្មើសដែលបានសម្រេចផលនោះទេ ដូចនេះហើយចៅក្រមប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិនិត្យពិចារណាទៅលើស្ថានភាពទាំងឡាយរបស់បទល្មើសដែលបានកើតឡើង គឺជាកត្តាសំខាន់បំផុតដើម្បីនឹងធ្វើការដាក់ទណ្ឌកម្មប្រកបដោយភាពត្រឹមត្រូវទៅនឹងអំពើរបស់ជនល្មើស។

### ៣.២.៣. ហេតុ បច្ច័យ

ជាគោលការណ៍ហេតុបច្ច័យ គឺជាផ្នែកមួយនៃធាតុសត្យានុម័តដែលមានន័យថាដើម្បីផ្តន្ទាទោសទៅលើជនណាម្នាក់ថាបានប្រព្រឹត្តបទល្មើសអ្វីមួយនោះចៅក្រមត្រូវធ្វើការពិចារណាពិនិត្យមើលនូវលក្ខណៈផ្សាភ្ជាប់គ្នាយ៉ាងជិតស្និតរវាងអំពើប្រព្រឹត្តដែលជាហេតុទៅនឹងព្យសនកម្មដែលជាបច្ច័យបានកើតឡើង។ ខាងក្រោមនេះ ជាគោលការណ៍ទូទៅមួយចំនួនដែលប្រើប្រាស់នៅក្នុងយុត្តាធិការភាគច្រើន :

- **ការទទួលទោសតាមព្យសនកម្មរបស់ជនរងគ្រោះ** : ជាទូទៅនៅពេលដែលជនណាម្នាក់សម្រេចចិត្តប្រព្រឹត្តបទល្មើសអ្វីមួយ ជននោះត្រូវទទួលខុសត្រូវនូវផលវិបាកដែលកើតមានឡើង ទោះបីជាជននោះមិនបានដឹងពីស្ថានភាពខាងក្រៅ និងស្ថានភាពផ្លូវចិត្តជនរងគ្រោះក៏ដោយ។
- **ការទទួលទោសតាមលក្ខខណ្ឌនៃអំពើរបស់ជនរងគ្រោះ** : ជនប្រព្រឹត្តត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបច្ច័យអាក្រក់ដែលបណ្តាលមកពីអំពើរបស់ជនរងគ្រោះខ្លួនឯងដែរ ប្រសិនបើការប្រព្រឹត្តបណ្តាលមកពីហេតុរបស់ជនល្មើស ហើយជនល្មើសអាចប្រមើលដឹងមុនបានថាហេតុនៃអំពើរបស់ខ្លួនអាចបណ្តាលឱ្យមានផលអាក្រក់កើតឡើង។
- **ការទទួលទោសតាមលក្ខខណ្ឌនៃអំពើរបស់តតិយជន** : ក្នុងករណីខ្លះជនល្មើសត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែលបណ្តាលមកពីអំពើអន្តរគមន៍របស់តតិយជន ឬអ្នកដទៃដែរ។ ឧទាហរណ៍ ក្នុងស្ថានភាពមួយដែលជនល្មើសបានប្លន់ប្រាក់ពីម្ចាស់ហាងមាសមួយកន្លែង ហើយបានចាប់ម្ចាស់ហាងធ្វើជារនាំង ដើម្បីរំដោះខ្លួនចេញពីនគរបាល ប៉ុន្តែដោយសារស្ថានភាពចាំបាច់ក្នុងការការពារខ្លួន ដោយជៀសមិនរួចនគរបាលក៏សម្រេចចិត្តបាញ់តបវិញដែលគ្រាប់កាំភ្លើងមួយគ្រាប់ត្រូវចំជនរងគ្រោះបណ្តាលឱ្យស្លាប់ទៅ។ ករណីនេះ បើទោះបីជាជនល្មើសមិនបានធ្វើឱ្យជនរងគ្រោះស្លាប់ក៏ដោយ ប៉ុន្តែជនល្មើសត្រូវបានផ្តន្ទាទោសពីបទប្លន់នឹងបន្ថែមទោសពីបទមនុស្សឃាតដោយចេតនា ឬបទឃាតកម្មដោយគិតទុកជាមុន។
- **ការទទួលទោសពាក់ព័ន្ធនឹងការព្យាបាលរបស់ពេទ្យលើជនរងគ្រោះ** : ក្នុងករណីជនល្មើសបានប្រព្រឹត្តលើជនរងគ្រោះ ហើយជនរងគ្រោះត្រូវបានស្លាប់នៅមន្ទីរពេទ្យ ក្រោយពីគ្រូពេទ្យបានព្យាបាលនោះ។ ករណីនេះជាទូទៅជនល្មើសត្រូវលើការស្លាប់របស់ជនរងគ្រោះនេះដោយមិនអាចនិយាយថាជនរងគ្រោះត្រូវស្លាប់តាមរយៈការព្យាបាលរបស់គ្រូពេទ្យបានឡើយ។ លើកលែង

តែមានភស្តុតាងបង្ហាញថាគ្រូពេទ្យមានការធ្វេសប្រហែស ឬមិនយកចិត្តទុកដាក់ក្នុងការព្យាបាលដែលអំពើនេះជាបទល្មើសប្រឆាំងនឹងជនរងគ្រោះរហូតធ្វើឱ្យជនរងគ្រោះស្លាប់។ ត្រឡប់មកវិញបើជនរងគ្រោះមានសភាពមិនធ្ងន់ធ្ងរពេកទេហើយក៏មិនត្រូវស្លាប់ដែរ បើមានការព្យាបាល ប៉ុន្តែជនរងគ្រោះត្រូវស្លាប់ដោយមិនបានព្យាបាលព្រោះគ្រូពេទ្យស្រវឹងស្រាខ្លាំងពេក។ ក្នុងករណីនេះជនល្មើសប្រហែលជាមិនទទួលខុសត្រូវលើការស្លាប់នេះទេ។ ពាក់ព័ន្ធទៅនឹងភស្តុតាងច្បាស់លាស់មួយដោយអ្នកជំនាញ គឺជាការចាំបាច់ណាស់ បើអ្នកជំនាញធ្វើកោសល្យវិច័យបញ្ជាក់ថាជនរងគ្រោះអាចនៅរស់ ទោះបីមានការព្យាបាលមិនសូវល្អក៏ដោយនោះតុលាការអាចសម្រេចថាជនល្មើសមិនបានបង្កមូលហេតុឱ្យជនរងគ្រោះស្លាប់ទេ។ ផ្ទុយទៅវិញបើអ្នកជំនាញបញ្ជាក់ថាទោះជាមានការព្យាបាលក៏ជនរងគ្រោះនៅតែស្លាប់ដែរនោះ ជនល្មើសនឹងត្រូវតុលាការកំណត់ថាជាអ្នកបង្កហេតុបណ្តាលឱ្យមានបច្ច័យកើតឡើង គឺជនរងគ្រោះស្លាប់។

### ៣.៣. ធាតុអត្តនោម័ត (ធាតុចិត្តសាស្ត្រ)

ជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌពុំអាចកំណត់បទល្មើសមួយត្រឹមធាតុសត្យានុម័តទេ ព្រោះតែវានៅមានលក្ខណៈមិនគ្រប់គ្រាន់។ ធាតុផ្សំដែលមានភាពសំខាន់ហើយមិនអាចខ្វះបាននោះ គឺធាតុអត្តនោម័តដែលតម្រូវឱ្យសិក្សាអំពីស្ថានភាពផ្លូវចិត្តរបស់ជនប្រព្រឹត្តអំពើណាមួយ។ ស្ថានភាពផ្លូវចិត្តរបស់ជនប្រព្រឹត្តអំពើណាមួយ គឺជាផ្នែកសំខាន់បំផុតក្នុងការកំណត់ថាតើជននោះត្រូវមានទោស ឬគ្មានទោស។ ជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌ ជនដែលបានប្រព្រឹត្តអំពើណាមួយស្តែងចេញមកពីឆន្ទៈ និងការដឹងពីលទ្ធផលខុសច្បាប់នៃអំពើរបស់ខ្លួនដែលគេហៅថាកំហុសចេតនា និងក្នុងករណីខ្លះទៀតបើទោះបីជាកំហុសសំដៅទៅលើស្ថានភាពដែលមិនមានឆន្ទៈគ្រប់គ្រាន់ ឬការប្រុងប្រយ័ត្នគ្រប់គ្រាន់ដើម្បីជៀសវាងនូវលទ្ធផលខុសច្បាប់ដែលគេហៅថាកំហុសអចេតនា។ ដូច្នេះហើយនៅក្នុងចំណុចនេះហើយនឹងមកស្គាល់ពីកំហុសចេតនា(**៣.៣.១.**) និងកំហុសអចេតនា(**៣.៣.២.**) រួមទាំងការវាយតម្លៃអំពីកំហុសចេតនា និងអចេតនា (**៣.៣.៣.**)។

#### ៣.៣.១. កំហុសចេតនា

ចេតនាប្រព្រឹត្តបទល្មើស សំដៅទៅលើឆន្ទៈឆ្ពោះទៅរកការប្រព្រឹត្តបទល្មើសដែលបានកំណត់ដោយច្បាប់ កាលបើចារីស្វែងរកលទ្ធផលខុសច្បាប់ពីអំពើរបស់ខ្លួន និងចារីដឹងថាអំពើរបស់ខ្លួននឹងផ្តល់នូវលទ្ធផលខុសច្បាប់នេះ។[54] ចេតនាប្រព្រឹត្តបទល្មើសត្រូវរួមផ្សំដោយ :

- **ចេតនាសម្រេចបទល្មើស** គឺជាចេតនារបស់បុគ្គលម្នាក់ដែលមានសេរីភាព និងមនសិការគ្រប់គ្រាន់ក្នុងការស្វែងរកលទ្ធផលដែលច្បាប់ព្រហ្មទណ្ឌហាមឃាត់ ឬនិយាយម្យ៉ាងទៀតថាជា

[54] មាត្រា៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

ចេតនាចង់រំលោភច្បាប់ព្រហ្មទណ្ឌតែម្តង។ ដូច្នេះចេតនាត្រូវផ្តើមចេញពីបុគ្គលម្នាក់ដែលមានសេរីភាពពេញលេញ និងមានមនសិការគ្រប់គ្រាន់ដឹងខុសត្រូវថាអំពើណាជាអំពើខុសច្បាប់ព្រហ្មទណ្ឌ ហើយនៅតែមានបំណងប្រព្រឹត្តអំពើខុសច្បាប់នោះទៀត។

- **ចេតនាប្រព្រឹត្តអំពើ** សំដៅទៅលើចារីត្រូវប្រព្រឹត្តអំពើដោយចេតនា បានន័យថាដោយដឹងច្បាស់ពីអំពើរបស់ខ្លួន។

ចេតនាទុច្ចរិតមានច្រើនប្រភេទរួមមាន ចេតនាទុច្ចរិតទូទៅ(**៣.៣.១.១.**) ចេតនាទុច្ចរិតពិសេស (**៣.៣.១.២.**) ចេតនាទុច្ចរិតធ្ងន់ធ្ងរ(**៣.៣.១.៣.**) ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ(**៣.៣.១.៤.**) និងចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់(**៣.៣.១.៥.**)។

**៣.៣.១.១. ចេតនាទុច្ចរិតទូទៅ**

ចេតនាទុច្ចរិតទូទៅ គឺជាចេតនារបស់ចារីក្នុងការប្រព្រឹត្តអំពើដែលខ្លួនបានដឹងថាច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ចេតនាទុច្ចរិតទូទៅ មានគ្រប់បទល្មើសទាំងអស់ដែលជនល្មើសមានចេតនាបំពានលើការហាមឃាត់ផ្នែកព្រហ្មទណ្ឌ តែមិនសំដៅទៅលើចេតនាព្យាបាទណាមួយនោះទេ។ និយាយជារួមការបង្ហាញភស្តុតាងពីចេតនាទុច្ចរិតទូទៅរបស់ចារី គឺជាការបង្ហាញភស្តុតាងឱ្យឃើញពី**ឆន្ទៈ** និង**មនសិការ** ដឹងខុសត្រូវពីលទ្ធផលខុសច្បាប់របស់ចារី។

**៣.៣.១.២. ចេតនាទុច្ចរិតពិសេស**

ចេតនាទុច្ចរិតពិសេស គឺជនល្មើសមានចេតនាចង់ឱ្យអំពើដែលខ្លួនប្រព្រឹត្តទទួលបាននូវលទ្ធផលជាក់លាក់ណាមួយដែលជាលទ្ធផលពិសេសសម្រាប់បទល្មើសដែលខ្លួនបានប្រព្រឹត្ត។ ឧទាហរណ៍ : ការញុះញង់ឱ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋដោយបានសម្រេចផល ពេលដែលជនល្មើសមានចេតនាពិសេសក្នុងការធ្វើឱ្យបទល្មើសឧក្រិដ្ឋមួយបានសម្រេចតាមរយៈការញុះញង់របស់ខ្លួន។

**៣.៣.១.៣. ចេតនាទុច្ចរិតធ្ងន់ធ្ងរ**

ពិតប្រាកដណាស់បទល្មើសព្រហ្មទណ្ឌទាំងអស់សុទ្ធតែកើតចេញពីចេតនាទុច្ចរិតដោយសារតែជនល្មើសមានស្ថានភាពផ្លូវចិត្តខុសៗគ្នា ពេលខ្លះជនល្មើសចង់ឱ្យអំពើប្រព្រឹត្តរបស់ខ្លួនបង្កើតបានជាព្យសនកម្មយ៉ាងធំធេងដែលលទ្ធផលនៃអំពើនេះកើតចេញពីចេតនាទុច្ចរិតដ៏ធ្ងន់ធ្ងររបស់ជនល្មើស ហើយបង្កនូវគ្រោះថ្នាក់យ៉ាងខ្លាំង និងយ៉ាងធ្ងន់ធ្ងរដល់សង្គម។

ឧទាហរណ៍ : ជនល្មើសមានចេតនាទុច្ចរិតធ្ងន់ធ្ងរ ក្នុងការប្រព្រឹត្តបទល្មើសឃាតកម្មដោយគិតទុកជាមុនតាមពិតបទល្មើសនេះបង្កើតជាព្យសនកម្មបណ្តាលឱ្យជនរងគ្រោះស្លាប់ ដូចជាព្យសនកម្មក្នុងបទឃាតកម្មដែរ

ប៉ុន្តែបទល្មើសឃាតកម្ម គឺជនល្មើសប្រព្រឹត្តក្នុងចេតនាទុច្ចរិតទូទៅតែប៉ុណ្ណោះ រីឯបទឃាតកម្មដោយគិតទុកជាមុនគឺមានការគិតទុកចាំមុន ឬបានរៀបចំការពួនស្ទាក់ដែលអំពើនោះគឺជាចេតនាទុច្ចរិតដ៏ធ្ងន់ធ្ងរ។[55]

### ៣.៣.១.៤. ចេតនាទុច្ចរិតចំពោះ និងមិនចំពោះ

ចេតនាទុច្ចរិតចំពោះ គឺជាកំហុសរបស់បុគ្គលម្នាក់ដោយក្នុងពេលប្រព្រឹត្តអំពើដែលបង្កគ្រោះថ្នាក់ដល់សង្គម ជននេះបានដឹងជាក់ច្បាស់ថាអំពើរបស់ខ្លួនមានចរិតគ្រោះថ្នាក់ ហើយមើលឃើញច្បាស់ពិតប្រាកដនូវបច្ច័យគ្រោះថ្នាក់នៃអំពើរបស់ខ្លួន ហើយចារីនៅតែចង់ឱ្យបច្ច័យនោះកើតឡើងទៀត។ ឧទាហរណ៍ថា ដោយសារការទាស់ពាក្យសំដីជាមួយម្ចាស់រថយន្តបានធ្វើឱ្យចារីវាយរថយន្តរបស់ជនរងគ្រោះខូចខាត។

ចំណែកចេតនាទុច្ចរិតមិនចំពោះ គឺជាកំហុសរបស់បុគ្គលម្នាក់ដោយក្នុងពេលប្រព្រឹត្តបទល្មើស ដោយបានយល់ដឹងពីចរិតគ្រោះថ្នាក់ដល់សង្គមនៃអំពើរបស់ខ្លួនដែរ តែខ្លួនពុំប៉ងប្រាថ្នាឱ្យបច្ច័យកើតឡើងទេ ក៏ប៉ុន្តែអំពើនោះបានធ្វើឱ្យបច្ច័យណាមួយកើតឡើងទៅវិញ។ សម្រាប់ជនល្មើសលទ្ធផលនៃអំពើល្មើសមានលក្ខណៈបន្ទាប់បន្សំតែប៉ុណ្ណោះពីព្រោះថាអំពើរបស់ខ្លួនមានគោលដៅផ្សេងទៅវិញដោយសារតែព្រឹត្តិការណ៍ណាមួយនោះជនល្មើសបានធ្វើឱ្យកើតឡើងនូវព្យសនកម្មលើសពីអ្វីដែលខ្លួនបានគ្រោងទុកទៅទៀត។ ហេតុដូច្នេះហើយទើបអ្នកនីតិបញ្ញត្តិបានកំណត់យកព្យសនកម្មចុងក្រោយ ធ្វើជាមូលដ្ឋាននៃការកំណត់បទល្មើសជាក់លាក់ណាមួយទៅវិញ។ ឧទាហរណ៍ : ប្រសិនបើចារីមានបំណងវាយជនរងគ្រោះឱ្យមានរបួស តែបែរជាជនរងគ្រោះស្លាប់ទៅវិញនោះ ចារីនឹងត្រូវទទួលរងនូវការផ្តន្ទាទោសពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ។[56]

### ៣.៣.១.៥. ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់

ចេតនាទុច្ចរិតច្បាស់លាស់ នៅពេលដែលលទ្ធផលទទួលបានពិតប្រាកដមានលក្ខណៈដូចគ្នាទៅនឹងអ្វីដែលជនល្មើសមានចេតនាប៉ងប្រាថ្នាចង់បាន។ ឧទាហរណ៍ : នៅពេលដែលចារីចង់សម្លាប់លោក **A** ចារីបានធ្វើឱ្យលោក **A** ទទួលមរណភាពដោយសារស្នាដៃផ្ទាល់របស់ខ្លួន ដូច្នេះហើយចារីពិតជាមានចេតនាទុច្ចរិតច្បាស់លាស់។ រីឯចេតនាទុច្ចរិតមិនច្បាស់លាស់ គឺជាការប្រព្រឹត្តដែលពុំបានដឹងច្បាស់លាស់ពីលទ្ធផលនៃអំពើល្មើសរបស់ខ្លួននោះទេ ពីព្រោះថាព្យសនកម្មដែលចារីចង់បានមានលក្ខណៈមិនច្បាស់លាស់ ឬមួយក៏ជនរងគ្រោះនៃអំពើល្មើសមានលក្ខណៈមិនច្បាស់លាស់។ និយាយរួមមកចារីពុំអាចគិតជាមុនបានច្បាស់លាស់អំពីលទ្ធផលនៃអំពើរបស់ខ្លួនបានទេ។

---

[55] មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[56] មាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ៣.៣.២. កំហុសអចេតនា

ជាការពិតណាស់ថា មានបទល្មើសខ្លះច្បាប់បានតម្រូវឱ្យមានការផ្តន្ទាទោស ទោះបីបទប្រព្រឹត្តដោយអចេតនាក៏ប៉ុន្តែលុះត្រាតែតុលាការរកឃើញថាជនប្រព្រឹត្តមានចេតនា មិនប្រុងប្រយ័ត្ន ធ្វេសប្រហែសជាដើម។ ផ្ទុយទៅវិញជនដែលប្រព្រឹត្តដោយអចេតនា ឬដោយចៃដន្យនោះមិនបានរកឃើញថាមានចេតនាធ្វេសប្រហែស ឬមិនប្រយ័ត្នទេនោះជនប្រព្រឹត្តនឹងមិនទទួលទោសព្រហ្មទណ្ឌឡើយ។ កំហុសអចេតនា គឺជាកំហុសដែលកើតឡើងពីការគ្រប់គ្រងឆន្ទៈរបស់ខ្លួនឯងបាន មានន័យថាចារីមានបំណងធ្វើសកម្មភាពរបស់ខ្លួនក៏ប៉ុន្តែចារីពិតជាពុំមានឆន្ទៈ ឬពុំបានដឹងពីផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួនឡើយ។[57] ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មិនបានផ្តល់និយមន័យទៅលើ កំហុសអចេតនាទេគ្រាន់តែរៀបរាប់ពីរបៀបនៃការសម្តែងចេញនូវកំហុសអចេតនាតែប៉ុណ្ណោះ។

កំហុសអចេតនាមានដូចជា៖

- **ការមិនប្រុងប្រយ័ត្ន** : ការមិនប្រុងប្រយ័ត្ន សំដៅទៅលើអំពើទាំងឡាយណាដែលបណ្តោលមកពីដូចជា៖ ការមិនបានប្រុងប្រៀបស្មារតីដោយការរាយមាយជាដើម។ ឧទាហរណ៍ : ការបើកបរម៉ូតូដោយគិតតែរវើរវាយទៅរឿងផ្សេងៗហើយមិនបានផ្តោតអារម្មណ៍លើការបើកបរ ជាដើម។
- **ការខ្ជីខ្ជា** : ការខ្ជីខ្ជា សំដៅលើការធ្វើការ ឬនិយាយអ្វីមិនម៉ត់ចត់។ ឧទាហរណ៍ : កម្មករម្នាក់បានកាន់ពូថៅឡើងលើជើងទារ ដោយការកាន់មិនជាប់ពូថៅឱ្យបានជាប់ ខណៈនោះស្រាប់តែពូថៅជ្រុះចេញពីដៃហើយធ្លាក់ចុះទៅក្រោមបណ្តើរឱ្យអ្នកថ្មើរជើងម្នាក់ដែលកំពុងដើរត្រូវបាត់បង់ជីវិត។
- **ការធ្វេសប្រហែស** : ការធ្វេសប្រហែស គឺជាការភ្លេចភ្លាំង ការបណ្តែតបណ្តោយ ការមាក់ងាយដោយជនល្មើស។ ឧទាហរណ៍ : គ្រូពេទ្យសម្ភពម្នាក់បានសម្រាលទារកដោយប្រើកន្ត្រៃមិនបានស្ងោរសម្លាប់មេរោគឱ្យបានត្រឹមត្រូវធ្វើឱ្យទារកមានជម្ងឺតេតាណូសស្លាប់។
- **ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ** : សំដៅលើការមិនប្រតិបត្តិតាមកាតព្វកិច្ចដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តតម្រូវឱ្យមាន។ ហេតុចាំបាច់ត្រូវច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលមានមូលដ្ឋានឱ្យចារីបំពេញកាតព្វកិច្ចណាមួយ បើទោះបីជាកាតព្វកិច្ចនោះពុំមានលក្ខណៈជាកាតព្វកិច្ចព្រហ្មទណ្ឌក៏ដោយ។ ឧទាហរណ៍ : អ្នកបើកបររថយន្ត បានបំពានច្បាប់ចរាចរណ៍ ដោយការបើបញ្ច្រាសផ្លូវធ្វើឱ្យប៉ះជាមួយនឹងម៉ូតូមួយដែលបើកស្របទិស ហើយម្ចាស់ម៉ូតូនោះបានដួលបោកក្បាលស្លាប់មួយរំពេច។

---
[57] មាត្រា ៤ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ៣.៣.៣. ការវាយតម្លៃអំពីកំហុសចេតនា និងកំហុសអចេតនា

នៅក្នុងការវាយតម្លៃកំហុសរបស់ចារី ពោលគឺការវាយតម្លៃអំពីធាតុអត្តនោម័តនៃបទល្មើស ចៅក្រមមានភារកិច្ចកំណត់អំពីស្ថានភាពស្មារតីរបស់ចារីនៅពេលប្រព្រឹត្តបទល្មើសទៅតាមរឿងក្ដីនីមួយៗ។ ចារីអាចលើកពីការភាន់ច្រឡំរបស់ខ្លួនចំពោះបទល្មើសដោយចេតនា ឬការប្រុងប្រយ័ត្នជាធម្មតារបស់ខ្លួន ចំពោះបទល្មើសដោយអចេតនា ដើម្បីបញ្ជាក់ពីអវត្តមាននៃធាតុអត្តនោម័តនៃបទល្មើស។ ការភាន់ច្រឡំអាចជាការយល់ច្រឡំរបស់ជនល្មើសអំពីអត្ថន័យគតិយុត្តដែលហៅថា ការភាន់ច្រឡំអំពីច្បាប់(**៣.៣.៣.១.**) និងការភាន់ច្រឡំពីអំពើ ឬពីអង្គហេតុ (**៣.៣.៣.២**)។

#### ៣.៣.៣.១. ការភាន់ច្រឡំអំពីច្បាប់

ការភាន់ច្រឡំពីច្បាប់ គឺជាការភាន់ច្រឡំលើវិធានច្បាប់ណាមួយ មានន័យថាចារីមានការយល់ច្រលំទៅលើអត្ថិភាព ឬអត្ថន័យនៃវិធានច្បាប់ណាមួយ។ ក្នុងករណីនេះចារីយល់ច្រឡំពីចរិតផ្ទុយច្បាប់នៃអំពើរបស់ខ្លួន និយាយម្យ៉ាងទៀតថាចារីពុំបានដឹងថាខ្លួនបានបំពានច្បាប់ព្រហ្មទណ្ឌទេ ក៏ប៉ុន្តែចារីមានបំណងធ្វើអំពើចេតនា។ ការភាន់ច្រឡំពីច្បាប់អាចមានរូបភាពដូចតទៅ **យល់ច្រឡំថាអំពើរបស់ខ្លួនពុំមែនជាបទល្មើស** តែច្បាប់ចាត់ទុកថាអំពើនោះជាបទល្មើស។ តាមគោលការណ៍គ្មាននរណាដែលមិនស្គាល់ ឬមិនយល់ដឹងពីច្បាប់ឡើយ ចារីពុំអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយលើកសំអាងពីការមិនដឹងច្បាប់បានឡើយ។ **យល់ច្រឡំថាអំពើរបស់ខ្លួនជាបទល្មើស** តែតាមការពិតច្បាប់ពុំបានបញ្ញត្តិថាអំពើនោះជាបទល្មើសឡើយ។ ក្នុងករណីនេះគឺពុំមានបញ្ហាអ្វីចោទឡើងចំពោះជនដែលបានប្រព្រឹត្តអំពើនោះទេ។

#### ៣.៣.៣.២. ការភាន់ច្រឡំពីអំពើ ឬ ពីអង្គហេតុ

ការភាន់ច្រឡំពីអំពើ គឺជាការយល់ច្រឡំរបស់បុគ្គលម្នាក់អំពីស្ថានភាពជាក់ស្ដែងរបស់ខ្លួន។ ការភាន់ច្រឡំពីអំពើដែលនាំឱ្យបាត់បង់នូវកំហុសរបស់ចារីត្រូវមានលក្ខខណ្ឌពីរយ៉ាងគឺ: ការភាន់ច្រឡំលើធាតុផ្សំសំខាន់នៃបទល្មើស (**ក**) និងការភាន់ច្រឡំដែលមិនអាចជៀសវាងបាន (**ខ**)។

##### ក. ការភាន់ច្រឡំលើធាតុផ្សំសំខាន់នៃបទល្មើស

ចាត់ទុកថាជាការភាន់ច្រឡំលើធាតុផ្សំសំខាន់នៃបទល្មើស ក្នុងករណីដែលជនម្នាក់បានប្រមូលយករបស់អ្នកដទៃមកទុកដោយភាន់ច្រឡំស្មានថាជារបស់ខ្លួន។ ការភាន់ច្រឡំរបស់អ្នកដទៃដោយគ្មានចេតនានោះមិនចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌទេ ពោលគឺមិនមានធាតុអត្តនោម័តតែម្ដង។ ក៏ប៉ុន្តែការភាន់ច្រឡំពីអំពើ ឬអង្គហេតុខ្លះដែលមិនមែនជាធាតុផ្សំសំខាន់នៃបទល្មើសទេ គឺពុំមែនជាមូលហេតុនាំឱ្យបាត់បង់នូវធាតុអត្តនោម័តឡើយ។ ឧទាហរណ៍ : ឃាតករចង់សម្លាប់ **ក** តែបែរជាចាក់សម្លាប់ **ខ** ទៅវិញដោយសារការភាន់ច្រឡំអ្នកទាំងពីរ។ សម្រាប់ឧទាហរណ៍នេះការភាន់ច្រឡំអត្តសញ្ញាណជនរងគ្រោះមិនមែនជាកត្តាសំខាន់នៃការកំណត់ថាជា

បទល្មើស ឬអត់នោះទេ។ សម្រាប់បទឃាតកម្មចេតនាសម្លាប់មនុស្ស គឺជាធាតុអត្តនោម័តនៃបទល្មើស ចំណែកឯមនុស្សនោះឈ្មោះ **ក** ឬឈ្មោះ **ខ** មិនមែនជាធាតុផ្សំសំខាន់ឡើយ។

**ខ. ការភាន់ច្រឡំដែលមិនអាចជៀសវាងបាន**

ការវាយតម្លៃកំណត់ថា ជាការភាន់ច្រឡំដែលជាមូលហេតុនាំឱ្យបាត់បង់នូវធាតុអត្តនោម័តនៃបទល្មើសណាមួយ ចៅក្រមត្រូវពិនិត្យពិច័យទៅលើបញ្ញាស្មារតីរបស់ចារី ស្ថានភាពចិត្តសាស្ត្រ និងរូបកាយរបស់ចារីនៅពេលដែលចារីបានប្រព្រឹត្តបទល្មើសដើម្បីបញ្ជាក់ថាតើការភាន់ច្រឡំនោះគឺពិតជាកើតឡើងដោយមិនអាចជៀសវាងបាន ឬយ៉ាងណា?

ចំពោះបទល្មើសមួយចំនួន ចារីតែងតែលើកសំអាងអំពើការភាន់ច្រឡំលើអាយុរបស់ជនរងគ្រោះ ឬការយល់ព្រមរបស់ជនរងគ្រោះ ដើម្បីជៀសផុតពីការទទួលខុសត្រូវ។ ការទទួលស្គាល់ដោយចៅក្រមថា ចារីពិតជាមានការភាន់ច្រឡំ ឬមិនមែននោះ គឺអាស្រ័យទៅតាមកត្តាច្រើនយ៉ាង ហើយលុះត្រាតែចៅក្រមមានជំនឿយ៉ាងមុតមាំថាការភាន់ច្រឡំពិតជាកើតមានដោយជៀសវាងមិនបាន ទើបចៅក្រមអាចកំណត់បានថាមិនមានធាតុអត្តនោម័តនៃបទល្មើស។

# ជំពូកទី៤
# អំពីជនល្មើស

# ជំពូកទី៤
# អំពីជនល្មើស

## ៤.១. ប្រភេទនៃជនល្មើស

បទល្មើសមួយមិនអាចកើតឡើងបានឡើយ ប្រសិនបើគ្មានប្រធាននៃបទល្មើសនោះគឺជនល្មើសនេះឯង។ តាមន័យទូទៅ "ជនល្មើស" មកពី :

- ពាក្យថា **ជន** ដែលមានន័យថា មនុស្ស។
- ពាក្យថា **ល្មើស** ដែលមានន័យថាការប្រព្រឹត្តលើសរំលងលើច្បាប់។

ដូច្នេះ ជនល្មើស គឺជាជនទាំងឡាយណាដែលប្រព្រឹត្តលើសរំលង ឬបំពារបំពានលើច្បាប់។ យើងអាចនិយាយជាសាមញ្ញថា ជនល្មើស គឺជាជនដែលបានប្រព្រឹត្តអំពើដោយចេតនា ឬអចេតនាក្តី ដោយសកម្ម ឬអកម្មក្តី ដែលអំពើរបស់ជននោះបណ្តាលឱ្យមានព្យសនកម្មដល់សង្គម ហើយអំពើរបស់ជននោះត្រូវបានកំណត់ទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ។ ក្នុងការប្រព្រឹត្តអំពើបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សង្គម ជនប្រព្រឹត្តអាចមានច្រើនសណ្ឋានដូចជាជនល្មើសដែដល់យើងហៅថា ចារី (៤.១.១.) ជនដែលបានចូលរួមប្រព្រឹត្តដោយផ្ទាល់ដែលហៅថាសហចារី (៤.១.២.) រួមទាំង អ្នកផ្តើមគំនិត (៤.១.៣.) និងអ្នកសមគំនិត (៤.១.៤.)។

### ៤.១.១. ជនល្មើសជាចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃ ឬជនដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសដោយផ្ទាល់ដៃក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់បានចែងទុក។[58] ឧទាហរណ៍ : ជនល្មើសបានយកដំបងវាយសំពងទៅលើជនរងគ្រោះ ជនល្មើសបានស្រែកជេរប្រមាថនូវពាក្យធ្ងន់ៗទៅដល់ជនរងគ្រោះ ជនល្មើសបានចាប់បង្ខំឱ្យជនរងគ្រោះប្រគល់ គ្រឿងអលង្ការឱ្យមកខ្លួនជាដើម។ គួរបញ្ជាក់ផងដែរថា សម្រាប់បទល្មើសមួយចំនួន ប្រធាននៃបទល្មើសត្រូវតែប្រព្រឹត្តអំពើដោយផ្ទាល់ខ្លួន បើមិនដូច្នេះទេមិនអាចចាត់ទុកថាជាចារីបានឡើយ។

### ៤.១.២. ជនល្មើសជាសហចារី

ក្នុងករណីខ្លះទៀត ការប្រព្រឹត្តសកម្មភាពល្មើសណាមួយដោយផ្ទាល់ដែលមានបក្សពួកចូលរួមត្រូវបានគេចាត់ទុកបុគ្គលទាំងអស់នោះថាសហចារី គឺជាជនទាំងឡាយណាដែលបានចូលរួមប្រព្រឹត្តដោយផ្ទាល់ជាមួយនឹងជនណាម្នាក់ ឬច្រើននាក់ផ្សេងទៀត ដោយមានការព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដើម្បីធ្វើសកម្មភាពក្នុងការសម្រេចគោលបំណងអ្វីមួយ។[59] ឧទាហរណ៍ : បុគ្គលបីនាក់បានចូលទៅលួចទ្រព្យសម្បត្តិក្នុងផ្ទះមួយ ដោយ

---

[58] មាត្រា ២៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[59] មាត្រា ២៦ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

អ្នកទាំងបីបាននាំគ្នាសែងទូរទឹកកកមួយគ្រឿងចេញពីផ្ទះនោះ។ ដូចនេះអ្នកទាំងបី គឺជាសហចារីពីព្រោះតែបាន ប្រព្រឹត្តដោយផ្ទាល់នូវអំពើជាសម្ភារៈនៃបទល្មើស (ការដកហូតយកវត្ថុរបស់អ្នកដទៃ)។

**៤.១.៣. អ្នកផ្ដើមគំនិត**

អ្នកផ្ដើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមចំពោះបុគ្គលដែល[60]:

- **ជម្រុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ** តាមការណែនាំ[61] ឬ ការបញ្ជា។ ឧទាហរណ៍ : លោក **គ** បានពន្យល់ **ឃ** ឱ្យទៅឆបោកយកប្រាក់របស់អ្នកនាង **ង** ហើយគម្រោងការរបស់លោក **គ** ក៏បានសម្រេចពិតមែន។ ក្នុងករណីនេះលោក **គ** ជាអ្នកផ្ដើមគំនិតព្រោះលោក **គ** ជាអ្នកណែនាំ **ឃ** ឱ្យប្រព្រឹត្តបទឆបោកអ្នកនាង **ង**។
- **បង្កឱ្យមានបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ** ដោយផ្ដល់អំណោយដោយការសន្យា ឬការគំរាមកំហែង ការញុះញង់ ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬអំណាចរបស់ខ្លួន។

អ្នកផ្ដើមគំនិត នឹងអាចត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង។ បុគ្គលដែលជាអ្នកផ្ដើមគំនិតនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវផ្ដន្ទាទោសដូចគ្នាទៅនឹងចារីដែរ។

**៤.១.៤. អ្នកសមគំនិត**

អ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះដោយផ្ដល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។[62] បុគ្គលដែលជាអ្នកសមគំនិតនឹងត្រូវផ្ដន្ទាទោសបាន លុះត្រាតែបទឧក្រិដ្ឋ ឬបទមជ្ឈិមត្រូវបានសម្រេច ឬបានប៉ុនប៉ង ហើយការផ្ដន្ទាទោសនោះដូចទៅនឹងចារីដែរ។ ការផ្ដល់ជំនួយ ឬការឧបត្ថម្ភ រួមមាន :

- **ការផ្ដល់មធ្យោបាយផ្សេងសម្រាប់ប្រព្រឹត្តបទល្មើស** : ការផ្ដល់មធ្យោបាយប្រព្រឹត្តបទល្មើសមានច្រើនយ៉ាងដូចជា ការផ្ដល់អាវុធ ផ្ដល់ឧបករណ៍ ឬមធ្យោបាយផ្សេងៗទៀតដែលអាចយកទៅប្រើប្រាស់ដើម្បីបំពេញសកម្មភាពល្មើសដោយដឹងយ៉ាងច្បាស់ថាឧបករណ៍ទាំងនោះនឹងត្រូវយកទៅប្រើប្រាស់ក្នុងគោលដៅប្រព្រឹត្តបទល្មើសជាក់ជាមិនខាន។
- **ការផ្ដល់ជំនួយ ឬការឧបត្ថម្ភផ្នែកស្មារតី** : ការលើកទឹកចិត្តឱ្យប្រព្រឹត្តបទល្មើស អាចចាត់ទុកថាជាការផ្ដល់ជំនួយ ឬការឧបត្ថម្ភផ្នែកស្មារតីឱ្យជនល្មើសសម្រេចបាននូវបទល្មើសផងដែរ។

[60] មាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[61] វចនានុក្រមរបស់សម្ដេចសង្ឃរាជ **ជួន ណាត** : ពាក្យ **ណែនាំ** មានន័យថា ប្រាប់ទំនង ប្រាប់ឧបាយ ឱ្យយល់ឱ្យភ្លឺ នាំឱ្យធ្វើដោយពន្យល់បណ្ដើរ។

[62] មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

***បញ្ជាក់ ៖*** ចំពោះអ្នកផ្តើមគំនិត អ្នកសមគំនិតត្រូវកើតចេញពីចេតនាទុច្ចរិតរបស់អ្នកផ្តើមគំនិត និងអ្នកសមគំនិតក្នុងការជម្រុញ ឬបង្កឱ្យបទល្មើសកើតឡើង ក៏ព្រោះតែខ្លួនបានដឹងថាអំពើរបស់ចារី គឺជាបទល្មើស ប៉ុន្តែនៅតែមានបំណងចង់ចូលរួមជាមួយចារីទៀត។ ផ្ទុយទៅវិញប្រសិនបើការចង់ចូលរួមនោះកើតឡើងក្រោយពេលដែលចារីបានប្រព្រឹត្តបទល្មើសចប់សព្វគ្រប់ហើយគឺពុំអាចផ្តន្ទាទោសបានទេ តែអាចផ្តន្ទាទោសតាមទម្រង់នៃបទល្មើសផ្សេងទៀតដូចជា បទលុបបំបាត់វត្ថុតាង បទលាក់បំបាំងសាកសព ជាដើម។

## ៤.២. មូលហេតុនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស

កត្តាដែលជម្រុញឱ្យមានការប្រព្រឹត្តបទល្មើសណាមួយកើតឡើង តែងតែមានកត្តាដែលមានទំនាក់ទំនងហេតុ និងផលដែលបណ្តាលឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តបទល្មើសនោះ។ ទំនាក់ទំនងទាំងអស់នេះកើតឡើងពីការសិក្សាខាងក្រៅនិងខាងក្នុងដែលផ្សំគ្នាបង្កើតឱ្យបុគ្គលមួយមានឆន្ទៈគំនិតល្អទៅជាមានគំនិតអាក្រក់ ដើម្បីសម្រេចលើគោលបំណងរបស់ខ្លួន។ គួរបញ្ជាក់ដែរថាបើពុំមានកត្តាខាងក្រៅជម្រុញបន្ថែមលើបុគ្គលអ្នកប្រព្រឹត្តបទល្មើសនោះទេក៏ពុំអាចបណ្តាលឱ្យមានការប្រព្រឹត្តបទល្មើសកើតឡើងដែរហើយមូលហេតុរួមមាន : មូលហេតុនៅក្នុងមជ្ឈដ្ឋានសង្គម (**៤.២.១.**) និងមូលហេតុផ្សេងទៀត (**៤.២.២.**)។

### ៤.២.១. មូលហេតុនៅក្នុងមជ្ឈដ្ឋានសង្គម

ខណៈពេលដែលសង្គម រមែងវិវត្តន៍ឥទ្ធិពលនៃផ្សេងៗដែលហូរចូលតាមវប្បធម៌បរទេសនានាមានកំណើនកាន់តែច្រើនតាមរយៈសម្ភារៈ បច្ចេកវិជ្ជា និងវិទ្យាសាស្ត្រទំនើបៗ។ កត្តាទាំងនេះវាក៏ជាផ្នែកមួយដែលជម្រុញឱ្យមានការប្រព្រឹត្តបទល្មើសដែរ។ មជ្ឈដ្ឋានសង្គមជាស្ថានភាពសង្គម សកម្មភាពសង្គម ទំនាក់ទំនងសង្គម ដែលជាហេតុនាំឱ្យមានការជះឥទ្ធិពលដល់សតិសម្បជញ្ញៈ និងឥរិយាបថបុគ្គល។ កត្តាសង្គម ជាឥទ្ធិពលមួយដែលអាចបណ្តាលឱ្យមានជាអំពើល្មើស និងអាចជម្រុញឱ្យការប្រព្រឹត្តបទល្មើសពីសំណាក់ជនណាមួយបាន ក្នុងនោះមានឥទ្ធិពលនៃស្ថានភាពសេដ្ឋកិច្ច(**៤.២.១.១.**) ឥទ្ធិពលនៃរបបនយោបាយ(**៤.២.១.២.**) ឥទ្ធិពលនៃសង្គ្រាម(**៤.២.១.៣.**) ឥទ្ធិពលនៃការគ្រប់គ្រងសេដ្ឋកិច្ចសង្គម(**៤.២.១.៤.**) ឥទ្ធិពលនៃវប្បធម៌អប់រំ (**៤.២.១.៥.**) និងឥទ្ធិពលនៃប្រព័ន្ធច្បាប់ (**៤.២.១.៦.**)។

#### ៤.២.១.១. ឥទ្ធិពលនៃស្ថានភាពសេដ្ឋកិច្ច

សេដ្ឋកិច្ច គឺជាផ្នែកមួយដែលមានឥទ្ធិពលយ៉ាងខ្លាំងដែលអាចជះឥទ្ធិពលដល់ទំនាក់ទំនងសង្គមរួមមាននយោបាយ នីតិ សីលធម៌ ការអប់រំ ហើយវាក៏ជាបាតុភូតសង្គមតែងតែងតែវិវឌ្ឍន៍ និងផ្លាស់ប្តូរតាមដំណាក់កាលប្រវត្តិសាស្ត្ររបស់សង្គមមនុស្ស។ សូមបញ្ជាក់បន្ថែមឱ្យកាន់តែច្បាស់ថា ការបម្រែបម្រួលនៃរបបសេដ្ឋកិច្ចផ្តល់ផលនាំឱ្យមានបម្រែបម្រួលនូវទំនាក់ទំនងសង្គមផ្សេងៗដែរ។ កិច្ចការផែនការសេដ្ឋកិច្ចទីផ្សារសេរី ជាសត្យានុម័តនាំមកនូវទំនាស់រវាងសេដ្ឋកិច្ច និងសង្គមព្រោះគោលដៅនៃសេដ្ឋកិច្ចទីផ្សារសេរី គឺស្វែងរកប្រយោជន៍ផ្នែកសេដ្ឋ

កិច្ចដោយពុំមានការធានានូវបញ្ហាសង្គមទូទៅឡើយ។ សេរីភាព ការច្នៃប្រឌិត ភាពរស់រវើក ជាលក្ខណៈពិសេសនៃសេដ្ឋកិច្ចទីផ្សារសេរីហើយវាក៏បង្កើតជាភាពអនាធិបតេយ្យដូចជាការរកស៊ីបោកប្រាស់ ភាពមិនសុច្ចរិត និងការដណ្តើមទុនគ្នាជាដើមក្នុងគោលបំណងដើម្បីទាញប្រយោជន៍របស់បុគ្គលរៀងៗខ្លួន។ កត្តាទាំងនេះជាមូលហេតុ និងលក្ខខណ្ឌដែលបណ្តាលឱ្យមានបទល្មើសសេដ្ឋកិច្ចរួមមានការរត់ពន្ធ ការឆបោក ការរំលោភលើទំនុកចិត្ត ការលក់ផលិតផលនិងទំនិញក្លែងក្លាយ។ លើសពីនេះទៅទៀត កត្តាសេដ្ឋកិច្ចក៏បណ្តាលឱ្យមានបទល្មើសដូចជាចោរកម្ម ឬអំពើល្មើសពាក់ព័ន្ធផ្សេងទៀតដោយសារបញ្ហាទុរគត ភាពក្រីក្របង្ខំឱ្យពួកគេត្រូវប្រព្រឹត្តបទល្មើសដើម្បីបំពេញនូវតម្រូវការរបស់ខ្លួន។

### ៤.២.១.២. ឥទ្ធិពលនៃរបបនយោបាយ

នយោបាយជាកត្តាមួយដែលបានស្តែងឡើង និងប្រមូលផ្តុំនូវកត្តាសេដ្ឋកិច្ចនៃទំនាក់ទំនងគ្នាទៅវិញទៅមករវាងមនុស្សគ្រប់ស្រទាប់វណ្ណៈនៃសកម្មភាពរបស់រដ្ឋ។ កត្តានយោបាយបានផ្សាភ្ជាប់ទៅនឹងផលប្រយោជន៍សេដ្ឋកិច្ចដែលឆ្លុះបញ្ចាំងនូវផលប្រយោជន៍ និងតម្រូវការរីកចម្រើនរបស់សេដ្ឋកិច្ច។ ការផ្លាស់ប្តូររបបនយោបាយនៃសង្គមមួយ អាចបង្កឱ្យមានការសម្រួលដល់មនោគមវិជ្ជានៃការមិនទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនដូចជាការសម្តែងដោយបរិហារកេរ្តិ៍ជេរប្រមាថ ញុះញង់ឱ្យប្រព្រឹត្តបទល្មើសណាមួយ ជាដើម។

### ៤.២.១.៣. ឥទ្ធិពលនៃសង្គ្រាម

សង្គ្រាម ជាបញ្ហាមួយដែលមានការជះជាឥទ្ធិពលអាក្រក់យ៉ាងធ្ងន់ធ្ងរទៅដល់ជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គម ហើយពេលខ្លះវាផ្តល់ផលអាក្រក់ដែលបានបន្សល់ពីសង្គ្រាមអាចជាផលយូរអង្វែងប៉ះពាល់ដល់ជីវភាពរស់នៅប្រាស្រ័យទាក់ទងគ្នាក្នុងសង្គម។ ផលដែលកើតពីក្រោយសង្គ្រាម រមែងតែជាផលមិនល្អដែលបានបំផ្លាញនូវ រចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គម ធនធានធម្មជាតិ ធនធានមនុស្ស។ នៅពេលដែលសេដ្ឋកិច្ចមិនស្ថិតស្ថេរសង្គមមានភាពវឹកវរ និងគ្មានសណ្តាប់ធ្នាប់នោះការឆ្លៀតឱកាសទាញផលប្រយោជន៍ពីសំណាក់បុគ្គលដើម្បីបម្រើសេចក្តីត្រូវការហួសប្រមាណដោយអំពើមិនត្រឹមត្រូវនាំឱ្យមានការប្រព្រឹត្តជាបទល្មើសកើតមានឡើង។

### ៤.២.១.៤. ឥទ្ធិពលនៃការគ្រប់គ្រងសេដ្ឋកិច្ចសង្គម

ទីតាំងភូមិសាស្ត្រ ជាកត្តាមួយដែលមានឥទ្ធិពលលើបញ្ហាបទល្មើស។ បទល្មើសមួយចំនួនអាចកើតមានបានដោយអាស្រ័យលើស្ថានភាពភូមិសាស្ត្រ ហើយរវាងទីក្រុង ជនបទ តំបន់ព្រៃភ្នំ វាលទំនាប ស្ថានភាពនៃបទល្មើសមានលក្ខណៈនឹងការវិវត្តន៍ខុសៗគ្នា។ បទល្មើសមួយចំនួនដែលអាចកើតមានដោយអាស្រ័យទីតាំងភូមិសាស្ត្ររួមមាន ការកាប់ព្រៃឈើខុសច្បាប់ដែលអាចមានឡើងនៅតាមតំបន់ព្រៃភ្នំ បទល្មើសនេសាទត្រីខុសច្បាប់កើតមាននៅតាមតំបន់បឹងទន្លេសាប និងបទល្មើសរំលោភសេពសន្ថវៈកើតមាននៅទីកន្លែងស្ងាត់។

### ៤.២.១.៥. ឥទ្ធិពលនៃវប្បធម៌អប់រំ

ប្រជាជាតិមួយ តែងតែមានមោទនភាពលើវប្បធម៌ និងអរិយធម៌របស់ខ្លួន ទោះបីជាយ៉ាងណាក៏មិនអាចបដិសេធនូវលំហូរនៃវប្បធម៌ផ្សេងដែលកំពុងមានការលាយឡំក្នុងវប្បធម៌ជាតិខ្លួន និងមានភាពល្អប្រសើរជាងនោះឡើយ។[63] ផ្ទុយទៅវិញកត្តាដែលគួរគប្បីធ្វើការពិចារណា គឺលំហូរនៃវប្បធម៌មួយចំនួនជាផលអវិជ្ជមានបង្កជាភាពអសកម្មដល់សង្គមដូចជា ការកាប់សម្លាប់មនុស្ស រំលោភសេពសន្ថវៈ ចោរកម្ម ប្លន់ទ្រង់ទ្រាយធំ ចាប់ជម្រិតទារប្រាក់ ដែលជាសកម្មភាពទាំងនោះពេលខ្លះវាបានកើតចេញពីកម្រងខ្សែភាពយន្តបញ្ចូលនូវសកម្មភាពឃោរឃៅ និងភាពយន្តអាសអាភាសដែលជម្រុញដល់អារម្មណ៍ផ្លូវភេទ។ ដូចនេះគ្រួសារ សាលារៀន និងសង្គមត្រូវរួមគ្នានឹងជួយគ្នាលើការវិស័យអប់រំ។ ភាពអវិជ្ជាសីលធម៌រស់នៅមិនសមរម្យជាផលិតផលដែលកើតចេញពីភាពខ្វះការអប់រំបានបង្កឱ្យមនុស្សមួយចំនួនធ្លាក់ចូលទៅក្នុងការប្រព្រឹត្តល្មើសដែរ។

### ៤.២.១.៦. ឥទ្ធិពលនៃប្រព័ន្ធច្បាប់

ការប្រឆាំង និងការបង្ការបទល្មើសតែងតែផ្សាភ្ជាប់និងទាមទារឱ្យមានការគាំទ្រដោយកម្លាំងបង្ខិតបង្ខំនៃច្បាប់។ ក្នុងប្រទេសដែលជានីតិរដ្ឋរាល់សកម្មភាពរបស់ស្ថាប័នរដ្ឋ សង្គមរួមទាំងពលរដ្ឋផងមានភាពសកម្ម និងឯកភាពគ្នាក្នុងការបំបាត់ចោលនូវបាតុភាពអសកម្មនានាដែលជាមូលដ្ឋាននៃភាពស្ថិតស្ថេរ និងរីកចម្រើននៃបទល្មើស។ ការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខសង្គមដោយច្បាប់ គឺជាស្ថានភាពបន្ទាប់បន្សំសម្រាប់នីតិរដ្ឋហើយជាពិសេសក្នុងវិស័យតស៊ូប្រឆាំងនឹងបង្ការបទល្មើស។ ផ្ទុយទៅវិញភាពចន្លោះប្រហោង ភាពអន់ថយ និងកង្វះខាតច្បាប់មានឥទ្ធិពលធ្វើឱ្យបញ្ហាបទល្មើសឈានឡើងដល់កម្រិតធ្ងន់ធ្ងរសម្រាប់សង្គម។ ការខ្វះចន្លោះភាពអន់ថយ ភាពប្រទាំងប្រទើសគ្នានៃច្បាប់នាំមកនូវភាពច្របូកច្របល់ក្នុងការកំណត់ និងវិនិច្ឆ័យអំពើល្មើសដែលកើតមានឡើងក្នុងសង្គម។ ជាពិសេសនៅពេលប្រទេសមានច្បាប់ទម្លាប់ត្រឹមត្រូវនោះពលរដ្ឋកំណត់បាននូវទិសដៅសកម្មភាពត្រឹមត្រូវរបស់ខ្លួនក្នុងជីវភាពសង្គម។

### ៤.២.២. មូលហេតុផ្សេងៗទៀត

ក្នុងចំណាត់ការប្រឆាំងបទល្មើសនឹងពុំអាចទទួលបានផលប្រយោជន៍ និងលទ្ធផលល្អឡើយ ប្រសិនបើយើងមិនបានយល់ពីបុគ្គលណាជាជនល្មើសដែលបានប្រព្រឹត្តអំពើល្មើស និងគោលបំណងពីក្រោយការប្រព្រឹត្តបទល្មើសនោះ។ ស្ថានភាពជាក់ស្តែងការវិវឌ្ឍនៃស្ថានភាពបទល្មើស ព្យាករណ៍ទិសដៅរីកចម្រើននៃបទល្មើសជាផ្នែកនៃការសិក្សាពីបុគ្គលិកលក្ខណៈរបស់ជនល្មើសដែលលក្ខណៈពិសេសមួយចំនួនរួមមាន ភេទ អាយុស្ថានភាពគ្រួសារ កម្រិតវប្បធម៌ តួនាទីសង្គមរបស់ជនល្មើស។ កត្តាខាងក្រោមនេះជាមូលហេតុមួយចំនួនស្តែងចេញពីអ្នកប្រព្រឹត្តបទល្មើស ឬហៅថាកត្តាខាងក្នុងដែលអាចជះឥទ្ធិពលនៃការប្រព្រឹត្តបទល្មើស។

[63] សៀវភៅ : ឧក្រិដ្ឋវិទ្យា, រៀបរៀងដោយៈ បណ្ឌិត ស៊ិន រិទ្ធ ឆ្នាំ២០១១, ទំព័រ ៣៧

**៤.២.២.១. ចិត្តសាស្ត្រ**

ចិត្តសាស្ត្រ ជាកត្តាមួយនៃការសម្រេចចេញ និងជម្រុញបុគ្គលឱ្យប្រព្រឹត្តនូវអំពើអមនុស្សធម៌ ព្រមទាំងអំពើល្មើសដែលច្បាប់បានកំណត់ចែងនៅក្នុងបញ្ញត្តិច្បាប់។ លក្ខណៈសម្គាល់របស់បុគ្គលក្នុងសង្គម គឺជាសញ្ញាខាងក្រៅចំណែកលក្ខណៈសម្គាល់ផ្នែកចិត្តសាស្ត្រជាផ្នែកខាងក្នុងដើម្បីកំណត់លើជនល្មើស។ ចិត្តសាស្ត្ររបស់ជនល្មើសអាចស្តែងចេញឡើងតាមរយៈបណ្តាសញ្ញាផ្សេងៗចំណុះដោយស្មារតី មនសិការ ដែលជាមូលហេតុយើងអាចកំណត់ពីឆន្ទៈនៃការប្រព្រឹត្តអំពើល្មើសរបស់បុគ្គល។ លក្ខណៈចិត្តសាស្ត្រត្រូវបានកំណត់ដោយសេចក្តីត្រូវការចំណង់ចូលចិត្តលើសកម្មភាពរបស់បុគ្គល។ ជាក់ស្តែងចំណូលចិត្តរបស់ជនល្មើសដែលប្រព្រឹត្តបទល្មើសដោយមូលហេតុផលប្រយោជន៍ទាក់ទងទៅនឹងសេដ្ឋកិច្ចមានភាពខុសគ្នាទៅនឹងសេចក្តីត្រូវការ និងចំណង់ចំណូលចិត្តរបស់ជនល្មើសបំពានលើរូបរាងកាយ សុខភាព កិត្តិយស អាយុជីវិតមនុស្ស។ លក្ខណៈសម្គាល់ផ្សេងទៀតអាចកើតពីការយល់ដឹងអាកប្បកិរិយារបស់បុគ្គលចំពោះតម្លៃនៃសីលធម៌ និងកម្រិតនៃការយល់ដឹងចំពោះតម្លៃសង្គមដូចជាកាតព្វកិច្ចរបស់ពលរដ្ឋចំពោះមាតុភូមិ ពលកម្ម ច្បាប់ ចំពោះគ្រួសារ បុគ្គលនៅជុំវិញខ្លួនយើង និងចំពោះខ្លួនឯងផ្ទាល់។

**៤.២.២.២. ការសិក្សាពីតំណពូជ**

បុគ្គលម្នាក់ៗ មានលក្ខណៈចរិតមាយាទខុសៗគ្នាមនុស្សមួយចំនួនមានចរិតដែលមិនប្រព្រឹត្តអំពើណាដែល ផ្ទុយពីការចែងនៃច្បាប់ក្នុងប្រទេសដែលខ្លួនរស់នៅ ចំណែកបុគ្គលខ្លះទៀតតែងតែប្រព្រឹត្តនូវអំពើណាដែលជាអំពើល្មើសតាមចរិតលក្ខណៈរបស់បុគ្គលម្នាក់នោះ។ កត្តាចរិតមាយាទ អាចជាផ្នែកមួយដែលបណ្តាលពីសរីរៈតពូជដែលជាការសិក្សាមួយចំនួនបានពីការសិក្សាការបញ្ជូនពូជតាមរយៈហ្សែន ហើយបញ្ហាហ្សែនដែលជាធាតុក្រូម៉ូសូមបង្កើតឡើងបានជាខ្សែស្រឡាយគ្រួសារពីឪពុកម្តាយទៅកូនពីមួយជំនាន់ទៅមួយជំនាន់។ ចំពោះការសិក្សានេះ គឺគេសិក្សាដំបូងដោយការរកខ្សែញាតិរបស់គ្រួសារមួយដែលបានប្រព្រឹត្តពីមួយជំនាន់ទៅមួយជំនាន់ដោយគណនាថាមានករណីល្មើសប៉ុន្មានដងដែលបានកើតមានឡើងក្នុងរង្វង់គ្រួសារនោះ និងខ្សែនៃបច្ឆាញាតិដែលជាជនល្មើស។ លើសពីនេះទៀតបើជាកូនភ្លោះការសិក្សាពីក្រូម៉ូសូមតែមួយលើអត្តចរិករបស់ កូនភ្លោះ និងអត្តចរិកលក្ខណៈកូនភ្លោះដែលកើតមានឡើងដោយក្រូម៉ូសូមខុសគ្នា។ ទោះជាយ៉ាងណាក្តីលក្ខណៈនៃតំណពូជទាំងនេះមិនសុទ្ធតែជាមូលហេតុដែលអាចឱ្យបុគ្គលនោះប្រព្រឹត្តបទល្មើសក៏ពិតមែន តែវាក៏ជាផ្នែកមួយដែលក្នុងការពិចារណាលើមូលហេតុនៃការធ្វើអំពើល្មើសរបស់បុគ្គលផងដែរ។

**៤.២.២.៣. ចរិតមាយាទរបស់បុគ្គល**

ឥទ្ធិពលនៃផ្នែកខាងក្នុងរាងកាយរបស់បុគ្គល គឺជាការសិក្សាពីសរីរាង្គខាងក្នុងរបស់បុគ្គលអាចបណ្តាលមកពីប្រវត្តិរបស់ជននោះពីកំណើត ឬក្រោយពេលកើតដែលចូលរួមក្នុងការបង្កើតនូវបុគ្គលភាពរបស់ជនល្មើស។ ប្រវត្តិមុនពេលកើត គឺជាការលូតលាស់មិនប្រក្រតីរបស់មនុស្សដែលបណ្តាលឱ្យមានបញ្ហាខាងផ្នែកស្មារតី ឬ

អាកប្បកិរិយា និងបង្កើតក្រម៉ុសូមខុសប្លែកពីគេ។ ប្រវត្តិនៅពេលកើត គឺជាការសិក្សាពីភាពអាក់អួល នៅពេលសម្រាលកូនដែលជាហេតុផលមួយអាចនាំឱ្យមានបញ្ហាខាងប្រព័ន្ធសរសៃប្រសាទរបស់កូននោះ។ ប្រវត្តិក្រោយពេលកើត គឺជាការសិក្សាពីការឆ្លងជម្ងឺដែលបណ្តាលឱ្យរំខានដល់ប្រព័ន្ធខួរក្បាល ការប្រែប្រួលដែលបណ្តាលមកពីសេពសុរា ឬស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ច្រើនពេក ជាពិសេសនៅពេលពេញវ័យជម្ងឺអាចបង្កឱ្យមានភាពពិការ ឬកាត់បន្ថយសមត្ថភាពធ្វើការនាំឱ្យក្លាយជាជនឥតមានការងារធ្វើ។ កត្តាខាងលើជាកត្តាដែលចូលរួមក្នុងការកាត់បន្ថយនូវតុល្យភាពចិត្តសាស្ត្រ និងធ្វើឱ្យជននោះងាយនឹងទទួលរងឥទ្ធិពលពីកត្តាខាងក្រៅទៀតផងធ្វើឱ្យកើតមាននូវបទល្មើស។

### ៤.២.២.៤. ការវិវត្តន៍ស្ថានភាពជាក់ស្តែង

គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស អាចស្តែងចេញមកខាងក្រៅអាស្រ័យទៅដោយស្ថានភាព ការវិវត្តន៍ស្ថានភាពជាក់ស្តែង ដែលមានភាពពិតប្រាកដដូចជាអវត្តមានគំនិតចង់លួចទ្រព្យសម្បត្តិក្នុងឃ្លាំងអាចប្រព្រឹត្តជាក់ស្តែងនូវគំនិតរបស់ខ្លួនដែលមានពីមុនមក។ បណ្តាការវិវត្តន៍នៃស្ថានភាពជាក់ស្តែងអាច :

- បង្កស្ថានភាពដោយជនល្មើស ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តបទល្មើសដូចជាការក្លែងលិខិតស្នាម ជាដើម។
- ស្ថានភាពដែលកើតឡើង ដោយសកម្មភាពរបស់អ្នកដទៃ ដូចជាការទុកវត្ថុចោលដោយគ្មានការគ្រប់គ្រង ការធ្វេសប្រហែសក្នុងកាតព្វកិច្ចគ្រប់គ្រងទូទៅ។
- ស្ថានភាពបង្កឡើងដោយធម្មជាតិ ដូចជា លំនៅឋាន ឃ្លាំងសម្ភារៈ ខូចខាត ធ្លុះធ្លាយ ដោយសារខ្យល់ព្យុះ ទឹកជំនន់។ល។
- ស្ថានភាពដែលកើតឡើងដោយចៃដន្យ ដូចជាគ្រោះថ្នាក់ចរាចរ ឬជម្ងឺដែលធ្វើឱ្យម្ចាស់ទ្រព្យសន្លប់បាត់ស្មារតី ជាឱកាសល្អសម្រាប់ការលួចយកទ្រព្យនោះ។
- ក្រៅពីនេះការខ្វះចន្លោះក្នុងសកម្មភាពគ្រប់គ្រង និង សកម្មភាពបំពាននៅក្នុងសកម្មភាពសេដ្ឋកិច្ច សង្គម ចាត់តាំង ឬកិច្ចការស្ថិតិ ការពារត្រួតពិនិត្យការដឹកជញ្ជូន ក៏ត្រូវចាត់ទុកជាការវិវត្តន៍នៃស្ថានភាពជាក់ស្តែងផងដែរ។

### ៤.២.២.៥. កត្តាជនរងគ្រោះ

តាមការស្រាវជ្រាវបានបង្ហាញថា ក្នុងបទល្មើសមួយចំនួនដែលបានកើតឡើងពេលខ្លះមូលហេតុ និងលក្ខខណ្ឌក៏ផ្សាភ្ជាប់ទៅនឹងជនរងគ្រោះដូចជា[64]:

[64] សៀវភៅ : ឧក្រិដ្ឋវិទ្យា, រៀបរៀងដោយៈ បណ្ឌិត ស៊ិន រិទ្ធ ឆ្នាំ២០១១, ទំព័រ ៤៣

- លក្ខណៈពិសេសនៃសភាពការណ៍ ស្ថានភាពកម្លាំង ចិត្តសាស្ត្រ ដែលរារាំងនូវការត្រួតពិនិត្យចំពោះមជ្ឈដ្ឋានជុំវិញខ្លួន។
- អាកប្បកិរិយាមិនយកចិត្តទុកដាក់ ធ្វេសប្រហែស ជឿជាក់ចំពោះសន្តិសុខ សុវត្ថិភាពរបស់បុគ្គលខ្លួន កិត្តិយស សេចក្តីថ្លៃថ្នូរ ការការពារទ្រព្យសម្បត្តិខ្លួន។
- ការមិនព្រមផ្តល់ពត៌មានដល់ស្ថាប័នមានសមត្ថកិច្ចអំពីអំពើរំលោភបំពានមកលើខ្លួន។
- អំពើបង្ករឿងហេតុ
- ការចូលរួមក្នុងកិច្ចសន្យា ឬសកម្មភាពមិនស្របច្បាប់ផ្សេងៗ

ជនរងគ្រោះ អាចមានឥទ្ធិពលដល់ការវិវត្តន៍នៃស្ថានភាពនៃឧក្រិដ្ឋកម្ម ដោយសកម្មភាពម្តងម្កាល ឬសកម្មភាពច្រើនដងរបស់ជនរងគ្រោះ ដូចជាធ្លាប់ត្រូវបានចោរលួចទ្រព្យ ឬធ្លាប់រងគ្រោះដោយការវាយតប់ ប៉ុន្តែនៅតែបង្ហាញខ្លួន ឬជឿជាក់ ឬធ្វេសប្រហែសនៅទីកន្លែងដែលខ្លួនធ្លាប់ទទួលរងគ្រោះ។ នៅមុនពេលប្រព្រឹត្តបទល្មើសនោះជនល្មើសតែងតែគិតទៅដល់កាលៈទេសៈផ្សេងៗដូចជា ការតបតរបស់ជនរងគ្រោះ ភេទ អាយុ សុខភាព កម្លាំងពលៈ មុខងារ វិជ្ជាជីវៈ និងលក្ខណៈផ្សេងទៀតនៃបុគ្គលជនរងគ្រោះ។ សរុបមកកត្តាជនរងគ្រោះមានឥទ្ធិពលចំពោះដំណើរការវិវត្តន៍នៃបទល្មើស។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

យោងទៅតាមការសិក្សាពីប្រធានបទនៃ "**ការកំណត់បទល្មើសព្រហ្មទណ្ឌ**" នៃសារណារបស់យើងខ្ញុំរួចមក យើងអាចសង្កេតឃើញថាចំពោះការចាត់ថ្នាក់ និងកំណត់ឱ្យបានច្បាស់លាស់ពីប្រភេទអំពើល្មើសណា ត្រូវចាត់ជាបទល្មើសដែលបានកំណត់នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ពិតជាមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់អ្នកសិក្សាច្បាប់ បុគ្គលទាំងឡាយប្រកបវិជ្ជាជីវៈផ្នែកច្បាប់ និងប្រជាពលរដ្ឋទូទៅក្នុងការប្រកបការងារព្រមទាំងការរស់នៅប្រចាំថ្ងៃក្នុងសង្គមដែលជាប្រទេសនីតិរដ្ឋដូចជាប្រទេសកម្ពុជាជាដើម។ លើសពីនេះទៅទៀតវាបានផ្តល់ជាស្ថេរភាពនយោបាយ និងរក្សាបាននូវសន្តិសុខសុវត្ថិភាពជូនដល់សាធារណៈជនដែលរស់នៅក្នុងសង្គមទាំងមូល។ ផលប្រយោជន៍ទាំងនោះវាមានប្រយោជន៍យ៉ាងខ្លាំងទៅដល់ការរស់នៅប្រចាំថ្ងៃ នឹងបានផ្តល់លទ្ធភាព ក្នុងការកំណត់បានយ៉ាងជាក់លាក់ថា ពេលណាមួយដែលអាចបណ្តាលឱ្យមានបទល្មើសមួយកើតឡើងបាន។ លើសពីនេះទៅទៀត ផលប្រយោជន៍ទាក់ទិននឹងអាជ្ញាយុកាល ផលប្រយោជន៍នៃការអនុវត្តនីតិវិធី រួមទាំងផលប្រយោជន៍ទាក់ទងនឹងការប៉ុនប៉ងដែលផលប្រយោជន៍ទាំងនោះបានផ្តល់ឱ្យយើងកំណត់រយៈពេលមួយឱ្យបានថាបុគ្គលអ្នកប្រព្រឹត្តបទល្មើសនោះអាចការពារផលប្រយោជន៍ ឬបាត់បង់ប្រយោជន៍ទៅតាមពេលវេលាដែលច្បាប់បានកំណត់ចូលជាធរមាន។

យើងសង្កេតឃើញថាបទល្មើសព្រហ្មទណ្ឌកម្ពុជាត្រូវបានកំណត់ជាច្រើនថ្នាក់ទៅតាមស្ថានភាព និងតាមទម្រង់ផ្សេងៗ ក្នុងការកំណត់ចំណាត់ថ្នាក់នៃបទល្មើសនេះវាក៏មានសារៈសំខាន់ដែរក្នុងការកំណត់បទល្មើសព្រហ្មទណ្ឌ។ ចំពោះបទល្មើសដែលកំណត់តាមច្បាប់ត្រូវបានគេបែងចែកចេញជា៣រួមមាន បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ការបែងចែកប្រភេទបទល្មើសកំណត់ដោយច្បាប់នេះដែរគឺស្របទៅតាមស្ថានទម្ងន់បទល្មើសដែលជនល្មើសបានប្រព្រឹត្ត ហើយតាមការអនុវត្តជាក់ស្តែង ក៏ដូចជាការកំណត់ក្នុងវិធានគតិយុត្តិបទល្មើសទាំងនោះអាចត្រូវបានពិន័យជាប្រាក់ និងពន្ធនាគារទៅតាមប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត។ ភាគច្រើននៃការកំណត់នៃបទល្មើសខាងលើគេតែងតែធ្វើការយើងទៅតាមរយៈពេលនៃទោសដែលកំណត់ចែងនៅក្នុងផ្លូវច្បាប់ដូចជា បទល្មើសលហុ មានទទួលទោសពីក្រោមឬស្មើនឹង៦ថ្ងៃ ឬអាចពិន័យជាប្រាក់ បទល្មើសមជ្ឈិម ទទួលទោសចន្លោះពី៦ថ្ងៃទៅ ក្រោមឬស្មើ៥ឆ្នាំ និងបទល្មើសឧក្រិដ្ឋ ត្រូវទទួលរងទោសចន្លោះពី៥ឆ្នាំ ទៅក្រោមឬស្មើ១៥ឆ្នាំ ឬអាចដល់មួយជីវិត។

ខណៈពេលដែលការកំណត់បទល្មើសមានសារៈសំខាន់ក៏ពិតមែន ប៉ុន្តែយើងពិនិត្យឃើញថាការយល់ដឹងរបស់ប្រជាពលរដ្ឋនូវមានកម្រិតលើអ្វីដែលចាត់ទុកជាបទល្មើស និងចំណាត់ថ្នាក់ទាំងនោះ។ យើងនៅតែឃើញមានពីក្តីបារម្ភក្នុងការអនុវត្តពីសំណាក់សមត្ថកិច្ចពាក់ព័ន្ធក្នុងការអន្តរាគមន៍នៅតែមានភាពខ្វះខាត និងធ្វើការអនុវត្តមិនគ្រប់ជ្រុងជ្រោយ។ ការអនុវត្តពេលខ្លះអាចមានភាពលើសលប់ដែលអាចប៉ះពាល់ដល់ជនល្មើសដែល

ពេលខ្លះត្រូវទទួលខុសត្រូវដែលវាខុសពីទំហំនៃអំពើល្មើសដែលខ្លួនបានប្រព្រឹត្តទៅវិញ។ ប្រការទាំងនេះវាក៏បណ្តាលជាក្តីបារម្ភពីការបាត់បង់ប្រយោជន៍របស់ចារីផងដែរ។

បន្ថែមពីនេះផងដែរ ក្នុងការកំណត់ថាវាជាបទល្មើសឱ្យបានលុះត្រាតែអំពើទាំងនោះត្រូវបានមានធាតុផ្សំសំខាន់ៗចំនួន៣គឺ ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ **ទីមួយ** គឺធាតុនីត្យានុកូល ឬហៅម្យ៉ាងទៀតថាធាតុច្បាប់ដែលជាគោលការណ៍មួយយ៉ាងសំខាន់ ក្នុងការកំណត់បទល្មើសដោយស្របតាម មាត្រា ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានចែងថា "**គ្មានបទល្មើស បើគ្មានច្បាប់ចែង**" ប្រការនេះបង្ហាញឱ្យយើងបានឃើញថាបើគ្មាច្បាប់ចែងពីបទល្មើស ឬ អំពើដែលជនមួយប្រព្រឹត្តនោះទេជននោះក៏មិនត្រូវទទួលរងការពិន័យ ឬជាប់ឈ្មោះជាអ្នកបំពានច្បាប់ឡើយ។ **ទីពីរ** គឺជាធាតុសត្យានុម័ត ដែលជាធាតុនៃអំពើប្រព្រឹត្តមួយក្នុងការកំណត់ថាមានបទល្មើសមួយកើតឡើងដោយកំណត់តាមទង្វើ និងសកម្មភាពរបស់អ្នកប្រព្រឹត្តរួមមានកាយវិការ សំដីសំណេរ ឬអាកប្បកិរិយាសាមញ្ញណាមួយផ្សេងទៀត។ **ទីបី**ជាធាតុអត្តនោម័ត ឬធាតុចិត្ត ដែលកំណត់បានថាអ្នកប្រព្រឹត្តអំពើបានប្រព្រឹត្តបទល្មើសពិតប្រាកដមែន។ គួរបញ្ជាក់ថា ស្ថានភាពផ្លូវចិត្តរបស់ជនប្រព្រឹត្តអំពើណាមួយ គឺជាផ្នែកសំខាន់បំផុតក្នុងការកំណត់ថាតើជននោះត្រូវមានទោស ឬគ្មានទោស។ ផ្ទុយទៅវិញប្រសិនបើពុំបានរកឃើញពីធាតុផ្សំទាំងបីក្នុងអំពើល្មើសដែលបានកើតឡើងទេនោះ គេមិនអាចចាត់ទុកជាបទល្មើសដោយខ្វះធាតុផ្សំណាមួយឡើយ។

សរុបជារួមមកវិញ បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ "**ការកំណត់បទល្មើសព្រហ្មទណ្ឌ**" ពិតជាបានផ្តល់នូវតម្លៃនៃចំណេះវិជ្ជាជាច្រើនមកដល់យើងខ្ញុំក៏ដូចជាអ្នកសិក្សាច្បាប់ជំនាន់ក្រោយផ្សេងទៀត ឱ្យបានយល់កាន់តែស៊ីជម្រៅពីភាពសំខាន់នៃការកំណត់ឱ្យបានច្បាស់លាស់លើបទល្មើសព្រហ្មទណ្ឌព្រោះថាវាផ្តល់ជាប្រយោជន៍ក្នុងការបង្ហាញថាជនណាមួយបានប្រព្រឹត្តបទល្មើស ឬជនណាដែលមិនបានប្រព្រឹត្តនូវបទល្មើស។ លើសពីនេះទៅទៀតយើងបានឃើញកាន់តែច្បាស់ថាក្រមព្រហ្មទណ្ឌកម្ពុជាជាច្បាប់មួយដែលមានវិសាលភាពទូលំទូលាយក្នុងការអនុវត្ត និងការបង្កើតបទល្មើសថ្មីៗជាច្រើនចេះតែវិវត្តន៍ទៅមុខដែលសិស្សានុសិស្ស និស្សិត អ្នកស្រាវជ្រាវច្បាប់ត្រូវតែសិក្សាយល់ដឹងពីវាបន្ថែម។ ក្រៅពីនេះបទល្មើសព្រហ្មទណ្ឌផ្តល់ជាសារៈសំខាន់ក្នុងការធានាឱ្យបាននូវសុវត្ថិភាព និងស្ថេរភាពនយោបាយសង្គមឱ្យមានភាពប្រសើរ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីការសិក្សាលើប្រធានបទខាងលើរួចមក យើងខ្ញុំបានឃើញពីចំណុចខ្វះខាតមួយចំនួនដែលត្រូវការកែតម្រូវ និងពង្រឹងបន្ថែមទៀត។ ជាការពិតណាស់ការសិក្សាឱ្យមានភាពស៊ីជម្រៅលើបទល្មើសដែលជនណាមួយដែលបានប្រព្រឹត្តបទល្មើស ដើម្បីធានាកុំឱ្យមានការខូចខាតសណ្ដាប់ធ្នាប់សាធារណៈអំពើប៉ះពាល់ដល់បូរណភាព ទឹកដី សេចក្ដីថ្លៃថ្នូរ សេរីភាព សិទ្ធិរបស់មនុស្ស និងអំពើណាដែលបានប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលតាមការលួច ឆក់ ប្លន់ជាដើម។ ការអនុវត្តនូវបទល្មើសមួយឱ្យបានត្រឹមត្រូវបានវាចាំបាច់ត្រូវដើរទន្ទឹមជាមួយគ្នាការអនុវត្តលើនីតិវិធី និងមានការចូលរួមពីអ្នកអនុវត្តដូចគ្នា។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែបានឃើញពីភាពអនុវត្តផ្ទាល់ ពេលខ្លះអាចនៅមានភាពខ្វះចន្លោះ ទោះជាច្បាប់បានកំណត់ច្បាស់លាស់ពីបទល្មើស ហើយបើមានការអនុវត្តផ្ទាល់មិនមានភាពប្រក្រតី នោះវាមិនអាចធានាបានទ្បើយថាជនដែលបានប្រព្រឹត្តបទល្មើស គឺទទួលទោសទៅតាមទំហំនៃបទល្មើសដែលខ្លួនបានប្រព្រឹត្ត។

ហេតុដូចនេះហើយ យើងគិតថាវាពិតជាចាំបាច់ជាខ្លាំងក្នុងការពង្រឹង បន្ថែមទៅលើការអនុវត្តដោយផ្ទាល់ទៅលើការកំណត់បទល្មើសព្រហ្មទណ្ឌនោះដែលវាត្រូវការចូលរួមពីភាគីច្រើនផ្នែកជាពិសេសសមត្ថកិច្ចពាក់ព័ន្ធក៏ដូចជាប្រជាពលរដ្ឋគ្រប់វណ្ណៈ។ ដើម្បីធានាឱ្យបានការអនុវត្តច្បាប់ដោយត្រឹមត្រូវមន្ត្រីសមត្ថកិច្ចត្រូវធានានូវកាតព្វកិច្ចនៃមុខងារកិច្ចការរបស់ខ្លួននីមួយៗដោយល្អិតល្អន់ដូចជា ចៅក្រមត្រូវធ្វើការកាត់សេចក្ដីដោយមិនត្រូវលំអៀងទៅភាគីណាមួយឡើយដោយមិនត្រូវធ្វើការវិនិច្ឆ័យសេចក្ដីណាមួយ ដោយពុំបានដឹងពីអង្គហេតុច្បាស់លាស់នោះឡើយ។ ការកាត់សេចក្ដីនីមួយៗត្រូវធ្វើឡើងត្រូវធានាថាការជំនុំជម្រះក្ដីដោយយុត្តិធម៌តុលាការមានភាពឯករាជ្យ និងមិនលំអៀង។ លើសពីនេះទៅទៀតយើងគួរតែធ្វើការពង្រឹងលើសមត្ថភាពនៃមន្ត្រីនគរបាលដែលជាអ្នកអនុវត្តតួនាទីក្នុងការឃាត់ខ្លួន ចាប់ខ្លួន ឃុំខ្លួន និងសួរចម្លើយជាដើមត្រូវដោយគោរពតាមតួនាទី និងភារកិច្ចជាមន្ត្រីនគរបាល។

ការពង្រឹងលើ ការអនុវត្តនីតិវិធីនៅគ្រប់ដំណាក់កាលជារឿងមួយចាំបាច់ដូចគ្នាដើម្បីពង្រឹងដល់ការអនុវត្តផ្ទាល់មានប្រសិទ្ធភាព។ ក្រៅពីការពង្រឹងក្នុងវិស័យយុត្តិធម៌តាមភាគីដែលមានសមត្ថកិច្ច យើងក៏ត្រូវគិតគូ ឬបន្ថែមលើការទទួលដឹងពីប្រជាពលរដ្ឋ ព្រោះប្រជាជនទាំងអស់មិនសុទ្ធសឹងទទួលបានចំណេះដឹងផ្នែកច្បាប់បានជិតដល់ឡើង។ ដូច្នេះហើយយើងគួរតែធ្វើការពង្រីក ព្រមទាំងបណ្ដុះបណ្ដាលចំណេះដឹងផ្នែកច្បាប់ជូនដល់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសធ្វើការដាក់បញ្ចូលច្បាប់ចូលក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅក៏ដូចជាការចុះបង្រៀនបន្ថែមតាមសហគមន៍ពីច្បាប់នៃការកំណត់អ្វីទៅជាបទល្មើសនេះតែម្ដង។

សរុបមកវិញប្រទេសដែលមានច្បាប់ល្អតម្រូវឱ្យប្រជាជនគោរពច្បាប់ ដើម្បីជាការចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិ។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

### ១.១. បទដ្ឋានគតិយុត្តអន្តរជាតិ

- អនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ដែលត្រូវបានព្រះរាជាណាចក្រកម្ពុជាផ្តល់សច្ចាប័ន នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៦៥។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ នៃព្រះរាជក្រមលេខ នស/រកម/០៧៩៩/០៨ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៩
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន នៃព្រះរាជក្រមលេខ នស/រកម/០៧០០/០៤ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០០
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ នៃព្រះរាជក្រមលេខ នស/រកម/០៣០៥/០០៦ ចុះថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០០៥
- សន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ នៃព្រះរាជក្រមលេខ នស/រកម/០១១១/០០១ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១១

### ១.២. បទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រម,ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា,ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០,ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២,ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពីកាតព្វកិច្ចយោធា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២០៦/០៣០,ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១១២/០០១,ថ្ងៃទី០២ ខែមករា ឆ្នាំ២០១២
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ព្រហ្មទណ្ឌ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២១៨/០០៣,ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨

## ២. ឯកសារដែលចងក្រងជាសៀវភៅ និងឯកសារសិក្សាផ្សេងៗទៀត

- នីតិព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រ រៀបរៀងដោយសាស្ត្រចារ្យ ហ៊ី សោភា ប្រធានតុលាការខេត្តកណ្ដាល
- សេចក្ដីផ្ដើមនៃការសិក្សានីតិព្រហ្មទណ្ឌ រៀបរៀងដោយសាស្ត្រចារ្យនីតិព្រហ្មទណ្ឌ សេង នាង ឆ្នាំ ២០០៩
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រចារ្យ ហ៊ាង ឡេង ឆ្នាំ២០១០
- ឧក្រិដ្ឋកម្ម រៀបរៀងដោយ បណ្ឌិត ស៊ិន រិទ្ធ ឆ្នាំ២០១១
- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយ លោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២
- នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀង និងវាយអត្ថបទដោយ កៅ សីហា កំពុងសិក្សាថ្នាក់បណ្ឌិតច្បាប់ សាស្ត្រាចារ្យច្បាប់ និងជាមន្ត្រីរាជការនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៣
- បាឋកថា ស្ដីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌ដែលរៀបរៀងដោយ ឯកឧត្តម កើត រិទ្ធិ
- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត គ.ស ១៩៦៧

# ឧបសម្ព័ន្ធ

## បញ្ជីនៃឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១** ៖ សាលក្រម ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ (បទឃាតកម្មគិតទុកជាមុន)
- **ឧបសម្ព័ន្ធទី២** ៖ សាលក្រម ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ (រំលោភអនីតិជន)
- **ឧបសម្ព័ន្ធទី៣** ៖ សាលក្រម ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ (បទហិង្សាដោយចេតនា)
- **ឧបសម្ព័ន្ធទី៤** ៖ សាលក្រម ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ (បទរំលោភលើទំនុកចិត្ត)
- **ឧបសម្ព័ន្ធទី៥** ៖ សាលក្រម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ (បទបរិហារកេរ្តិ៍ជាសាធារណៈ)

# ឧបសម្ព័ន្ធទី១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាមនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

ណុំរឿងព្រហ្មទណ្ឌ
ខ ៥២៤៧
ថ្ងៃទី ៣១-១០-២០១៦
ណុំរឿងជំនុំជម្រះ
ខ ២១២
ថ្ងៃទី ១២-០១-២០១៧
លក្រមព្រហ្មទណ្ឌ
ខ ៩៦ ក្រ៣ "ឆ"
ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក ដោយមានសមាសភាព ៖

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រមប្រឹក្សា**

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ
-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជំរះសំណុំរឿងព្រហ្មទណ្ឌលេខ ៥២៤៧ ចុះថ្ងៃទី ៣១-១០-២០១៦ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរជាងធ្វើពិដាន ទីកន្លែងកំណើត ភូមិអូរអង្រៃ ឃុំអូរអង្រៃ ស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ ទីលំនៅបច្ចុប្បន្ន មិនពិតប្រាកដ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] រស់-ប្រពន្ធឈ្មោះ [redacted] លែងលះ) មានកូន ០២នាក់ ទោសពីមុនគ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦៦៧៧ (ធ) ជ.ឃ.ជ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។ (ម១)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទ(ចាត់តាំង)។

ជាប់ចោទពីបទ: ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦។

បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ: [redacted] មានទីលំនៅ ផ្ទះជួល ផ្លូវ២៧១ ក្រុម២ ភូមិ១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៣០នាទី បន្ទាប់ពីខឹងជនរងគ្រោះ ឈ្មោះ: [redacted] អាយុ២២ឆ្នាំ ដែលជាសង្ស័យថាមានប្រុសច្រើន រួចមកជនសង្ស័យឈ្មោះ: [redacted] បានទៅជួលបន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោ អូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

និងបានណាត់ជនរងគ្រោះឲ្យមកដេកជាមួយ ហើយនៅយប់ថ្ងៃដដែលនោះជនរងគ្រោះក៏បានមកដេកជាមួយជនសង្ស័យ និងបានរួមរក័ក្នាចំនួន ០៣លើក។ បន្ទាប់ពីរួមរក័ក្នារួចមកជនសង្ស័យបានឈ្លោះប្រកែកគ្នាជាមួយជនរងគ្រោះ ហើយជនសង្ស័យក៏បានធ្វើសកម្មភាពសម្លាប់ជនរងគ្រោះតែម្តង។ ក្រោយពេលសម្លាប់ជនរងគ្រោះរួចជនសង្ស័យឈ្មោះ [redacted] ហៅ ពៅ បានដោះយកខ្សែកប្លាកទីន ០១ខ្សែ កងដៃប្លាកទីនចំនួន ០៣កង និងទូរសព្ទ័ដៃម៉ាក iphon ស៊ិចភ្លើស ចំនួន ០១គ្រឿង របស់ជនរងគ្រោះរួចគេចខ្លួនបាត់។ លុះដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ ជនសង្ស័យត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ ក្រោយពេលឃាត់ខ្លួនសមត្ថកិច្ចបានយកទឹកនោមជនសង្ស័យទៅធ្វើតេស្រត៍រកសារធាតុញៀនជាលទ្ធផលបង្ហាញថាមានសារធាតុញៀន ប្រភេទមេតំហ្វេតាមីន។

បានឃើញរបាយការណ៍សំយោគលេខ ១២៣/១៦ រ.ប.ក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៣០៧១ អ.យ.ត ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ របស់តំណាងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាដំណោះស្រាយលេខ ៥៥៨៨ (ធ) ជ.ជ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃ សាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ: [redacted]ានឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទ័ណាត់ជាមួយឈ្មោះ: [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៤ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់លេខ២០C ដល់ម៉ោង ៥និង៣០នាទី ឈ្មោ[redacted] បានមកដល់ បន្ទាប់មកពួកខ្ញុំបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួច ម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើកាជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទ័ឆ្លើយឆ្លងនៅចំពោះមុខខ្លួន ដោយពេលនោះខ្លួនខឹងពេកក៏បានសង្គ្រប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែក ដោះខ្សែដៃ និងយកទូរសព្ទ័របស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង បន្ទាប់មកដើរចេញពីផ្ទះសំណាក់ហើយហៅម៉ូតូឌុបជិះចេញទៅបាត់តែម្តង (នៅពេលខ្លួនដើរចេញពីផ្ទះសំណាក់មិនបានពាក់ម៉ាសទេ)។ នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១១ថ្ងៃត្រង់ ក៏មានសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនសាកសួរ ហើយខ្លួនក៏ឆ្លើយសារភាពតាមសកម្មភាពដែលខ្ញុំបានប្រព្រឹត្តតែម្តង។ មូលហេតុដែលខ្លួនសម្លាប់ហើយយកខ្សែក និងកងដៃរបស់ជនរងគ្រោះ ព្រោះវាជារបស់ដែលខ្លួនបានធ្វើឲ្យនាង ចំណែកឯទូរសព្ទ័គឺជារបស់គាត់។ ខ្លួនមិនមែនណាត់ជួបគាត់ដើម្បីប្លន់យកទ្រព្យសម្បត្តិរបស់គាត់នោះទេ។ ខ្លួននិងជនរងគ្រោះស្គាល់គ្នា និងទាក់ទងគ្នាជាសង្សាប្រហែល១ឆ្នាំ ហើយពួកខ្លួនធ្លាប់ណាត់ជួបគ្នាជារឿយៗ ទើបតែលើកចុងក្រោយនេះគាត់ទើបធ្វើឲ្យខ្លួនដឹងថាគាត់មានសង្សាច្រើន ថែមទាំងទូរសព្ទ័និយាយជាមួយប្រុសផ្សេងមុខខ្លួនទៀត ខ្លួនខឹងពេកដោយទ្រាំនឹងគាត់បញ្ឈឺមិនបានក៏សម្លាប់គាត់តែម្តង។ នៅមុនពេលសម្លាប់ជនរងគ្រោះខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ តែមុនពេលឃាត់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀន

ពិតមែន។ ខ្លួនសំណូមពរសុំឲ្យតុលាការសម្រេចទៅតាមច្បាប់ ដោយខ្លួនដឹងអំពីកំហុសរបស់ខ្លួន ហើយស្តាយចំពោះទង្វើរបស់ខ្លួនដែលបានប្រព្រឹត្តលើជនរងគ្រោះ។

-តាមអំណានចម្លើយដើមបណ្ដឹងឈ្មោ[redacted]នឆ្លើយថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៦និង៣០នាទី ប្អូនស្រីខ្លួន[redacted]ភេទស្រី អាយុ២២ឆ្នាំ មុខរបរបុគ្គលិកខារ៉ាអូខេ ហេងហេង(DN) ស្នាក់នៅផ្ទះជួលលេខ១៦C-១៦D ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានស្រុកកំណើតនៅ ភូមិស្វាយពល ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង (ត្រូវជាប្អូនបង្កើតរបស់ខ្លួន) បានចេញពីផ្ទះដោយប្រាប់អ្នកនៅជាមួយថាទៅកក់សក់ រួចក៏ចេញបាត់ទៅ លុះដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៨និង៣០នាទី ខ្លួនបានទទួលដំណឹងតាមរយៈមិត្តភក្រ្តប្អូនស្រីថា ប្អូនស្រីខ្លួនឈ្មោះ[redacted]ត្រូវបានគេសម្លាប់ ឥឡូវសពតម្កល់នៅវត្តស្ទឹងមានជ័យ។ បានដំណឹងនេះខ្លួនក៏ធ្វើដំណើរទៅកាន់វត្តស្ទឹងមានជ័យកន្លែងតម្កល់សពឃើញថា សពនោះពិតជាប្អូនស្រីបង្កើតខ្លួនឈ្មោះ [redacted] ពិតប្រាកដមែន។ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃរបស់ប្អូនស្រីខ្លួនជាប់នឹងខ្លួនមានកងដៃផ្លាកទីនចំនួន ០៣កង , ខ្សែកផ្លាកទីន ០១ខ្សែ ទម្ងន់ប្រហែល ០២ជី , ទូរសព្ទដៃម៉ាក iphon ស៊ិចភ្លើស ០១គ្រឿង ពណ៌ទឹកមាស ប្រើស៊ីមស្មាតលេខ ០៨៧ ៦៧ ៤៧ ៤៧។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា ៖ ខ្លួនបានស្គាល់ឈ្[redacted] រយៈពេលមួយឆ្នាំហើយ ពេលធ្វើការជាមួយគាត់នៅខារ៉ាអូរេ ហេងហេង(២) ម្តុំក្បែរប៉ុស្តិ៍នគរបាលផ្សារដេប៉ូ៣។ នៅឆ្នាំ២០១៥ ប្រហែលក្នុងខែ៧ ឆ្នាំ២០១៦ ខ្លួនក៏ឈប់ធ្វើការនៅហេងហេង(២) ហើយទៅធ្វើការនៅឌីយ៉ាម៉ង់វិញ(ម្តុំអូរបែកក្អម)។ [redacted]គាត់មានសង្សារម្នាក់ឈ្មោ[redacted] ភេទប្រុស អាយុប្រហែល ២០ឆ្នាំជាង មានមុខរបរអ្វីពុំដឹងទេ លេខទូរសព្ទមិនស្គាល់ ខ្លួនជួបគាត់នៅផ្ទះជួលរបស់បង [redacted] ជិតខារ៉ាអូខេហេងហេង(២) នាងជួបឈ្មោះ[redacted] ប្រហែល ៣ដង ជួបម្តងៗ មួយភ្លែតៗប៉ុណ្ណោះ ឈ្មោះ[redacted]មានកំពស់ប្រហែល ១,៧០ម៉ែត្រ សក់ស្លូត ច្រមុះស្រួច សម្បុរខ្មៅស្រអែម។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៩និង០០នាទី ខ្លួនបានទូរសព្ទទៅបង[redacted]ខ ០៨៧ ៦៧ ៤៧ ៤៧ ដើម្បីខ្ចីលុយគាត់ ២០$ តែគាត់ថាកំពុងនៅផ្ទះសំណាក់ ចាំគាត់តេមកវិញ ពេលនោះគឺខ្លួនកំពុងនៅខារ៉ាអូខេឌីយ៉ាម៉ង់ អូរបែកក្អម ខ្លួនចាំរហូតដល់ម៉ោង ១០យប់ ថ្ងៃដដែលក៏ទូរសព្ទទៅម្តងទៀតតែពុំចូល រហូតដល់ម៉ោង ១១យប់ តេច្រើនលើកនៅតែពុំចូល។ លុះព្រឹកឡើងថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ១៩និង ០០នាទីឈ្មោ[redacted]ភេទស្រី នៅខារ៉ាអូខេជាមួយខ្លួនប្រាប់ថាបង[redacted]ប់ហើយ ត្រូវគេសម្លាប់ លុះព្រឹកឡើងថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ ខ្លួនក៏ទៅធ្វើបុណ្យគា[redacted]នៅខេត្តព្រៃវែងជាមួយមិត្តភក្រ្ត ០៤នាក់ទៀត។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]នឆ្លើយថា ៖ ខ្លួន និងឈ្មោះ[redacted]បានជួលផ្ទះលេខ១៦C រស់នៅជា[redacted]ក់ រយៈពេលប្រហែល ០៤ខែហើយ ប៉ុន្តែខ្លួនស្គាល់គ្នារយៈពេល ៣ឆ្នាំហើយ។ អ្នកនៅជាមួយគ្នានោះ ១-ខ្លួនឈ្[redacted]ហៅ លីហ្សា ទូរសព្ទលេខ ០៩៦ ៥៨០ ១២១ ៧ , ២-ឈ្មោះ[redacted]ភេទស្រី អាយុ១៩ឆ្នាំ ទូរសព្ទលេខ ០៩៦ ៥០៨ ៨៨៧ ៦ , ៣-[redacted]ភេទស្រី អាយុប្រហែល ២០ឆ្នាំ ទូរសព្ទលេខ ០១៦ ៥០ ៥៣ ៣៨ , ៤-ឈ្មោ[redacted]ភេទស្រី អាយុប្រហែល ២៨ឆ្នាំ ទូរសព្ទមិនស្គាល់ ទើបមកនៅបានប្រហែល ១អាទិត្យ។ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល ២៣រំលង និង ០០នាទី បានមកលេងក្នុងហាងមួយសន្ទុះហើយចេញទៅវិញ លុះម៉ោង ១និង៣០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ពេលខ្លួនចេញពីកន្លែងធ្វើការមកផ្ទះ ស្រាប់តែឃើ[redacted]ក្នុងផ្ទះជាមួយឈ្មោ[redacted]ក្មួយប្រុសម្នាក់អាយុ ៧ឆ្នាំ និងសង្សា(សព)ឈ្មោះ[redacted] ហើយខ្លួនក៏ចូលដេកនឹងនៅជាមួយគ្នារហូតដល់ម៉ោ១៥ និង៩០នាទី ថ្ងៃខែដដែលទើបខ្លួនចេញទៅកន្លែងធ្វើសក់មុនគេ។ ពេលដែលខ្លួនកំពុងនៅក្នុងបន្ទប់ជាមួយ[redacted]ប់ពី ម៉ោង ១២h

ដល់ម៉ោង១៥h ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ទូរស[redacted] មានមនុស្សប្រុសតេមកប្រហែល ២-៣ដង លើកទី១ ណាត់[redacted]ជួបគ្នាញ៉ាំអីនៅវត្តតំបូកខ្ពស់ តែខ្លួនប្រាប់ [redacted] ថាកុំទៅអីឆ្ងាយណាស់ លើកទី២ តេមកតែ[redacted]អត់លើកទូរសព្ទ លើកទី៣ តេមកម្តងទៀតប្រាប់ទៅជួបពូកម៉ាក់នៅម្តុំក្តាន់ពីរសិនបន្តចទៀតថាជួបគ្នា ដល់ពេល[redacted]ទៅជួបអ្នកដែលទូរសព្ទមកនោះមិនដឹងម៉ោងប៉ុន្មានទេ ព្រោះខ្លួនចេញទៅកន្លែងកក់សក់បាត់ហើយ។ អ្នកដែលតេមកទូរសព្ទ [redacted]ះខ្លួនអត់ស្គាល់លេខទេ ឮតែសម្លេងនិយាយឆ្លើយឆ្លងគឺមនុស្សប្រុស។ លុះម៉ោង២៤ និង០០នាទី ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ដោយបាត់[redacted]មិនមកធ្វើការ ខ្លួនបានទូរសព្ទទៅលេខ ០៨៧ ៦៧ ៨៧ ៨៧ តែតេមិនចូល រហូតដល់ម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ក៏តេមិនចូល លុះម៉ោង១៦ និង០០នាទី ថ្ងៃខែដដែលខ្លួនបើកហ្វេសបុកមើលស្រាប់តែឃើញរូបភាព[redacted]ាប់ដែលគេបង្ហោះ ទើបមានការភ្ញាក់ផ្អើលប្រាប់មិត្តភក្ត្រិតៗគ្នា។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]នឆ្លើយថា ៖ ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់អូយេស លេខ១៧ ផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះ អាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ពេលបង់ប្រាក់រួចភ្ញៀវបានទិញភេសជ្ជៈចំនួន ៤បដ (គោជល់១ដប ទឹកសណ្តែក១ដប បាកាស១កំប៉ុង ទឹកហ្សេនយ៉ា១ដប) ហើយបានឡើងបន្ទប់លេខ២០C ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលាម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោះ[redacted]ភេទស្រី អយុ២៨ឆ្នាំ អាយុ២៨ឆ្នាំ ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែ។ ពេលភ្ញៀវប្រុសចុះចេញពីបន្ទប់លេខ២០C នោះមិនដឹងចុះតាំងពីពេលណាទេ។ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១៦និង៥០នាទី ខ្លួនកំពុងតែប្រចាំការនៅកន្លែងទទួលភ្ញៀវ ក៏មានភ្ញៀវដែលនៅបន្ទប់លេខ២០C ជាន់ទី៣ ក្នុងផ្ទះសំណាក់អូយេស ភេទប្រុស (ជនសង្ស័យ)បានទូរសព្ទលើតុ ហើយខ្លួនបានលើក ហើយប្រាប់ខ្លួនថាទិញកាតទូរសព្ទស្មាត ១$១ ចំនួន២សន្លឹក ពេលនោះខ្លួនក៏បានវាយអាយកូមទៅឈ្មោះ[redacted] ភេទប្រុស អាយុ២០ឆ្នាំ ឲ្យមកយកកាតទៅឲ្យភ្ញៀវខាងលើ។ ចំពោះកាតទូរសព្ទ ស្មាត នៃ គឺខ្លួនត្រវបានថៅកែទុកឲ្យលក់ ៥០$ មានប្រភេទស្មាត ១ដុល្លា សែលខាត និងមេតហ្វូន គឺគាត់ទុកឲ្យលក់(ចុចពីម៉ាស៊ីនទុកឲ្យលក់) ហើយលក់អស់ទើបចុចឲ្យខ្ញុំទៀត រីឯលុយគឺគិតតាមកាត ហើយទូទាត់ឲ្យថៅកែ។

-តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]បានឆ្លើយថា ៖ កាលពីថ្ងៃទី២៥ ខែ១០ ឆ្នាំ២០១៦ វេលាម៉ោង១១និង៣០នាទី ខ្លួនបានឡើងមកឆែកបន្ទប់លេខ២០C ជាន់ទី៣ ពេលឡើងមកដល់មុខបន្ទប់ឃើញបន្ទប់ជាប់សោរ រួចបានគោះបន្ទប់ហៅភ្ញៀវខាងក្នុងចំនួន៣ដង តែមិនឃើញភ្ញៀវឆ្លើយតបក៏បានចុះទៅខាងក្រោមយកកូនសោរមកចាក់បន្ទប់លេខ២០C បើកទ្វារ ខ្លួនក៏សួរថាបងថែមម៉ោងឬអត់តែភ្ញៀវដេកដណ្តប់ភួយមិនឆ្លើយ ខ្លួនក៏បានយកដៃទៅអង្រួនជើង ស្រាប់តែឃើញជើងភ្ញៀវត្រជាក់ ពេលនោះនាងខ្ញុំក៏បានហៅអ្នកខាងក្រោមឲ្យជួយពិនិត្យមើល ឃើញភ្ញៀវកំពុងតែដេកស្ងៀមមិនកំរើក រួចប្រាប់ទៅម្ចាស់ផ្ទះហើយរាយការណ៍ទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលស្រះចកតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]ានឆ្លើយថា ៖ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦និង៤០នាទី ខ្លួនកំពុងឈរមុខផ្ទះសំណាក់ឃើញមនុស្សម្នាក់ ភេទប្រុស អាយុ

ប្រហែល៣២ឆ្នាំ ស្លៀកពាក់ស៊ីវិល ពាក់អាវសាច់ក្រណាត់ដៃវែងពណ៌ក្រហមក្រឡាការ៉ូ ខោពណ៌ខ្មៅជើងវែង ដើរចូលមកក្នុងផ្ទះសំណាក់ម្នាក់ឯងមកជួប[redacted]ប្រុស (អ្នកគ្រប់គ្រង) កេបន្ទប់ដេក រួចមនុស្សប្រុសនោះដើរឡើងមកបន្ទប់ជាន់ទី៣បាត់រហូត ដល់ម៉ោងប្រហែល ១៧និង០០នាទី ខ្លួនឃើញនារីនោះមកពីទិសខាងកើតផ្ទះសំណាក់ ហើយឈប់មុខផ្ទះសំណាក់ រួចរាប់លុយឲ្យអ្នកឌុបចេញទៅបាត់ ចំណែកនារីនោះក៏ដើរឡើងមកជាន់ទី៣បាត់រហូតដល់ម៉ោង ១៩និង០០នាទី ខ្លួនដល់ម៉ោង ត្រូវឈ្មោ[redacted]ល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្លួនយាមវិញវេលាម៉ោងប្រហែល១១និង០០នាទី ឈ្មោ[redacted]ទស្រី(អ្នកបោសសម្អាតបន្ទប់) បានប្រាប់ខ្លួនថា បន្ទប់លេខ២០ ជាន់ទី៣ ដែលភ្ញៀវចូលដេកនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ (មានស្រីម្នាក់ និងប្រុសម្នាក់) បិទទ្វារហៅមិនមានការឆ្លើយតបក៏ឲ្យខ្ញុំជួយមើល ពេលខ្លួនមើលជាមួយស្រីនាង ឃើញមនុស្សស្រីដេកស្តូកលើពូក ខ្លួនក៏ទៅប្រាប់ម្ចាស់ផ្ទះតែម្តង។តមការចំណាំរបស់ខ្លួនកន្លងមកខ្លួនមិនដែលឃើញបុរសនោះ និងនារីរងគ្រោះចេញចូលផ្ទះសំណាក់នេះទេ(ជាម៉ូយថ្មី)។ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោងប្រហែល១៦ជាងជិតម៉ោង១៧ ពេលមនុស្សប្រុសនោះទិញកាតបញ្ចូលទឹកប្រាក់ចំនួន១$ ចំនួនពីរសន្លឹកពី[redacted]តែខ្លួនមិនដឹងថាមនុស្សប្រុសនោះចេញពីផ្ទះសំណាក់ពេលណាទេ។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]បានឆ្លើយថា ៖ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ខ្ញុំកំពុងប្រកបអាជីវកម្ម ទិញ-លក់គ្រឿងអលង្ការ យីហោ ចាបមាស តូបលេខ៥០A ផ្សារសាមគ្គី ស្ថិតក្នុងសង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ម៉ោងប្រហែល ៩និង០០នាទីព្រឹក មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានយកគ្រឿងអលង្ការផ្លាកទីន មានកងដៃចំនួន៣កង និងខ្សែកតូចមួយខ្សែយកមកលក់ ពេលនោះខ្លួនសួរថារបស់ទាំងហ្នឹងទិញពីកន្លែងណាមក ជននោះក៏យកវិក័យបត្រដែលមានយីហោតូបរបស់ខ្លួនមកបង្ហាញ ដោយឃើញវិក័យបត្រនេះខ្ញុំក៏យល់ព្រមទិញហើយបានយកថ្លឹង ដោយកងដៃ៣កងទម្ងន់បួនជីមួយហ៊ុន ចំណែកខ្សែកមានទម្ងន់មួយជីបួនហ៊ុនប៊ីលី សរុបទាំងអស់ខ្ញុំទិញក្នុងតម្លៃទីផ្សារសរុប ៣៦៥$។ លុះដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ ម៉ោង៩ និង០០នាទីព្រឹក ក្រោយពីខ្លួនដឹងថារបស់ខាងលើពាក់ពន្ធ័ជាវត្ថុតាងនៅអំពើល្មើសច្បាប់ខ្លួនបានសហការណ៍ប្រគល់ឲ្យសមត្ថកិច្ចដើម្បីទុកជាវត្ថុតាង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយថា ៖ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១១ថ្ងៃត្រង់ខ្លួនកំពុងនៅហាងលក់ទូរសព្ទ័របស់ឈ្មោះ[redacted]ពេលនោះក៏មានមនុស្សចំនួន ០២នាក់ ជិះម៉ូតូម៉ាកហុងដា១២៥ មិនដឹងសេរី បានយកទូរស[redacted]ម៉ាក iphon ស៊ិចភ្លើសពណ៌ទឹកមាសមកលក់ឲ្យខ្លួនក្នុងតម្លៃ ២១០$ ដោយទូរសព្ទ័នោះមានឆ្នាំងសាក និងកាសគ្រប់គ្រាន់ ទើបនាងខ្ញុំហ៊ានទិញ ក្រោយពីទិញបានហើយខ្លួនក៏បានដាក់ក្នុងទូរសព្ទ័លក់ធម្មតា។ សូមបញ្ជាក់ថាទូរសព្ទ័នេះខ្ញុំពុំបានដឹងថាពួកគាត់បានមកពីណាទេ។ ទើបមកដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង១៧និង៣០នាទី ក៏ឃើញមានសមត្ថកិច្ចនាំជនដែលលក់ទូរសព្ទ័ឲ្យខ្លួននោះមកហាងខ្លួន ហើយសមត្ថកិច្ចបានអញ្ជើញខ្លួនមកសួរ ទើបខ្ញុំដឹងថាទូរសព្ទ័នោះពាក់ពន្ធ័នឹងអំពើឃាតុកម្ម ហើយខ្លួនសូមប្រគល់ទូរសព្ទ័នេះជូនសមត្ថកិច្ចវិញដោយស្មគ្រ័ចិត្តមិនតវ៉ាអ្វីទេ។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]បានឆ្លើយថា ៖ ចំពោះចម្លើយរបស់ខ្លួនដែលបានឆ្លើយនៅសមត្ថកិច្ច កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ គឺខ្លួនទទួលស្គាល់ដោយមិនមានការកែប្រែទេ។ ខ្លួន និងជនរងគ្រោះ គឺធ្លាប់ទាក់ទងគ្នាជាសង្សាររយៈពេលប្រហែល ០១ឆ្នាំហើយ រីឯជនល្មើសវិញខ្លួនមិនដែលស្គាល់នោះទេ ហើយជនរងគ្រោះក៏មិនដែលប្រាប់ពីព័ត៌មានទាក់ទងនឹងជនល្មើសឲ្យខ្លួនដឹងដែរ។ ថ្ងៃដែលខ្លួនជួបនឹងជនរងគ្រោះចុងក្រោយបំផុត គឺនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ០៤រសៀល ជិតម៉ោង៥រសៀល គឺខ្លួនទៅយកម្ហូបសុវត្ថិភាពនៅផ្ទះរបស់គាត់ ជួលហើយក៏បែកគ្នាទៅ។ ថ្ងៃដែលខ្លួនដឹងថាជនរងគ្រោះស្លាប់គឺនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦

ម៉ោងប្រហែល ៥រសៀល តាមរយៈមិត្តភក្តិស្រីរបស់គាត់ឈ្មោះ [redacted] ាអ្នកទូរសព្ទ័ប្រាប់ខ្លួន។ ខ្លួនបានដឹងតែប៉ុណ្ណឹង ចំពោះរឿងអ្វីផ្សេងទៀតខ្លួនមិនបានដឹងទេ។

**សេចក្តីសន្និដ្ឋានផ្តើមសុំរបស់តំណាងអយ្យការ**

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងតាមការសួរដេញដោលឃើញថា នៅចំណុច ផ្ទះលេខ២០C ជាន់ទី៣ ផ្ទះសំណាក់យ៉ហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ គឺពិតជាកើតមានអំពើ ឃាតកម្មគិតទុកជាមុន បង្កដោយជនជាប់ចោទឈ្មោះ [redacted] ន ដែលអំពើនេះបានគិតទុកជាមុន អំពើនេះត្រូវបានបញ្ញត្តិ និងផ្តន្ទាទោសតាមមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ ជនជាប់ចោទក៏បានសារភាពដែរថា ខ្លួនបានប្រើប្រាស់គ្រឿងញៀនផងដែរ ដូចនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៣៥៨៣ អ.យ.ត ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ទុកជាបានការ និងសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ**

-លោក [redacted] ជាមេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ៖ យោងតាមការពិភាក្សាដេញដោលឃើញថា កូនក្តីខ្លួនពុំមានទោសពីមុន មានកំរិតវប្បធម៌ទាប និងជាជាងពិដាន ដោយកូនក្តីខ្លួនមានការខឹងជនរងគ្រោះដោយកំហឹង ពុំមែនមានគំពេងសម្លាប់ឡើយ គឺកូនក្តីខ្លួនខឹងភ្លាមក៏ស្ទុះសង្កត់ជនរងគ្រោះ និងច្របាច់ក ក៏បណ្តាលឲ្យជនរងគ្រោះស្លាប់ភ្លាមៗ គឺពុំមានគំពេងពីមុនទេ។ ពេលជនរងគ្រោះស្លាប់ហើយ កូនក្តីខ្លួនក៏ដោះយកសម្ភារៈ ព្រោះសម្ភារៈទាំងនោះជារបស់ដែលកូនក្តីខ្លួនទិញឲ្យជនរងគ្រោះ ហើយកូនក្តីខ្លួនយកទៅគីដោះដូរដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដូចនេះខ្លួនសំណូមពរសុំឲ្យក្រុមប្រឹក្សាមេត្តាប្តូរបទចោទប្រកាន់ពីមាត្រា ២០០ ទៅជាមាត្រា ២២៤ វិញ គឺហិង្សាដោយមានមរណៈភាពជនរងគ្រោះ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] ៣ ៣៧ ៖ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោស។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបាន ពិនិត្យ ពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ មានករណី ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កើតឡើងនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យ៉ហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ជានីតិជន និងជាជនមានសមត្ថភាពអាចទទួលខុសត្រូវពីបទព្រហ្មទណ្ឌបាន។

-តាមការអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] បានបញ្ជាក់ថា ៖ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ខ្លួនបានទូរសព្ទណាត់ជាមួយឈ្មោះ [redacted] ភេទស្រី អាយុ២២ឆ្នាំ ទៅជួបគ្នានៅម៉ោង ៤ឬ៥ល្ងាច នៅផ្ទះសំណាក់អូយេស ហើយខ្លួនបានទៅដល់ផ្ទះសំណាក់មុន ខ្លួនក៏បានជួលបន្ទប់ផ្ទះសំណាក់ លេខ២០C ដល់ម៉ោង ៥និង៣០នាទី [redacted] បានមកដល់ បន្ទាប់មកពួកខ្លួនបានរួមភេទគ្នា ក្រោយពីរួមភេទគ្នារួចម៉ោងប្រហែល ៩និង៣០នាទី ពួកខ្លួនបាននិយាយគ្នា ដោយខ្លួនថាឲ្យគាត់ឈប់ធ្វើការជានារីខារ៉ាអូខេតែគាត់មិនព្រមឈប់ទេ ហើយថែមទាំងបានបង្អួតខ្លួនថាគាត់មានមិត្តប្រុសច្រើនទៀតផង ដោយបាននិយាយទូរសព្ទឆ្លើយឆ្លងនៅចំពោះមុខខ្លួន ពេលនោះខ្លួនខឹងពេកក៏បានសង្កប់ពីលើជនរងគ្រោះ ហើយអង្គុយពីលើគាត់ដោយដៃម្ខាងខ្ទប់មាត់ និងដៃម្ខាងទៀតច្របាច់កគាត់រហូតដល់ស្លាប់តែម្តង ដោយខ្លាចគាត់មិនទាន់ស្លាប់ខ្លួនបានយកកន្សែងពោះគោចុកមាត់គាត់ថែមទៀត។ ក្រោយពីបានធ្វើសកម្មភាពសម្លាប់គាត់រួច ខ្លួនបានដោះខ្សែកដោះខ្សែដៃ និងយកទូរសព្ទរបស់ជនរងគ្រោះហើយចាក់សោទ្វារបន្ទប់ពីក្នុង ហើយនៅមុនពេលខ្លួនសម្លាប់ជនរងគ្រោះ ខ្លួនបានព្រមានថាឲ្យឈប់ទាក់ទងជាមួយប្រុសទៀត បើនៅតែធ្វើបែបនេះខ្លួននឹងសម្លាប់ចោល ដែលការសារភាពនេះតុលាការអាចជឿបាន ព្រោះវាស៊ីសង្វាក់នឹងចម្លើយរបស់សាក្សីឈ្មោះ [redacted] ខ្លួនជាអ្នកទទួលភ្ញៀវចូលផ្ទះសំណាក់ អូយ៉េស ហើយកាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៦និង៤៥នាទី មានភ្ញៀវប្រុសម្នាក់មិនស្គាល់ឈ្មោះអាយុប្រហែល៣២ឆ្នាំ ប្រើលេខទូរសព្ទ ០៩៦ ៨៣ ៧៦ ៧៥ បានដើរមកជួលបន្ទប់ដេកមួយយប់តម្លៃ ៨$ បន្ទប់លេខ២០C ជាន់ទី៣ ដោយនិយាយថាបើឃើញសង្សារខ្ញុំមកឲ្យឡើងទៅបន្ទប់លេខ២០C រហូតមកដល់វេលាម៉ោងប្រហែល ១៧និង០៥នាទី ភ្ញៀវស្រីម្នាក់មកដល់ក៏សួររកបន្ទប់លេខ២០C ខ្លួនក៏ប្រាប់ឲ្យឡើងមកជាន់ទី៣ជាប់នឹងជណ្តើរឡើង។ លុះដល់វេលា ម៉ោង១១ និង៣០នាទី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ស្រាប់តែមានភាពឆោឡោចេញពីឈ្មោ[redacted] ជាអ្នកសំអាតបន្ទប់ថាមានភ្ញៀវដេកស្លាប់នៅក្នុងបន្ទប់លេខ២០C ជាន់ទី៣ ខ្លួនក៏បានឡើងមកមើលឃើញភ្ញៀវស្រីដេកដណ្តប់ភួយស្លាប់នៅលើគ្រែមែន។

-អំពើដែលជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] ដែលបានប្រើប្រាស់ថ្នាំញៀន នៅមុនពេលសម្លាប់ជនរងគ្រោះ និងគិតថានឹងសម្លាប់ជនរងគ្រោះបើសិនជនរងគ្រោះមានប្រុសក្បត់ខ្លួន ហើយនៅថ្ងៃកើតហេតុជនជាប់ចោទក៏បានច្របាច់កជនរងគ្រោះរហូតស្លាប់ និងដោះយកសម្ភារៈជនរងគ្រោះនោះ ត្រូវចាត់ជាអំពើ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យករួមមានកៅស៊ូចងសក់ , ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១និងស្បែកជើងផ្ទាត់ចំនួន០១គូ , ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ត្រូវរហែកមានប្រឡាក់ឈាម,អាវយឺតមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវីងចំនួន០២សន្លឹក,សំបកបាកាស់០១ M150 ១ដប គោជល់០១ដបនិង អាវដៃវែងនិងឆ្នូតក្រហាមមួយ គឺជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស និងជាភស្តុតាងបញ្ជាក់ពីអំពើល្មើសរបស់ជនជាប់ចោទ គប្បីពុលាការរឹបអូសតាមច្បាប់ ។ ចំនែកឯវត្ថុចាប់យក រួមមានកាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១ , ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងឌីសចំនួន០១ , កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ [redacted] ឯវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក

គឺជាសម្ភារៈរបស់ជនរងគ្រោះនិងជាសម្ភារៈរបស់ជនជាប់ចោទ ហើយពុំមានពាក់ព័ន្ធនឹងអំពើល្មើសឡើយ ដូចនេះតុលាការគប្បីប្រគល់ឲ្យម្ចាស់ដើមវិញ។

-មានពិរុទ្ធភាពលើឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ដើមបណ្តឹងឈ្មោះ [redacted] ពុំបានចូលមកតាំងខ្លួនជាដើមបណ្តឹង និងប្តឹងទាមទារសំណងជម្ងឺចិត្តឡើយ ដូចនេះតុលាការគប្បីទុកសិទ្ធិជូនដើមបណ្តឹងទាមទារសំណងពេលក្រោយតាមច្បាប់។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ហៅ ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារសរុបកំណត់ មួយជីវិត ពីបទៈ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់លេខ២០C ជាន់ទី៣ ផ្ទះសំណាក់យីហោអូយេស ស្ថិតនៅផ្លូវលេខ១៣២ ក្រុម២០ ភូមិ២ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០០ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌគឺ:

-កៅស៊ូចងសក់ពណ៌ខ្មៅចំនួន០៣ , កែវជ័រចំនួន០១ និងស្បែកជើងផ្ទាត់ចំនួន០១គូ។

-ម៉ាសមុខ , កន្សែងពោះគោពណ៌សចំនួន០២ , កន្សែង០១ ត្រូវហែកមានប្រឡាក់ឈាម។

-អាវរ៉ូបមួយពណ៌ស ឆ្នូតពណ៌ខ្មៅ០១ , អាវទ្រនាប់០១ , ខោលីអូ០១ និងកាតទូរស័ព្ទវៃចំនួន០២សន្លឹក។

-សំបកបាកាស់០១ M150 ១ដប និងគោជល់០១ដប , អាវដៃវែងនិងឆ្នូតក្រហមមួយ។

៣-វត្ថុចាប់យកត្រូវប្រគល់ឲ្យម្ចាស់ដើមវិញគឺ:

-កាបូបស្ពាយពណ៌ខ្មៅ និងកាស់ទូរស័ព្ទដៃពណ៌ស ចំនួន០១។

- ទូរស័ព្ទដៃ០១គ្រឿងម៉ាកណូគា ពណ៌លឿងនិងខីសចំនួន០១។

-កាបូបដៃចំនួន០១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានឈ្មោះ [redacted] និងវិក័យប័ត្រទិញលក់មាសចំនួន០៣សន្លឹក។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៦-០៣-២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហៅ ពៅ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ [redacted] ងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨-០៣-២០១៧ ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| លខា និងត្រ [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខ [redacted] | ហត្ថលេខានិងត្រា [redacted] |

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

បានចំលងចេញត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៧

ក្រឡាបញ្ជី

[redacted]

# ឧបសម្ព័ន្ធទី២

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

កណ្ដាល ថ្ងៃទី០៩ ខែ៦ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

ព្រំ-ចាន់ថា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ: ០៤០

ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១

សាលក្រមលេខ: ០២ (ផ.វ.ន)

ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាលនាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ វេលាម៉ោង ៩ ព្រឹកដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ០៤០ អក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ:

ឈ្មោះ: [redacted]ទប្រុស អាយុ៥៨ ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិថ្មី ឃុំថ្មី ស្រុកកំពង់រោ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅភូមិព្រៃកណ្ដា ឃុំព្រៃកគាគូរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឪពុកឈ្មោះ: [redacted]) ម្ដាយឈ្មោះ: [redacted]ពន្ធឈ្មោះ: [redacted] (ı) មានកូនចំនួន ០២ នាក់។

ត្រូវបានជាប់ចោទពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រៃកណ្ដា ឃុំព្រៃកគាគូរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្ដន្ទាទោសតាមមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

មេធាវីការពារជនជាប់ចោទឈ្មោះ: [redacted]

<u>**ដំណើរអង្គហេតុមានដូចតទៅ**</u>

កាលពីខែសីហា ឆ្នាំ២០១០ វេលាម៉ោង ១៧ និង០០នាទី ជនរងគ្រោះឈ្មោះ[redacted] ភេទស្រី អាយុ ៩ឆ្នាំ កំពុងដេកនៅលើផ្ទះ ស្ថិតនៅភូមិល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជាមួយជនត្រូវចោទឈ្មោះ[redacted]បន្ទាប់មកឈ្មោះ[redacted]បានមកដេកទ្រាបពីលើជនរងគ្រោះឈ្មោះ[redacted] ហើយបានគំរាមនាងមិនឲ្យស្រែក និងបានចាប់ស្រាតខោរបស់នាង និងស្រាតខោខ្លួន នៅពេលនោះឈ្មោះ[redacted]បានបញ្ចេញប្រដាប់ភេទរបស់ខ្លួនបំរុងដាក់បញ្ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ តែចៃដន្យឈ្មោះ[redacted]និងឈ្មោះ[redacted] បានឡើងមកទាន់ ភ្លាមនោះឈ្មោះ[redacted]ក៏រត់គេចខ្លួនតែម្ដង។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦១៧ ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣។

បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ៖ ៨១៩ ចុះថ្ងៃទី០២ ខែ កញ្ញា ឆ្នាំ២០១៣។

បានឃើញ ចំណាត់ការចាត់តាំងចៅក្រមជំនុំជម្រះ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៣។

**នាពេលសវនាការ**

-អំណានចម្លើយជនរងគ្រោះឈ្មោះ[redacted] បានឆ្លើយថា៖ ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រែកល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តែម្នាក់ឯង ចំណែកម៉ីងខ្លួនឈ្មោះ[redacted] គាត់កំពុងដេរខោអាវនៅក្រោមផ្ទះ បន្ទាប់មកឈ្មោះ[redacted]ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងទ្រាបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងបេកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះម៉ីងខ្លួន ឈ្មោះ[redacted]និងយាយឈ្មោះ[redacted]បានឡើងមកទាន់ ហើយឈ្មោះ[redacted]នរត់ចុះទៅដីតែម្ដង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ[redacted]បានឆ្លើយថា៖ នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ២០១០ នៅវេលាម៉ោង ១៦ និង០០នាទី ចៅស្រីខ្លួនឈ្មោះ[redacted]នទៅដេកលេងនៅលើផ្ទះរបស់ឈ្មោះ[redacted] រីឯខ្លួនបានដើរទៅផ្ទះឈ្មោះ[redacted]នៅខាងត្បូងផ្ទះឈ្មោះ[redacted] ប្រហែលជា ១៥០ ម៉ែត្រ លុះដល់ម៉ោង ១៧ និង០០នាទី ខ្លួនក៏បានដើរទៅផ្ទះឈ្មោះ[redacted]ញ ហើយខ្លួន និងកូនស្រីខ្លួនឈ្មោះ[redacted]ត្រូវជាប្រពន្ធឈ្មោះ[redacted]បាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ[redacted] កំពុងតែដេកផ្កាប់មុខទ្រាបពីលើចៅស្រីខ្លួនដោយដៃ[redacted] ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ[redacted]បញ្ចេញមកក្រៅរៀបនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។ ពេលនោះខ្លួនមិនបានចាំថា ឈ្មោះ[redacted] ស្លៀកខោ ឬក្រមាទេ លុះឃើញពូកខ្លួន ឈ្មោះ[redacted]ក៏ស្ទុះក្រោកចុះមកដីឯតទឹកទៅ រីឯចៅខ្លួនដេកថ្ងាមោនសភាពស្លេកស្លាំង មិនហ៊ានស្រែកឡើយ ចាប់តាំងពីពេលនោះមកឈ្មោះ[redacted]ឧស្សាហ៍រករឿងឈ្លោះប្រកែកជាមួយខ្លួនណាស់ ព្រមកាន់កាំបិតគំរាមរកកាប់ខ្លួនទៀតផង

ដោយខ្លួនខ្លាចឈ្មោ[redacted]សម្លាប់ គឺមិនហ៊ានប្តឹងទៅប៉ុស្តិ៍នគរបាលនោះទេ គឺខ្លួនគ្រាន់តែនិយាយប្រាប់ឈ្មោះ ហេង ជាតំណាងឲ្យក្រុមហ៊ុនអភិវឌ្ឍន៍ពោធិប្អូនប៉ុណ្ណោះ។

-អំណានចម្លើយសាក្សីឈ្មោះ[redacted]នឆ្លើយថា៖ កាលពីថ្ងៃទីមិនចាំអំឡុងខែឧសភា ឆ្នាំ ២០១០ វេលាម៉ោងប្រហែល ២ រសៀល ខ្លួនរួមជាមួយក្មួយស្រីខ្លួនឈ្មោ[redacted]យុ ១០ ឆ្នាំ បាននាំគ្នាលាងចានបាយនៅក្រោមផ្ទះ ឯប្តីខ្លួនឈ្មោះ[redacted]ងូតទឹករួចគាត់ឡើងទៅលើផ្ទះស្លៀកពាក់ខោអាវ បំរុងទៅភូមិខាងលើ ចំណែកម្តាយខ្លួនឈ្មោះ[redacted]ាត់បានដើរទៅលេងនៅផ្ទះរបស់ឈ្មោ[redacted]ាត់ហើយ បានបន្តិចក្មួយស្រីខ្លួនឈ្មោះ[redacted]ឡើងទៅលើផ្ទះខ្លួនមិនដឹងថាឡើងទៅធ្វើអ្វីទេ បន្ទាប់មកខ្លួនក៏បានយកចានទៅទុក ពេលទៅដល់លើផ្ទះឃើញប្តីខ្លួនអង្គុយនៅក្បែរទូរ ស្លៀកខោជើងវែង ពណ៌ប្រផេះ ពាក់អាវដៃវែង ពណ៌ស ឯក្មួយស្រីខ្លួនឈ្មោះ[redacted]ង្គុយជិតចង្ក្រាន ចំងាយពីប្តីខ្លួនប្រហែលជាងមួយម៉ែត្រ ឯកូនប្រុសខ្លួនឈ្មោះ[redacted]ាយុ ៥ឆ្នាំ កំពង់ដេកនៅខាងមុខទូរ ចំណែកម្តាយខ្លួនគាត់មិនទាន់ត្រឡប់មកដល់ផ្ទះវិញទេ។ ភ្លាមនោះប្តីខ្លួនក៏បាននាំក្មួយស្រីខ្លួនទៅងូតទឹក នៅពេលងូតទឹកឲ្យក្មួយស្រីខ្លួនរួច ប្តីខ្លួនក៏ដើរទៅភូមិបាត់ទៅ រហូតដល់ម៉ោង ៥ ល្ងាច ទើបម្តាយខ្លួនមកដល់ផ្ទះខ្លួនវិញ នៅពេលខ្លួនឡើងទៅលើផ្ទះនោះ ម្តាយខ្លួនគាត់មិនទាន់មកដល់ គាត់មិនបានឡើងទៅលើផ្ទះជាមួយខ្លួនទេ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការៈ ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី តំណាងអយ្យការយល់ឃើញថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោ[redacted]តជាបានជាបានស្រាតខោជនរងគ្រោះ និងយកប្រដាប់ភេទបម្រុងដាក់បញ្ចូលប្រដាប់ភេទជនរងគ្រោះ ប៉ុន្តែឈ្មោះ[redacted]នមកទាន់ ជនជាប់ចោទក៏បានបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកជាជាបទ ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលចែងឱ្យផ្តន្ទាទោសតាមមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ៖ ៦១៧ដកសព ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ទុកជាបានការទាំងស្រុង។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទៈ ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ និងអំណានចម្លើយសាក្សី ខ្លួនជាមេធាវីការពារឱ្យជនជាប់ចោទ ស្នើសុំដល់តុលាការមេត្តាពិចារណា និងសម្រេចតាមច្បាប់។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

១.ជនរងគ្រោះឈ្មោះ [redacted]នឆ្លើយថា ខ្លួនមិនបានចាំថ្ងៃខែឆ្នាំទេ វេលាម៉ោងប្រហែល ៥ ល្ងាច ខ្លួនកំពុងអង្គុយលើផ្ទះនៅក្នុងភូមិព្រែកល្វា ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល តែម្នាក់ឯង បន្ទាប់មកឈ្មោះ[redacted]ត្រូវជាពូរបស់ខ្លួន បានដើរមករកខ្លួន ហើយគាត់បានឡើងទ្រាបពីលើខ្លួន ព្រមទាំងនិយាយថា បើខ្លួនហ៊ានស្រែក គាត់នឹងយកកាំបិតមកចាក់សម្លាប់ខ្លួន រួចគាត់បានស្រាតខោខ្លួនឯង និងស្រាតខោរបស់ខ្លួន គាត់បានយកប្រដាប់ភេទគាត់ដាក់លើប្រដាប់ភេទរបស់ខ្លួន ភ្លាមនោះ[redacted]និងបងរបស់ឈ្[redacted]ះឡើងមកទាន់ ហើយឈ្មោះ[redacted]បានរត់ចុះទៅពីផ្ទះ ដែលមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយសាក្សីឈ្មោះ [redacted]

២.សាក្សីឈ្មោះ[redacted]នឆ្លើយថា នៅថ្ងៃមិនចាំខែសីហា ក្នុងឆ្នាំ២០១០ នៅម៉ោង ១៧ និង០០នាទី ខ្លួន និងកូនស្រីខ្លួនឈ្មោះ ព[redacted]ាប្រពន្ធឈ្មោះ[redacted]បាននាំគ្នាដើរឡើងទៅលើផ្ទះ ដោយខ្លួនដើរពីក្រោយកូនស្រីខ្លួន ពេលឡើងទៅដល់ស្រាប់តែឃើញ ឈ្មោះ[redacted] កំពុងតែដេកផ្កាប់មុខទ្រាបពីលើចៅស្រីខ្លួនដោយ[redacted]ម្ខាងចាប់ទាញស្រាតខោចៅស្រីរបស់ខ្លួនមកដល់ត្រឹមភ្លៅ ឯប្រដាប់ភេទរបស់ឈ្មោះ[redacted]ពេញមកក្រៅរៀបនឹងដាក់ចូលទៅក្នុងប្រដាប់ភេទចៅស្រីរបស់ខ្លួនទៅហើយ។

៣.តាមចម្លើយជនរងគ្រោះឈ្មោះ[redacted]ងសាក្សីឈ្មោះ[redacted]បញ្ជាក់បានថា កាលពីខែសីហា ឆ្នាំ២០១០ ជនជាប់ចោទឈ្មោះ[redacted]ពិតជាបានធ្វើសកម្មភាពចាប់ស្រាតខោជនរងគ្រោះ និងខោខ្លួនក្នុងគោលបំណងដាក់លិង្គរបស់ខ្លួន ចូលក្នុងប្រដាប់ភេទរបស់ជនរងគ្រោះ ប៉ុន្តែចៃដន្យឈ្[redacted]បានមកទាន់ ធ្វើឱ្យជនជាប់ចោទបញ្ឈប់សកម្មភាពរបស់ខ្លួន ដែលអំពើនេះច្បាប់ចាត់ទុកថាជាបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ**។

៤.អំពើរបស់ជនជាប់ចោទឈ្មោះ[redacted]ប្រព្រឹត្តលើជនរងគ្រោះជាអនីតិជនដែលមានអាយុទើបតែ ០៩ ឆ្នាំ ដែលជាបុគ្គលមានភាពទន់ខ្សោយពិសេស ដោយមូលហេតុនៃអាយុបុគ្គល ហេតុដូច្នេះតុលាការធ្វើការកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ** មកបទៈ **ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ)** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។

៥.អំពើរបស់ជនត្រូវចោទឈ្មោះ[redacted]ប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់របៀបរៀបរយសង្គម កិត្តិយស និងរូបកាយរបស់ជនរងគ្រោះ ហើយជនត្រូវចោទជានីតិជន មានស្មារតីយល់ដឹងគ្រប់គ្រាន់ចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត និងក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។

៦ មានភស្តុតាង និងកាតុព្យុំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្វា ឃុំព្រៃកតាក្វេ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពី ខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ។

៧.ជនជាប់ចោទឈ្មោះ [redacted] ប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ បានរត់គេចខ្លួន ហើយអំពើរបស់ជនជាប់ចោទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារលើសពីមួយឆ្នាំ គប្បីសាលាដំបូងខេត្តកណ្តាល ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ [redacted] ទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេចសេចក្តី

១/កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ឆ្នាំ ពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ មកបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ។

២/ផ្តន្ទាទោស: ឈ្មោះ [redacted] ទប្រុស អាយុ ៥៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន ៧ ឆ្នាំ (ប្រាំពីរឆ្នាំ) ពីបទ៖ ប៉ុនប៉ងរំលោភសេពសន្ថវៈ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) ប្រព្រឹត្តនៅភូមិព្រៃកល្វា ឃុំព្រៃកតាក្វេ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីខែសីហា ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧ និងមាត្រា២៤១ នៃក្រមព្រហ្មទណ្ឌ ។

៣/ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ទប្រុស អាយុ ៥៤ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ កំបាំងមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមក្រុមប្រឹក្សា**
ហត្ថលេខា និងត្រា
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

**បានឃើញ**
**ចៅក្រម**
[redacted]

...ចម្លងត្រឹមត្រូវតាមច្បាប់ដើម
កណ្តាល, ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤
**ក្រឡាបញ្ជីសវនាការ**
[redacted]

# ឧបសម្ព័ន្ធទី៣

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខ ១០៣៤
ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦
-សំណុំរឿងជំនុំជម្រះលេខ ២៥៧៨
ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦
-សាលក្រមលេខ ៣៦០៦-ថ-
ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៦

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ដោយមានសមាសភាពជំនុំជម្រះ

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**<u>ដើម្បីជំនុំជម្រះ</u>**

សំណុំរឿងព្រហ្មទណ្ឌលេខ ១០៣៤ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះលេខ៥AE ផ្លូវលេខ១៣៤ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]- ម្តាយឈ្មោះ[redacted]- នៅលីវ ជានីតិជន។ ទោសពីមុន គ្មាន។

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ១៤១៣-ឈ-ដឃដ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦។

២.ឈ្មោះ[redacted]ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅផ្ទះលេខ៧២Eo ផ្លូវលេខ២១៥ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]- ម្តាយឈ្មោ[redacted] នៅលីវ ជានីតិជន។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)។

លោក[redacted] លោក [redacted]ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

៣.ឈ្មោះ [redacted]ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើតនៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ សាសនា ព្រះពុទ្ធ ទីលំនៅផ្ទះលេខ២៤៦ ផ្លូវលេខ២៣៨ ក្រុមទី៧២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]- ម្តាយឈ្មោះ[redacted]- នៅលីវ ជានីតិជន។ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)។

លោកស្រី[redacted]ជាមេធាវីការពារសិទ្ធិជនជាប់ចោទ។

ជាប់ចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះជួល ផ្លូវលេខ៣២០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ២៩Eo ផ្លូវលេខ១៦៣ សង្កាត់អូរឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

លោក អឿន សុខា ជាមេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី។

<u>អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ</u>

-កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១១និង១៥នាទី នៅចំណុចមុខផ្ទះលេខ ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយកាំបិតកែច្នៃ ដែលបានបង្កឡើងដោយជនជាប់ចោទជាច្រើននាក់ ជិះម៉ូតូចំនួនបួនគ្រឿងមានឈ្មោះ [redacted] ជាអ្នកកាន់កាំបិតកែច្នៃមួយ ឈ្មោះ [redacted] ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ១៧ឆ្នាំ(គេចខ្លួន), ឈ្មោះ [redacted] ភេទប្រុស (គេចខ្លួន), ឈ្មោះ [redacted] ភេទប្រុស (គេចខ្លួន), ឈ្មោះ [redacted] ភេទប្រុស (គេចខ្លួន), ឈ្មោះ [redacted] ភេទប្រុស (គេចខ្លួន) និងគូកនពីរនាក់ទៀត មិនស្គាល់ឈ្មោះ បានធ្វើសកម្មភាពកាប់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] និងឈ្មោះ [redacted] បណ្ដាលឲ្យមានរបួសទាំងពីរនាក់ជាទម្ងន់ ហើយក៏នាំគ្នាគេចខ្លួនអស់។ លុះមកដល់ថ្ងៃ[redacted] ខែមីនា ឆ្នាំ២០១៦ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងឃាត់ខ្លួនជនជាប់ចោទបានជាបន្តបន្ទាប់។

-បានឃើញរបាយការណ៍សំយោគលេខ ៥២របក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៩០៥អ.យ.ប ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៥៣២-ឈ-ដ.ជ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្ញុំបាទដឹងពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស។ ខ្ញុំបាទឆ្លើយបញ្ជាក់នាពេលសវនាការជូនលោកស្រីចៅក្រមជំនុំជម្រះថា កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១៦និង១៥នាទី ខ្ញុំបាទ និងមិត្តភក្តិចំនួន០៩នាក់ទៀតមានឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូ០៤គ្រឿងចេញពីកន្លែងលេង Snooker នៅជិតសាលាជ័យថាវី បំណងទៅលេងអ៊ិនធើណិតនៅអារីហ្សូននៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា ពេលនាំគ្នាជិះទៅដល់មុខកន្លែងលេងអ៊ិនធើណិតនោះ ក៏ជួបជាមួយបក្ខពួកដែលជិះម៉ូតូពីរគ្រឿងជា(បក្ខប្រឆាំងឈ្មោះ ញា) នៅអារីណាហ្សូន។ ពេលនោះខ្ញុំនៅមុខអារីណាហ្សូន ពួកគេវាយគ្នានៅក្រោយ ហើយស្រាប់តែ

ឈ្មោ[redacted]ស្រែកថា ជួយផងៗ ខ្ញុំក៏ចុះពីលើម៉ូតូកាប់លើបក្ខខាងនោះខ្ញុំមានសាំម៉ូរ៉ៃមួយ ចំណែកបក្ខពួកគេមានសាំម៉ូរ៉ៃពីរ។ ខ្ញុំកាប់ត្រូវគេម្នាក់ត្រង់ក្បាល និងដៃ ហើយក៏ឡើងម៉ូតូជិះជាមួយឈ្មោះ[redacted]រត់តែម្តង។ ខ្ញុំសុំរក្សាចម្លើយកន្លងមកគ្រប់ដំណាក់កាល។ ខ្ញុំធ្លាប់មានជម្លោះជាមួយបក្ខខាងជនរងគ្រោះម្តងនៅកោះពេជ្រម្តងហើយ ដោយពួកគេដេញកាប់ខ្ញុំតែខ្ញុំជិះម៉ូតូគេចខ្លួនផុត លុះនៅថ្ងៃកើតហេតុក៏ជួបពួកជនរងគ្រោះដោយចៃដន្យ ក៏ពួកគ្នាខ្ញុំវ៉ៃគ្នាស្រែកឱ្យខ្ញុំជួយ ខ្ញុំក៏កាប់ទៅលើជនរងគ្រោះប៉ុណ្ណោះ ខ្ញុំកាប់លើជនរងគ្រោះ តែពុំដឹងថាត្រូវប៉ុន្មានកាំបិតទេ។ ពេលជិះម៉ូតូឈ្មោះ[redacted]ជាអ្នកឌុប វាពុំបានដឹងថាខ្ញុំមានលាក់កាំបិតទេ ហើយខ្ញុំបបួលឈ្មោះ [redacted] ទៅលេងហ្គេមនៅអាវីណាហ្សុន ពុំបានបបួលថាទៅកាប់គ្នានោះទេ។

-ជនរងគ្រោះឈ្មោះ [redacted]បានឆ្លើយថា៖ នៅថ្ងៃកើតហេតុខ្ញុំកំពុងតែជិះម៉ូតូពីរគ្រឿងមានគ្នា០៥នាក់ទៅលេងហ្គេមនៅអាវីណាហ្សុន ក្រោយពីលេងហើយខ្ញុំចេញមកវិញ ក៏ឃើញពួកខាងជនល្មើសវាយខ្ញុំដោយដៃសិន ពួកវាមានគ្នាច្រើនណាស់ដោយជិះម៉ូតូ០៥គ្រឿងដោយមួយម៉ូតូជិះពីរនាក់ទៅបីនាក់ ពេលដែលវ៉ៃខ្ញុំនោះខ្ញុំរត់ចូលក្នុង តែប្អូនខ្ញុំឈ្មោះ[redacted]ត្រូវគេវ៉ៃនៅក្រៅ ខ្ញុំក៏ចេញទៅជួយ ស្រាប់តែជនល្មើសដែលនៅចំពោះមុខខ្ញុំនេះកាប់ខ្ញុំមួយកាំបិតត្រូវដៃ ហើយគាត់ថែមមួយកាំបិតទៀតពីក្រោយចំក្បាលខ្ញុំទៀត បណ្តាលឱ្យខ្ញុំសន្លប់តែម្តង។ បក្ខពួកគាត់មានគ្នាច្រើន និងមានកាំបិតគ្រប់ដៃ ព្រោះថាបើគាត់មានកាំបិតតែមួយដើមមិនអាចកាប់ខ្ញុំដល់ទៅ៥កាំបិតឡើយ។ ខ្ញុំពុំដែលមានទំនាស់ជាមួយខាងជនជាប់ចោទ គឺគេមកវ៉ៃខ្ញុំតែម្តង ខ្ញុំពុំបានតដៃទេ។ ខ្ញុំទាមទារ ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក។ បក្ខពួកខ្ញុំពុំមានកាំបិតទេ ពេលគេកាប់ខ្ញុំត្រូវមួយកាំបិត ខ្ញុំចង់សន្លប់ហើយ ថែមខ្ញុំមួយកាំបិតទៀត។ ខ្ញុំពុំដែលមានទំនាស់ជាមួយគេឡើយ។ សព្វថ្ងៃដៃខ្ញុំមិនដូចដើមឡើយ ធ្វើការមិនកើត។ ខ្ញុំចាំមុខបក្ខពួកគាត់កាប់ខ្ញុំបាន ដែលជនជាប់ចោទនោះចំពោះមុខខ្ញុំនេះ។ ខ្ញុំទៅលេងហ្គេមពីម៉ោង៩ព្រឹកដល់ម៉ោង១១ជាងក៏មានបញ្ហា។ ខ្ញុំសន្លប់ក្រោយពីខាងជនជាប់ចោទកាប់ខ្ញុំ។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ[redacted]នៅចៅក្រមស៊ើបសួរចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១០និង៥០នាទី ពេលខ្លួនកំពុងនៅរៀនក្នុងសាលាបាក់ទូក ស្រាប់តែឈ្មោះ[redacted]ជាអ្នកស្គាល់បានទូរស័ព្ទហៅខ្លួនឲ្យចេញពីថ្នាក់ទៅជួបគេនៅមុខសាលា។ ពេលនោះខ្លួនដើរចេញទៅឃើញឈ្មោះ [redacted] ចាន់សំណាង កំពុងតែរង់ចាំយលើម៉ូតូម៉ាកនិចពណ៌ស ម្នាក់ឯង រួចឈ្មោ[redacted]ក៏ប្រើឲ្យខ្លួនបើកម៉ូតូឌុបវាទៅកន្លែងលេងស្នូកយ័រជ័យថាវី។ ពេលនោះខ្លួនក៏បើកម៉ូតូទៅដល់សាលាជ័យថាវី ក៏ជួបឈ្មោះ[redacted]ជាអ្នករៀននៅសាលាបាក់ទូកជាមួយខ្លួន, ឈ្មោះ[redacted] ភេទប្រុស រៀនសាលាបាក់ទូកជាមួយខ្លួនដែរ, ឈ្មោះ[redacted]ភេទប្រុស ជាអ្នកស្គាល់, ឈ្មោះ [redacted] ភេទប្រុស រៀនសាលាបាក់ទូកជាមួយខ្លួន, ឈ្មោ[redacted] ឈ្មោះ [redacted]ភេទប្រុស ជាអ្នកស្គាល់ និងពីរនាក់ទៀតមិនស្គាល់ឈ្មោះកំពុងតែលេងស្នូកយ័រ។ បន្ទាប់មកក៏នាំគ្នាទៅកន្លែងលេងអ៊ីនធើណេតអាវីណាហ្សុនទាំងអស់គ្នាទៀត នៅផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញដោយជិះម៉ូតូបួនគ្រឿងមានគ្នា០៨នាក់ដូចខាងលើ។ ឈ្មោ[redacted]ក៏ឲ្យខ្លួនបើកម៉ូតូម៉ាកនិចឌុបឈ្មោះ[redacted] ចំណែកឈ្មោ[redacted]ះម៉ូតូម៉ាកលែត អ្នកឌុបម្នាក់គេមិនស្គាល់ឈ្មោះ, ចំណែកម៉ូតូពីរគ្រឿងទៀតម៉ាកស្កុបពី ពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកស៊ុមម័រទីក

ប្រាក់ ដោយខ្លួនមិនដឹងថាអ្នកណាជាអ្នកឧបអ្នកណាទេ។ ពេលខ្លួនបើកម៉ូតូទៅមុខកន្លែងអ៊ីនធើណែត ស្រាប់តែឃើញឈ្មោះ[redacted]លោតចុះពីលើម៉ូតូខ្លួន ដោយខ្លួនមិនដឹងខ្លួន ហើយក៏ដកកាំបិតលាក់ទុកចេញពីខ្លួន រត់ទៅប្រតាយប្រតប់គ្នាជាមួយភាគីម្ខាងទៀត ដែលមានគ្នាប្រហែល០៨នាក់ កំពុងតែដើរចុះពីកន្លែងលេងអ៊ីនធើណែតនោះ ចំណែកខ្លួនភ័យពេកមិនបានឈប់ម៉ូតូទេ ហើយក៏បើកម៉ូតូគេចខ្លួន ចំណែកឈ្មោះ[redacted]ឃើញ ក៏លោតឡើងជិះម៉ូតូជាមួយដែរ ខ្លួនក៏បើកម៉ូតូមកសាលាបាក់ទុកវិញ ហើយឈ្មោះ[redacted]ក៏បើកម៉ូតូម៉ាកនិច នោះចេញទៅបាត់ទៅ ហើយខ្លួនក៏យកម៉ូតូរបស់ខ្លួននៅក្នុងសាលាបើកមកផ្ទះខ្លួនវិញទៅ។ ក្នុងរឿងនេះខ្លួនពុំបានដឹង និងសមគំនិតក្នុងអំពើហិង្សានេះទេ។ ម្យ៉ាងទៀតខ្លួនក៏ពុំបានដឹងថាឈ្មោ[redacted]មានលាក់កាំបិត និងមានបំណងទៅកាប់គេដែរ។ ចំពោះរឿងហេតុហិង្សានៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ថិតនៅត្រើមលែនមុខណាហ្គា ខ្លួនពុំបានដឹងរឿងហេតុទេ។ លុះមកដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៨និង៣០នាទី សមត្ថកិច្ចបានមកឃាត់ខ្លួននៅក្នុងសាលាបាក់ទុក ពេលខ្លួនកំពុងចេញពីរៀនគួរ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted]នៅចៅក្រមស៊ើបសួរចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ ខ្លួនសុំដកពាក្យបណ្តឹង និងកំណត់ហេតុបណ្តឹងចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឈប់ប្តឹងតទៅទៀតហើយ ពីព្រោះរបួសខាងស្តាំទងត្រចៀកស្តាំ និងចង្កាស្តាំតិចតួចប៉ុណ្ណោះ ដែលជនបង្កបានវាយមកលើខ្លួនកាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោងប្រហែល១១ នៅកន្លែងលេងហ្គេមហាត់ប្រាណ ផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ចំពោះជនជាប់ចោទជិះម៉ូតូ០៤គ្រឿងមានគ្នា០៨ទៅ០៩នាក់ ខ្លួនពុំដែលស្គាល់ទេ ហើយក៏ពុំធ្លាប់មានទំនាស់ជាមួយពួកគេដែរ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោ[redacted]នៅសមត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង៩ ខ្លួនបានចូលលេងហ្គេមនៅក្នុងកន្លែងហាត់ប្រាណមានគ្នា០៥នាក់ គឺមានឈ្មោះ[redacted]ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោ[redacted]ភេទប្រុស អាយុ១៤ឆ្នា, ឈ្មោះ[redacted]ភេទប្រុស អាយុ២២ឆ្នាំ និងរូបខ្លួន។ ក្រោយមកខ្លួនបាននាំគ្នាឈប់លេងនៅវេលាម៉ោងប្រហែល១១និង១៥នាទី ចេញមកក្រៅស្រាប់តែបានឃើញម៉ូតូ០៤គ្រឿងនៅជ្រុងខាងលិច, មានម៉ូតូ០២គ្រឿងនៅខាងកើតមុខសាលាបឋម ម៉ាកស្កុបពីពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកស៊ិមម័រ ពណ៌ខ្មៅ គ្មានស្លាកលេខ មួយសន្ទុះស្រាប់តែអ្នកជិះម៉ូតូម៉ាកឡែតនៅខាងលិច បានជិះម៉ូតូសំដៅមករកខ្លួន ពេលនោះខ្លួនកំពុងឈរ ក្រោយមកអ្នកជិះខាងក្រោយបានស្ទុះមកវាយខ្លួន បណ្តាលឲ្យរបួសកែងដៃខាងស្តាំ ស្មាខាងឆ្វេង និងក្បាលត្រូវដោយសារខ្សែក្រវ៉ាត់។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ[redacted]នៅសមត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១១ ពេលនោះខ្លួនបានចុះពីផ្ទះ ហើយដើរទៅទិញទឹកអំពៅនៅជិតក្លឹបហាត់ប្រាណខ្លាឃ្មុំ ពេលខ្លួនដើរកាត់ទីនោះពុំទាន់មានទំនាស់អ្វីនៅទីនោះទេ ពេលដែលខ្លួនទិញទឹកអំពៅ ហើយដើរត្រឡប់មកវិញ មកដល់កន្លែងហាត់ប្រាណខ្លាឃ្មុំ ខ្លួនក៏បានឃើញមនុស្សផ្អើល ដោយសារក្រុមក្មេងស្ទាវកាប់គ្នា ហើយខ្លួនបានដើរចូលទៅមើល ឃើញក្មេងស្ទាវម្នាក់រងរបួសមានឈាម តែខ្លួនមិនដឹងថាត្រូវចំត្រង់ណាទេ ពេលដែលខ្លួន

កំពុងឈរមើលនោះ ស្រាប់តែមានក្មេងដែលជាពួកម៉ាករបស់ជនរងគ្រោះបានចោទប្រកាន់មកលើរូបខ្លួនថា រូបខ្លួនជាបក្ខពួករបស់ជនបង្ក ហើយបាននាំខ្លួនមកស្នាក់ការនគរបាលប៉ុស្តិ៍បឹងព្រលឹត ដើម្បីធ្វើការសាកសួរតែម្តង។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ [redacted] នៅសមត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅមុនពេលកើតហេតុ ខ្លួននៅរៀនក្នុងវិទ្យាល័យយុគន្ធរ រហូតដល់វេលាម៉ោង៩ ខ្លួនមានម៉ោងលីប០២ម៉ោង ក្រោយចេញពីរៀនខ្លួននិងមិត្តភក្តិ០២នាក់ទៀត មានឈ្មោះ [redacted] និងឈ្មោ [redacted] បានបបួលគ្នាមកលេងអ៊ីនធើណែតនៅផ្ទះលេខ៣៦៧ ផ្លូវលេខ២៣៨ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ រហូតដល់វេលាម៉ោង១១និង១៥នាទី ស្រាប់តែខ្លួនឃើញជនល្មើសមកធ្វើសកម្មភាពកាប់មកលើឈ្មោះ [redacted] បណ្តាលឲ្យរយៈក្បាលចេញឈាម។ បក្ខពួកជនជាប់ចោទមានគ្នា១១នាក់ជិះម៉ូតូ០៤គ្រឿង មានម៉ូតូម៉ាកឡែត ពណ៌សខ្មៅ មួយគ្រឿង, ម៉ូតូម៉ាកស្កុបពីពណ៌ក្រហម មួយគ្រឿង, ម៉ាកស៊ូមម៉ែរពណ៌ខ្មៅមួយគ្រឿង និងម៉ាកនិចពណ៌សមួយគ្រឿង។ ក្រោយពីធ្វើសកម្មភាពកាប់ជនរងគ្រោះនៅចំណុចមុខផ្ទះលេខ៣៦៧ ផ្លូវលេខ១៣៨ រួចជនជាប់ចោទជិះម៉ូតូចេញទៅទិសខាងកើតបាត់អស់ទៅ។ ក្រោយមកទើបឃើញប៉ូលីសទៅដល់ ហើយបញ្ជូនជនរងគ្រោះទៅពេទ្យ ហើយខ្លួនមកប៉ុស្តិ៍ប៉ូលីសដើម្បីបំភ្លឺ។

<u>លោក [redacted] មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា</u>

ក្រោយពីស្តាប់ការដេញដោល និងពិនិត្យឯកសារដែលខ្ញុំមាន ឃើញថា កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ពិតជាមានអង្គហេតុហិង្សាកើតឡើងពិតប្រាកដមែន ដោយមានជនល្មើសជាច្រើននាក់ ដែលកាប់មកលើជនរងគ្រោះបណ្តាលឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរបណ្តាលឱ្យកូនក្តីខ្ញុំខូចដៃ និងមានស្ថានភាពមិនប្រក្រតីដូចដើម ហើយជនជាប់ចោទដែលជាដៃដល់ឈ្មោ [redacted] ក៏បានសារភាពថា បានកាប់កូនក្តីខ្ញុំដែរ ហេតុនេះខ្ញុំស្នើសុំចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងឱ្យជនជាប់ចោទសងសំណងមកកូនក្តីខ្ញុំតាមការទាមទារ។

<u>តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា</u>

ក្រោយពីស្តាប់ចម្លើយជនជាប់ចោទ ក្រោយពីពិនិត្យភស្តុតាង និងក្រោយពីស្តាប់ចម្លើយជនរងគ្រោះឃើញថា ជនជាប់ចោទឈ្មោះ [redacted] ទប្រុស , ឈ្មោ [redacted] ទប្រុស និងឈ្មោ [redacted] ទប្រុស ពិតជាបានប្រើអំពើហិង្សាលើជនរងគ្រោះដោយប្រើអាវុធពិតប្រាកដមែន ហេតុនេះខ្ញុំសុំតម្កល់ការចោទប្រកាន់ដដែល និងស្នើសុំលោកស្រីចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

<u>មេធាវីការពារសិទ្ធិជនជាប់ចោទលោកស្រី [redacted] នធ្វើសេចក្តីសន្និដ្ឋានការពារថា</u>

ក្រោយពីស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] និងអំណានចម្លើយសាក្សី ក៏ដូចជាចម្លើយរបស់ជនជាប់ចោទឈ្មោ [redacted] ឃើញថា ពុំបានចង្អុលបង្ហាញថាកូនក្តីខ្ញុំឈ្មោ [redacted] នចូលរួមប្រព្រឹត្តឡើយ ហេតុនេះនាងខ្ញុំជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ស្នើសុំលោកស្រីចៅក្រមមេត្តាឱ្យកូនក្តីខ្ញុំរួចផុតពីការចោទប្រកាន់។

មេធាវីការពារសិទ្ធិជនជាប់ចោទលោក[redacted]បានធ្វើសេចក្ដីសន្និដ្ឋានការពារថា

ក្រោយពីស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted]និងចម្លើយរបស់កូនក្ដីខ្ញុំគ្រប់នីតិវិធី ឃើញថា កូនក្ដីខ្ញុំឈ្មោះ[redacted]ពុំបានប្រព្រឹត្តឡើយ គឺគាត់ជិះម៉ូតូជាមួយឈ្មោះ[redacted]ហើយពេលដល់កន្លែងកើតហេតុឈ្មោះ[redacted]លោតចុះពីលើម៉ូតូដោយខ្លួនឯង ហើយកូនក្ដីខ្ញុំពុំបានដឹងរឿងឡើយ គាត់ទៅជាមួយឈ្មោះ[redacted]ដើម្បីលេងហ្គេមប៉ុណ្ណោះ ពុំមានចេតនាទៅបង្កហិង្សា ឬសមគំនិតជាមួយឈ្មោះ[redacted]ទេ ហើយបើតាមចម្លើយកូនក្ដីខ្ញុំ គឺគាត់បានប្រាប់ហើយថា គាត់ពុំបានដឹងអ្វីឡើយ។ បើពិនិត្យមើលការចោទប្រកាន់លើកូនក្ដីខ្ញុំតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌនោះ គឺពុំចូលឡើយមើលធាតុផ្សំនៃបទល្មើស គឺសួរថាកូនក្ដីខ្ញុំមានការគិតទុកជាមុនអត់ គឺអត់ទេ កូនក្ដីខ្ញុំបាទពុំបានដឹងទេ គឺឈ្មោះ[redacted]លោតចុះពីលើម៉ូតូខ្លួនឯង កូនក្ដីខ្ញុំពុំដឹងទេ ហើយសួរថាតើកូនក្ដីខ្ញុំមានប្រើអាវុធទេ គឺអត់ទេ អាវុធជារបស់ឈ្មោះ[redacted]មិនមែនជារបស់កូនក្ដីខ្ញុំទេ បើពិនិត្យមើលធាតុសត្យានុម័ត គឺកូនក្ដីខ្ញុំពុំបានបញ្ចេញសកម្មភាពអ្វីទេ ហេតុនេះស្នើសុំចៅក្រមជំនុំជម្រះឱ្យកូនក្ដីខ្ញុំរួចផុតពីការចោទប្រកាន់។

ជនជាប់ចោទឈ្មោះ[redacted]បាននិយាយសម្ដីចុងក្រោយថា

សំណូមពរសុំតុលាការបន្ធូរបន្ថយទោសឱ្យខ្ញុំបាទផង។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងរាជធានីភ្នំពេញ

## យល់ឃើញថា

-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៥៣២-ឈ-ដ.ជ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted]ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ[redacted]ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ ទៅជំនុំជម្រះពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-តាមចម្លើយជនជាប់ចោទឈ្មោះ[redacted]ថា ខ្លួនដឹងពីការចោទប្រកាន់របស់ព្រះរាជអាជ្ញាពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស។ ខ្លួនឆ្លើយបញ្ជាក់នាពេលសវនាការជូនលោកស្រីចៅក្រមជំនុំជម្រះថា កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១៦និង១៥នាទី ខ្លួន និងមិត្តភក្តិចំនួន០៩នាក់ទៀតមានឈ្មោ[redacted] ឈ្មោះ: [redacted] ឈ្មោះ:[redacted]ឈ្មោះ: [redacted] ឈ្មោ[redacted] ឈ្មោ[redacted] និងឈ្មោះ[redacted]បានជិះម៉ូតូ០៤គ្រឿងចេញពីកន្លែងលេង Snooker នៅជិតសាលាជ័យថាវីបំណងទៅលេងអ៊ិនធើណិតនៅអារីហ្សូននៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា ពេលនាំគ្នាជិះទៅដល់មុខកន្លែងលេងអ៊ិនធើណិតនោះ ក៏ជួបជាមួយបក្ខពួកដែលជិះម៉ូតូពីរគ្រឿងជា(បក្ខប្រឆាំងឈ្លោះគ្នា) នៅអារីណាហ្សូន។ ពេលនោះខ្លួននៅមុខអារីណាហ្សូន ពួកគេវាយគ្នានៅក្រោយ ហើយស្រាប់តែឈ្មោះ[redacted]ស្រែកថា ជួយផងៗ ខ្លួនក៏ចុះពីលើម៉ូតូកាប់លើបក្ខខាងនោះខ្លួនមានសាំម៉ូរ៉ៃមួយ ចំណែកបក្ខពួកគេមានសាំម៉ូរ៉ៃពីរ។ ខ្លួនកាប់ត្រូវគេម្នាក់ត្រង់ក្បាល និងដៃ ហើយក៏ឡើងម៉ូតូជិះជាមួយឈ្មោះ[redacted]រត់តែម្តង។ ខ្លួនសុំរក្សាចម្លើយកន្លងមកគ្រប់ដំណាក់កាល។ ខ្លួនធ្លាប់មានជម្លោះជាមួយបក្ខខាងជនរងគ្រោះម្តងនៅកោះពេជ្រម្តងហើយ ដោយពួកគេដេញកាប់ខ្លួនតែខ្លួនជិះម៉ូតូគេចខ្លួនផុត លុះនៅថ្ងៃកើតហេតុក៏ជួបពួកជនរងគ្រោះដោយចៃដន្យ ក៏ពួកគ្នាខ្លួនវ៉ៃគ្នាស្រែកឱ្យខ្លួនជួយ ខ្លួនក៏កាប់ទៅលើជនរងគ្រោះប៉ុណ្ណោះ ខ្លួនកាប់លើជនរងគ្រោះ តែពុំដឹងថាត្រូវប៉ុន្មានកាំបិតទេ។ ពេលជិះម៉ូតូឈ្មោះ[redacted]ជាអ្នកឧប វាពុំបានដឹងថាខ្លួនមានលាក់កាំបិតទេ ហើយខ្លួនបបួលឈ្មោ[redacted]ទៅលេងហ្គេមនៅអារីណាហ្សូន ពុំបានបបួលថាទៅកាប់គ្នានោះទេ។

-តាមចម្លើយជនរងគ្រោះឈ្មោ[redacted] នៅថ្ងៃកើតហេតុខ្លួនកំពុងតែជិះម៉ូតូពីរគ្រឿងមានគ្នា០៥នាក់ទៅលេងហ្គេមនៅអារីណាហ្សូន ក្រោយពីលេងហើយខ្លួនចេញមកវិញ ក៏ឃើញពួកខាងជនល្មើសវាយខ្លួនដោយដៃសិន ពួកវាមានគ្នាច្រើនណាស់ដោយជិះម៉ូតូ០៥គ្រឿងដោយមួយម៉ូតូជិះពីរនាក់ទៅបីនាក់ ពេលដែលវ៉ៃខ្លួននោះខ្លួនរត់ចូលក្នុង តែប្អូនខ្លួនឈ្មោ[redacted]ត្រូវគេវ៉ៃនៅក្រៅ ខ្លួនក៏ចេញទៅជួយ ស្រាប់តែជនល្មើសដែលនៅចំពោះមុខខ្លួននេះកាប់ខ្លួនមួយកាំបិតត្រូវដៃ ហើយគាត់ថែមមួយកាំបិតទៀតពីក្រោយចំក្បាលខ្លួនទៀត បណ្តាលឱ្យខ្លួនសន្លប់តែម្តង។ បក្ខពួកគាត់មានគ្នាច្រើន និងមានកាំបិតគ្រប់ដៃ ព្រោះថាបើគាត់មានកាំបិតតែមួយដើមមិនអាចកាប់ខ្លួនដល់ទៅ៥កាំបិតឡើយ។ ខ្លួនពុំដែលមានទំនាស់ជាមួយខាងជនជាប់ចោទ គឺគេមកវ៉ៃខ្លួនតែម្តង ខ្លួនពុំបានតដៃទេ។ ខ្លួនទាមទារ ៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក។ បក្ខពួកខ្លួនពុំមានកាំបិតទេ ពេលគេកាប់ខ្លួនត្រូវមួយកាំបិត ខ្លួនចង់សន្លប់ហើយ ថែមខ្លួនមួយកាំបិតទៀត។ ខ្លួនពុំដែលមានទំនាស់ជាមួយគេឡើយ។ សព្វថ្ងៃដៃខ្លួនមិនដូចដើមឡើយ ធ្វើការមិនកើត។ ខ្លួនចាំមុខបក្ខពួកគាត់កាប់ខ្លួនបាន ដែលជនជាប់ចោទនោះចំពោះមុខខ្លួននេះ។ ខ្លួនទៅលេងហ្គេមពីម៉ោង៩ព្រឹកដល់ម៉ោង១១ជាងក៏មានបញ្ហា។ ខ្លួនសន្លប់ក្រោយពីខាងជនជាប់ចោទកាប់ខ្លួន។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]នៅចៅក្រមស៊ើបសួរចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១០និង៥០នាទី ពេលខ្លួនកំពុងនៅរៀនក្នុងសាលាបាក់ទូក ស្រាប់តែឈ្មោះ[redacted]អ្នកស្គាល់បានទូរស័ព្ទហៅខ្លួនឲ្យចេញពីថ្នាក់ទៅជួបគេនៅមុខសាលា។ ពេលនោះខ្លួនដើរចេញទៅឃើញឈ្មោះ[redacted]កំពុងតែអង្គុយលើម៉ូតូម៉ាកនិចពណ៌ស ម្នាក់ឯង រួចឈ្មោះ[redacted]ក៏ប្រើឲ្យខ្លួន

បើកម៉ូតូឌុបវាទៅកន្លែងលេងស្នូកឃ័រជ័យថាវី។ ពេលនោះខ្លួនក៏បើកម៉ូតូទៅដល់សាលាជ័យថាវី ក៏ជួប ឈ្មោះ [redacted] ជាអ្នករៀននៅសាលាបាក់ទូកជាមួយខ្លួន, ឈ្មោះ [redacted] ភេទប្រុស រៀនសាលាបាក់ទូកជាមួយខ្លួនដែរ, ឈ្មោះ [redacted] ភេទប្រុស ជាអ្នកស្គាល់, ឈ្មោះ [redacted] ភេទប្រុស រៀនសាលាបាក់ទូកជាមួយខ្លួន, ឈ្មោះ [redacted] ឈ្មោះ [redacted] ភេទប្រុស ជាអ្នកស្គាល់ និងពីរនាក់ទៀតមិនស្គាល់ឈ្មោះកំពុងតែលេងស្នូកឃ័រ។ បន្ទាប់មកក៏នាំគ្នាទៅកន្លែងលេងអ៊ីនធើណេតអារីណាហ្សូនទាំងអស់គ្នាទៀត នៅផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយជិះម៉ូតូបួនគ្រឿងមានគ្នា០៨នាក់ដូចខាងលើ។ ឈ្មោះ [redacted] ក៏ឲ្យខ្លួនបើកម៉ូតូម៉ាកនិចឌុប ឈ្មោះ [redacted] ចំណែកឈ្មោះ [redacted] ជិះម៉ូតូម៉ាកវ៉េវ អ្នកឌុបម្នាក់គេមិនស្គាល់ឈ្មោះ, ចំណែកម៉ូតូពីរគ្រឿងទៀតម៉ាកស្កុបពី ពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកស៊ីមម័រទឹកប្រាក់ ដោយខ្លួនមិនដឹងថាអ្នកណាជាអ្នកឌុបអ្នកណាទេ។ ពេលខ្លួនបើកម៉ូតូទៅមុខកន្លែងអ៊ីនធើណែតស្រាប់តែឃើញឈ្មោះ [redacted] លោតចុះពីលើម៉ូតូខ្លួន ដោយខ្លួនមិនដឹងខ្លួន ហើយក៏ដកកាំបិតលាក់ទុកចេញពីខ្លួន រត់ទៅប្រតាយប្រតប់គ្នាជាមួយភាគីម្ខាងទៀត ដែលមានគ្នាប្រហែល០៨នាក់ កំពុងតែដើរចុះពីកន្លែងលេងអ៊ីនធើណែតនោះ ចំណែកខ្លួនភ័យពេកមិនបានឈប់ម៉ូតូទេ ហើយក៏បើកម៉ូតូគេចខ្លួន ចំណែកឈ្មោះ [redacted] ឃើញ ក៏លោតឡើងជិះម៉ូតូជាមួយដែរ ខ្លួនក៏បើកម៉ូតូមកសាលាបាក់ទូកវិញ ហើយឈ្មោះ [redacted] បើកម៉ូតូម៉ាកនិច នោះចេញទៅបាត់ទៅ ហើយខ្លួនក៏យកម៉ូតូរបស់ខ្លួននៅក្នុងសាលាបើកមកផ្ទះខ្លួនវិញទៅ។ ក្នុងរឿងនេះខ្លួនពុំបានដឹង និងសមគំនិតក្នុងអំពើហិង្សានេះទេ។ ម្យ៉ាងទៀតខ្លួនក៏ពុំបានដឹងថាឈ្មោះ [redacted] មានលាក់កាំបិត និងមានបំណងទៅកាប់គេដែរ។ ចំពោះរឿងហេតុហិង្សានៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៦ ស្ថិតនៅត្រើមលែនមុខណាហ្គា ខ្លួនពុំបានដឹងរឿងហេតុទេ។ លុះមកដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង១៨និង៣០នាទី សមត្ថកិច្ចបានមកឃាត់ខ្លួននៅក្នុងសាលាបាក់ទូក ពេលខ្លួនកំពុងចេញពីរៀនគួរ។

-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នៅចៅក្រមស៊ើបសួរចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ ខ្លួនសុំដកពាក្យបណ្តឹង និងកំណត់ហេតុបណ្តឹងចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ឈប់ប្តឹងតទៅទៀតហើយ ពីព្រោះរបួសខាងស្តាំទងត្រចៀកស្តាំ និងចង្កាស្តាំតិចតួចប៉ុណ្ណោះ ដែលជនបង្កបានវាយមកលើខ្លួនកាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោងប្រហែល១១ នៅកន្លែងលេងហ្គេមហាត់ប្រាណ ផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។ ចំពោះជនជាប់ចោទជិះម៉ូតូ០៤គ្រឿងមានគ្នា០៨ទៅ០៩នាក់ ខ្លួនពុំដែលស្គាល់ទេ ហើយក៏ពុំធ្លាប់មានទំនាស់ជាមួយពួកគេដែរ។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]នៅសមត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង៩ ខ្លួនបានចូលលេងហ្គេមនៅក្នុងកន្លែងហាត់ប្រាណមានគ្នា០៥នាក់ គឺមានឈ្មោះ[redacted] ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ, ឈ្មោះ ហ[redacted]ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោ[redacted]ភេទប្រុស អាយុ២២ឆ្នាំ និងរូបខ្លួន។ ក្រោយមកខ្លួនបាននាំគ្នាឈប់លេងនៅវេលាម៉ោងប្រហែល១១និង១៥នាទី ចេញមកក្រៅ ស្រាប់តែបានឃើញម៉ូតូ០៤គ្រឿងនៅជ្រុងខាងលិច, មានម៉ូតូ០២គ្រឿងនៅខាងកើតមុខសាលាបឋម ម៉ាកស្កុបពីពណ៌ក្រហម និងមួយគ្រឿងទៀតម៉ាកស៊ីមម័រ ពណ៌ខ្មៅ គ្មានស្លាកលេខ មួយសន្ទុះ

ស្រាប់តែអ្នកជិះម៉ូតូម៉ាកឡែតនៅខាងលិច បានជិះម៉ូតូសំដៅមករកខ្លួន ពេលនោះខ្លួនកំពុងឈរ ក្រោយមកអ្នកជិះខាងក្រោយបានស្ទុះមកវាយខ្លួន បណ្តាលឲ្យរបួសកែងដៃខាងស្តាំ ស្មាខាងឆ្វេង និងក្បាល ត្រូវដោយសារខ្សែក្រវ៉ាត់។

-តាមអំណានចម្លើយសាក្សីឈ្មោ[redacted]នៅសបត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោងប្រហែល១១ ពេលនោះខ្លួនបានចុះពីផ្ទះ ហើយដើរទៅទិញទឹកអំពៅនៅជិតភ្លើបហាត់ប្រាណខ្លាឃ្មុំ ពេលខ្លួនដើរកាត់ទីនោះពុំទាន់មានទំនាស់អ្វីនៅទីនោះទេ ពេលដែលខ្លួនទិញទឹកអំពៅ ហើយដើរត្រឡប់មកវិញ មកដល់កន្លែងហាត់ប្រាណខ្លាឃ្មុំ ខ្លួនក៏បានឃើញមនុស្សផ្អើល ដោយសារក្រុមក្មេងស្ទាវកាប់គ្នា ហើយខ្លួនបានដើរចូលទៅមើល ឃើញក្មេងស្ទាវម្នាក់រងរបួសមានឈាម តែខ្លួនមិនដឹងថាត្រូវចំត្រង់ណាទេ ពេលដែលខ្លួនកំពុងឈរមើលនោះ ស្រាប់តែមានក្មេងដែលជាពួកម៉ាករបស់ជនរងគ្រោះបានចោទប្រកាន់មកលើរូបខ្លួនថា រូបខ្លួនជាបក្ខពួករបស់ជនបង្ក ហើយបាននាំខ្លួនមកស្នាក់ការនគរបាលប៉ុស្តិ៍បឹងព្រលិត ដើម្បីធ្វើការសាកសួរតែម្តង។

-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted]នៅសបត្ថកិច្ចចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានខ្លឹមសារថា៖ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅមុនពេលកើតហេតុ ខ្លួននៅរៀនក្នុងវិទ្យាល័យយុគន្ធរ រហូតដល់វេលាម៉ោង៩ ខ្លួនមានម៉ោងលីប០២ម៉ោង ក្រោយចេញពីរៀនខ្លួននិងមិត្តភក្តិ០២នាក់ទៀត មានឈ្មោះ[redacted]ងឈ្មោ[redacted]បានបបួលគ្នាមកលេងអ៊ីនធើណែតនៅផ្ទះលេខ៣៦៧ ផ្លូវលេខ២៣៨ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ រហូតដល់វេលាម៉ោង១១និង១៥នាទី ស្រាប់តែខ្លួនឃើញជនល្មើសមកធ្វើសកម្មភាពកាប់មកលើឈ្មោះ [redacted]បណ្តាលឲ្យរយៈក្បាលចេញឈាម។ បក្ខពួកជនជាប់ចោទមានគ្នា១១នាក់ជិះម៉ូតូ០៤គ្រឿង មានម៉ូតូម៉ាកឡែត ពណ៌សខ្មៅ មួយគ្រឿង, ម៉ូតូម៉ាកស្កុបពីពណ៌ក្រហម មួយគ្រឿង, ម៉ាកស៊ីមម័រពណ៌ខ្មៅមួយគ្រឿង និងម៉ាកនិចពណ៌សមួយគ្រឿង។ ក្រោយពីធ្វើសកម្មភាពកាប់ជនរងគ្រោះនៅចំណុចមុខផ្ទះលេខ៣៦៧ ផ្លូវលេខ១៣៨ រួចជនជាប់ចោទជិះម៉ូតូចេញទៅទិសខាងកើតបាត់រស់ទៅ។ ក្រោយមកទើបឃើញប៉ូលីសទៅដល់ ហើយបញ្ជូនជនរងគ្រោះទៅពេទ្យ ហើយខ្លួនមកប៉ុស្តិ៍ប៉ូលីសដើម្បីបំភ្លឺ។

-តាមរបាយការណ៍សំយោគលេខ ៥២របក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល បានសន្និដ្ឋានថា ឈ្មោះ ព្រាក់ ចាន់សំណាង ឈ្មោះ[redacted]ហៅ[redacted]ឈ្មោះ [redacted]ហៅ[redacted], ឈ្មោះ [redacted], ឈ្មោះ[redacted], ឈ្មោះ[redacted] និងគូកន០២នាក់ទៀតមិនស្គាល់ឈ្មោះ ពិតជាបានប្រព្រឹត្តអំពើ សមគំនិតក្នុងអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើអាវុធ(កាំបិតកែច្នៃ) និងដោយសារមានមនុស្សច្រើននាក់កាប់ទៅលើជនរងគ្រោះបណ្តាលឲ្យរបួសធ្ងន់ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ វេលាម៉ោង១១និង១៥នាទី នៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ពិតប្រាកដមែន។

-មានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងរវាងចម្លើយជនជាប់ចោទ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី របាយការណ៍សំយោគលេខ ៥២របក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ របស់

ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាល និងតាមការពិនិត្យឯកសារជាភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿង បញ្ជាក់បានថា កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ នៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ[redacted]ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ[redacted] ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ ពិតជាបានប្រព្រឹត្តនូវអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រាកដមែន ។

-ជនជាប់ចោទឈ្មោះ[redacted] ឈ្មោះ[redacted]និងឈ្មោះ[redacted] ជាជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណាមួយដែលនាំឲ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងការប្រព្រឹត្តបទល្មើសនោះទេ និងជាសមត្ថជនដែលមានការពិចារណាយល់ដឹងអំពីផលវិបាក ដែលកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុនេះត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដែលបញ្ជាក់ថា ពិតជាមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted]ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted]ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានប្តឹងទាមទារការខូចខាតសំណងជម្ងឺចិត្ត ចំនួន៥០,០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ហេតុនេះតុលាការនឹងធ្វើការពិចារណាទៅតាមព្យសនកម្មជាក់ស្តែង។

-នៅក្នុងសំណុំរឿងនេះ ពុំមានវត្ថុចាប់យកបញ្ជូនមកតុលាការទេ ហេតុនេះតុលាការពុំធ្វើការពិចារណាពីបញ្ហានេះឡើយ។

-តាមសេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ហេតុនេះតុលាការនឹងធ្វើការពិចារណាពីបញ្ហានេះ ។

## ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ

## វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសជនជាប់ចោទ៖

ក.ឈ្មោះ[redacted]ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤(បួន)ឆ្នាំ។

ខ.ឈ្មោះ[redacted]ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ

គ.ឈ្មោះ[redacted]ភេទប្រុស អាយុ១៤ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០២(ពីរ)ឆ្នាំ តែទោសនេះត្រូវព្យួរជាធម្មតា។

ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ១១B ផ្លូវលេខ ២៣៨ ភូមិ១ សង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សងសំណងការខូចខាតចំនួន ៤០,០០០,០០០ (សែសិបលាន)រៀល, ឈ្មោះ [redacted] សងសំណងការខូចខាតចំនួន ២០,០០០,០០០(ម្ភៃលាន) រៀល និងឈ្មោះ [redacted] សងសំណងការខូចខាតចំនួន ២០,០០០,០០០(ម្ភៃលាន)រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការទាមទារលើសពីនេះបដិសេធចោល។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted]

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

*-បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម ។-*

ភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកោះកុង

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ១៧៧ បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ ដោយ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ មានសមាសភាពដូចតទៅ

សាលក្រម
លេខ ៥២ "យ"
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខៈ១៧៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ដែលរួមមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] ភេទប្រុស អាយុ៤៨ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិទន្លេបាទី ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ (ទោសពីមុនគ្មាន) ជានិតិជន។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ និងកាលបីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ២៧៣១ ត.ព/១៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកោះកុង។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ២០៦ អ.យ/១៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

- បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ២០២ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តកោះកុង ។

**អង្គហេតុមានដូចតទៅ**

កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ មានក្រុមហ៊ុនចំនួនបី ក្នុងនោះមានក្រុមហ៊ុនអិល អាយ ភី (LIP), ក្រុមហ៊ុនយ៉ាសាគិ(YASAKI) និងក្រុមហ៊ុន ខេខេអិន (KKN) បាន[illegible]

សុំធ្វើសៀវ ភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តាមរយៈលោក [redacted] ដែលជាប្រធានការិយាល័យការងារនិងទទួលបន្ទុកប្រមូលចំណូលផ្នែកសេវាទូទៅរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកោះកុង ។ ដោយក្រុមហ៊ុនបានប្រគល់ប្រាក់ឲ្យឈ្មោះ [redacted] ចំនួន២៧,៩៣៥ ដុល្លារអាមេរិក សម្រាប់ធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តែមកដល់ពេលនេះឈ្មោះ [redacted] មិនបានប្រគល់ប្រាក់ថ្លៃធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ មកឲ្យមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ខេត្តកោះកុងទេ ហើយក្រុមហ៊ុនដែលបានស្នើសុំធ្វើសៀវភៅការងារនោះក៏មិនទាន់បានទទួលសៀវភៅការងារនេះពីឈ្មោះ [redacted] នេះដែរ ។

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ឈ្មោះ [redacted] បានទទួលប្រាក់ពីក្រុមហ៊ុនចំនួនបួនទៀត ដែលមានក្រុមហ៊ុនខេខេអិន (KKN), ក្រុមហ៊ុនមីកាសា, ក្រុមហ៊ុនហាណា និងក្រុមហ៊ុន៩៩ ដែលមានទឹកប្រាក់ចំនួន ២៩,៧៣០,០០០ រៀល សម្រាប់ថ្លៃសេវាពិនិត្យកាយសម្បទារបស់នាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ តែឈ្មោះ [redacted] មិនបានយកប្រាក់មកបង់ជូននាយកដ្ឋានពេទ្យការងារទេ ហើយក្រុមហ៊ុនក៏មិនទាន់បានទទួលវិញ្ញាបនបត្រពិនិត្យកាយសម្បទាពីនាយកដ្ឋានពេទ្យការងារដែរ។

-តុលាការប្រកាសបើកសវនាការ

-តុលាការប្រកាសអំពីសមាសភាពជំនុំជម្រះ

-តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់សាក្សី

-ជនជាប់ចោទមិនជំទាស់ និងសមាសភាពជំនុំជម្រះទេ

**នាពេលសវនាការ**

-តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយបំភ្លឺថា៖ កាលពីឆ្នាំ២០១៥ ឈ្មោះ [redacted] ដែលជាប្រធានការិយាល័យការងារនិងទទួលបន្ទុកប្រមូលចំណូលផ្នែកសេវាទូទៅរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សៀវភៅការងារខ្មែរ និងបរទេស) ។ ក្រុមហ៊ុនអិលភីយ ភី (I.Y.P) ក្រុមហ៊ុនយ៉ាសាគិ(YASAKI) និងក្រុមហ៊ុន(KKN) បានដាក់ពាក្យស្នើសុំធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តាមរយៈលោក [redacted] ។ ដោយក្រុមហ៊ុនបានប្រគល់ប្រាក់ឲ្យឈ្មោះ [redacted] ចំនួន២៧,៩៣៥ ដុល្លារអាមេរិក សម្រាប់ធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តែមកដល់ពេលនេះឈ្មោះ [redacted] មិនបានប្រគល់ប្រាក់ថ្លៃធ្វើ សៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ មកឲ្យមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ខេត្តកោះកុងទេ ហើយក្រុមហ៊ុនដែលបានស្នើសុំធ្វើសៀវភៅការងារនោះក៏មិនទាន់បានទទួលសៀវភៅការងារនេះពីឈ្មោះ [redacted] នេះដែរ ។

-ជនជាប់ចោទឈ្មោះ [redacted] បានអវត្តមានក្នុងពេលសនាការ ចៅក្រមជំនុំជម្រះបានឲ្យក្រឡាបញ្ជីអានអំណានចម្លើយរបស់ជនជាប់ចោទនៅក្នុងដំណាក់កាលចៅក្រមស៊ើប[illegible]

ស្វរជនត្រូវចោទឈ្មោ [redacted]បានឆ្លើយសារភាពថា៖ កាលពី រវាងខែឧសភា និងខែមិថុនា ឆ្នាំ២០១៦ ខ្លួនពិតជាបានយកប្រាក់ពីក្រុមហ៊ុនអិលវ៉ាយភី ក្រុមហ៊ុនយ៉ាសាគិ និងក្រុមហ៊ុនខេខេអិន ចំនួន២៧,៩៣៥ ដុល្លារអាមេរិក សម្រាប់ធ្វើសៀវភៅការងារសម្រាប់ប្រជាពលរដ្ឋខ្មែរ និងបរទេស និងបានយកប្រាក់ពីក្រុមហ៊ុនមីកាសា ,ក្រុមហ៊ុនហាណា និងក្រុមហ៊ុន៩៩ ដែលមានទឹកប្រាក់ចំនួន ២៩,៧៣០,០០០ រៀល សម្រាប់ថ្លៃសេវាពិនិត្យកាយសម្បទារបស់នាយកដ្ឋានពេទ្យការងារ ពិតប្រាកដមែន ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ :

+ ដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រប់គ្រាន់ ហើយការឆ្លើយដោះសាររបស់ជនជាប់ចោទគ្មានមូលដ្ឋានអាចយកមកពិចារណាបាន។ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ និងសំណូមពរដល់ចៅក្រមជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសកម្មភាពដែលបានប្រព្រឹត្ត។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [redacted]ភេទប្រុស អាយុ៤៤ ឆ្នាំ ជនជាតិ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ និងកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

+សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ២០៦ អ.យ/១៧ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង និងសូមឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់។

1) ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
2) ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
3) ក្រោយពីបានពិនិត្យភស្តុតាង
4) ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកោះកុង

## យល់ឃើញថា

១. តាមចម្លើយដើមបណ្តឹងឈ្មោ [redacted]បានឆ្លើយបំភ្លឺថា៖ កាលពីឆ្នាំ២០១៥ ឈ្មោះ [redacted]ដែលជាប្រធានការិយាល័យការងារនិងទទួលបន្ទុកប្រមូលចំណូលផ្នែកសេវាទូទៅរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សៀវភៅការងារខ្មែរ និងបរទេស) ។ ក្រុមហ៊ុនអិលវ៉ាយ ភី (I.Y.P) ក្រុមហ៊ុនយ៉ាសាគិ(YASAKI) និងក្រុមហ៊ុន(KKN) បានដាក់ពាក្យស្នើសុំធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តាមរយៈលោក [redacted]។ ដោយក្រុមហ៊ុនបានប្រគល់ប្រាក់ឲ្យឈ្មោ [redacted]ចំនួន២៧,៩៣៥ ដុល្លារអាមេរិក សម្រាប់ធ្វើសៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ តែមកដល់ពេលនេះឈ្មោះ [redacted]មិនបានប្រគើប្រាក់ថ្លៃធ្វើ សៀវភៅការងារសម្រាប់ជនបរទេស និងសម្រាប់ប្រជាពលរដ្ឋខ្មែរ មកឲ្យមន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ខេត្តកោះកុងទេ ហើយក្រុមហ៊ុនដែលបានស្នើសុំធ្វើសៀវភៅការងារនោះក៏មិនទាន់បានទទួលសៀវភៅការងារនេះពីឈ្មោ [redacted]

[redacted]នះដែរ ។ តុលាការយល់ឃើញពិតជាមានហេតុនេះកើតឡើងពិតប្រាកដមែន ។

២-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយសារភាពថា៖ កាលពី អំឡុងខែឧសភា និងខែមិថុនា ឆ្នាំ២០១៦ ខ្លួនពិតជាបានយកប្រាក់ពីក្រុមហ៊ុនអិលវ៉ាបរភី ក្រុមហ៊ុនហ៊េសាគិ និង ក្រុមហ៊ុនខេខេអ៊ិន ចំនួន២៧,៩៣៥ ដុល្លារអាមេរិក សម្រាប់ធ្វើសៀវភៅការងារសម្រាប់ប្រជាពលរដ្ឋខ្មែរ និងបរទេស និងបានយកប្រាក់ពីក្រុមហ៊ុនប៊ីកាសា ,ក្រុមហ៊ុនហាណា និង ក្រុមហ៊ុន៩៩ ដែលមានទឹកប្រាក់ចំនួន ២៩,៧៣០,០០០ រៀល សម្រាប់ថ្លៃសេវាពិនិត្យកាយសម្បទារបស់នាយកដ្ឋានពេទ្យការងារ ពិតប្រាកដមែន ។ យោងតាមចម្លើយសារភាពនេះបានបញ្ជាក់ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចបទចោទប្រកាន់មែន គប្បីតុលាការពិចារណាសម្រេចតាមច្បាប់ ។

៣. ជនត្រូវចោទឈ្មោះ[redacted]ត្រូវបានចៅក្រមស៊ើបសួរសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ដែលការសម្រេចមិនបានប៉ះពាល់ដល់នីតិវិធីស៊ើបសួរឡើយ ។

៤. ផ្អែកតាមកិច្ចសន្យាសងប្រាក់ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទបានបង្ហាញថា ជនជាប់ចោទបានទទួលស្គាល់អំពើប្រព្រឹត្តរបស់ខ្លួន ហើយបានព្រមព្រៀងសងប្រាក់ដែលបាត់បង់ទៅដើមបណ្តឹងរដ្ឋប្បវេណីវិញ ។

៥. យោងតាមវិញ្ញាបនប័ត្រពេទ្យ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានមន្ទីរពេទ្យបង្អែកខេត្តកណ្តាល បានបង្ហាញថាជនជាប់មានជំងឺ ដែលត្រូវសម្រាកព្យាបាលទៀតទាត់ជាមួយគ្រូពេទ្យជំនាញ ។

៦. ផ្អែកតាមមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិចារណាសម្រេចលើការព្យួរទោស ដោយពិនិត្យលើស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ អង្គហេតុ និង អង្គច្បាប់ ដែលកើតមានឡើង ។

៧. ផ្អែកតាមមាត្រា៣៩១ និង មាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណា ។

៨. តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានតម្កល់ការចោទប្រកាន់ ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរ ។

៩. ដើមបណ្តឹងរដ្ឋប្បវេណីបានសំណូមពរដល់តុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្ត ៥០.០០០.០០០ (ហាសិបលាន)រៀល ។ តុលាការយល់ឃើញថានៅក្នុងសំណុំរឿងនេះតាមរយៈសកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណី មានការប៉ះពាល់ និងការខាតបង់ពេលវេលា អាស្រ័យហេតុនេះគប្បីតុលាការពិចារណាដោយផ្អែកលើភាពសមហេតុសមផល និងព្យសនកម្មដែលកើតមានជាក់ស្តែង ។

១០. យោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១/-ផ្តន្ទាទោស ឈ្មោះ [redacted] ភេទប្រុស អាយុ៤៥ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ចំនួន០១(មួយ)ឆ្នាំ តែទោសនេះត្រូវព្យួរ ។

ជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦ និងកាលបីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២/- បង្គាប់ឲ្យឈ្មោះ [redacted] ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ

ក/. សងប្រាក់ដែលបានបាត់បង់ ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ។

ខ/. សងសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល ។

៣/-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted]

បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី** [redacted]

**ចៅក្រមជំនុំជម្រះ** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

កោះកុង ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

កោះកុង ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨

**ចៅក្រមជំនុំជម្រះ**

[redacted]

07.05.2018.

[redacted]

11.05.2018

[redacted]

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកោះកុង**
សំណុំរឿងព្រហ្មទណ្ឌលេខ : ១៨៨
ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦
សាលក្រមលេខ : ៦៣ "ខ"
ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**
**សាលាដំបូងខេត្តកោះកុង**

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១៧ វេលាម៉ោង ២:៣០ នាទីរសៀល ដោយមានសមាសភាពដូចតទៅ៖

<u>ចៅក្រមជំនុំជម្រះ</u>
-លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកោះកុង
<u>តំណាងអយ្យការ</u>
-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង
<u>ក្រឡាបញ្ជីសវនាការ</u>
-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

-<u>ដើម្បីជំនុំជម្រះលើ</u> សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៨ ចុះថ្ងៃទី ០៩-០៩-២០១៦ ដែលមានជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅសង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្តីឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុន គ្មាន ។

ត្រូវចោទពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលពិន័យឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-<u>ដើមបណ្តឹងរដ្ឋប្បវេណី</u> ឈ្មោះ [redacted] ភេទ ប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិ ០៣ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

-<u>បានឃើញ:</u> ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ០៣ ម.យ/១៧ ចុះថ្ងៃទី ១៦-១០-២០១៦ របស់ ចៅក្រមសាលាដំបូងខេត្តកោះកុង ។

-<u>បានឃើញ:</u> ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៥៩ ចុះថ្ងៃទី ១៧-១០-២០១៦ របស់លោកប្រធានសាលាដំបូងខេត្តកោះកុង ។

<u>ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:</u>

កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង១០ និង០៥នាទីព្រឹក ឈ្មោះ [redacted] បានទូរស័ព្ទមកប្រាប់ឈ្មោះ [redacted] ថា ប្រពន្ធឈ្មោះ [redacted] បានដេកជាមួយប្តីរបស់ខ្លួន ដោយប្រពន្ធឈ្មោះ [redacted] បានទៅដេកជាមួយប្តីរបស់ខ្លួនឈ្មោះ [redacted] ជាច្រើនដងមកហើយ និងសុំឲ្យប្រពន្ធឈ្មោះ [redacted] កុំមកទាក់ទងប្តីរបស់ខ្លួនទៀត ។

ហើយឈ្មោះ [redacted] នៅតែបន្តទូរស័ព្ទមកឈ្មោះ [redacted] និយាយបរិហារកេរ្តិ៍ប្រពន្ធរបស់ឈ្មោះ [redacted] ជាបន្តបន្ទាប់ ព្រមទាំងបានសរសេរតាមរយៈពត៌មានសង្គមហ្វេសប៊ុកទៀត និងធ្វើការសួរនាំឈ្មោះ [redacted] នៅក្នុងផ្សារថ្មីចាំយាម ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយសម្លេងខ្លាំងៗ ធ្វើឲ្យមានការភ្ញាក់ផ្អើលដល់សាធារណៈជន នៅក្នុងផ្សារមើលមកឈ្មោះ [redacted] ។ ក្រោយពីបានលឺ និងឃើញឈ្មោះ [redacted] ធ្វើសកម្មភាពបែបនេះ ឈ្មោះ [redacted] ក៏បានសួរនាំប្រពន្ធឈ្មោះ [redacted] ហើយឈ្មោះ [redacted] បានឆ្លើយថា ពុំប្រព្រឹត្តដូចដែរឈ្មោះ [redacted] បាននិយាយប្រាប់នោះទេ ។

<u>នាពេលសវនាការ</u>

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨ ម៉ោង១០,៤៥នាទីព្រឹក ឈ្មោះ [redacted] បានទូរស័ព្ទមកខ្លួន ដោយប្រាប់ថា ប្រយ័ត្នប្រពន្ធឯង កុំឲ្យទាក់ទងប្តីគាត់ទៀត ហើយឈ្មោះ [redacted] នេះតែងតែទូរស័ព្ទមកខ្លួនជាច្រើនដងដោយនិយាយដដែលៗ ថាប្រពន្ធខ្លួនទាក់ទងជាមួយប្តីគាត់ តែខ្លួនបានសួរប្រពន្ធខ្លួនរួចហើយ ដោយប្រពន្ធរបស់ខ្លួនបដិសេធថា មិនបានធ្វើអ្វីក្បត់ខ្លួននោះទេ គ្រាន់តែស្គាល់គ្នាធម្មតាប៉ុណ្ណោះ ព្រោះឈ្មោះ [redacted] ដែលជាប្តីរបស់ឈ្មោះ [redacted] នេះជាអ្នករត់ម៉ូតូឌុប ។ ហើយឈ្មោះ [redacted] បាននិយាយ ប្រាប់ខ្លួនទៀតថា ពួកគេចង់ចេញទៅជួលផ្ទះដើម្បីនៅជាមួយគ្នា ។ ក្នុងរឿងនេះ ខ្លួនសំណូមពរសុំ តុលាការជួយរកយុត្តិធម៌ ប្រសិនបើប្រពន្ធរបស់ខ្លួនបានប្រព្រឹត្តអំពើផិតក្បត់បែបនេះមែន សូមតុលាការសម្រេចតាមច្បាប់ ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: ឈ្មោះ [redacted] ជាអ្នករត់ ម៉ូតូឌុប នៅមុខកាស៊ីណូ ហើយខ្លួនធ្លាប់ជិះម៉ូតូគាត់ ចឹងហើយក៏ស្គាល់គ្នា ។ លុះដល់អំឡុងខែសីហា ឆ្នាំ២០១៨ ប្រពន្ធរបស់ [redacted] ឈ្មោះ [redacted] បានខមមិនជេរខ្លួន តាមហ្វេសបុក ដោយសរសេរថា "ឈ្មោះ [redacted] ធ្វើការនៅកាស៊ីណូទាក់ទងប្តីគេ ! ប្តីគេប្រាប់គេអស់ហើយ ថាប្តីគេឈប់ទាក់ទង លេងហ្វេសបុក ជាមួយខ្លួនហើយ !តែថាខ្លួននៅតែលេងជាមួយប្តីគេទៀត" ។ ក្រោយមកខ្លួនមិនដឹងថាឈ្មោះ [redacted] បានលេខប្តីរបស់ខ្លួនពីណាមកទេ ក៏ទូរស័ព្ទទៅប្រាប់ប្តីខ្លួន ដោយនិយាយពាក្យមិនល្អពីខ្លួនជាច្រើនប្រាប់ប្តីខ្លួន ។ ហើយក្រោយមកខ្លួនបានជួបឈ្មោះ [redacted] នៅក្នុងផ្សារថ្មី នៅភូមិចាំយាម ដោយឈ្មោះ [redacted] ហៅខ្លួនដោយសួរខ្លួនថា ឈ្មោះ [redacted] មែន? ខ្លួនឆ្លើយថា ចាំ ពេលនោះឈ្មោះ [redacted] បានចង្អុលមុខខ្លួន ដោយនិយាយលឺៗ ថា នាងនុំទាក់ទងប្តីគេ ខ្លួនតបវិញ ថា "កុំចោទនុំដល់ថ្នាក់នឹង នុំគ្រាន់តែស្គាល់គ្នាតាមរយៈជិះម៉ូតូឌុប ទៅធ្វើការនៅកាស៊ីណូជាមួយគ្នា កុំនិយាយជ្រុសជ្រាស់" និងបាននិយាយទៀតថា "នុំរវល់" រួចក៏បែកគ្នាទៅ ។ ក្រោយមកទៀត ឈ្មោះ [redacted] នៅតែបន្តនិយាយថាខ្លួនទាក់ទងប្តីគេរហូត ។ ខ្លួនសំណូមពរសុំតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: ខ្លួននិងឈ្មោះ [redacted] ពិតជាធ្លាប់មានទំនាក់ទំនងផ្លូវភេទជាមួយគ្នាមែន ។ កាលពីអំឡុងខែ០៣ រឺខែ០៤ ឆ្នាំ២០១៨ ខ្លួនបានស្គាល់ឈ្មោះ [redacted] ដោយនុំជាអ្នករត់ម៉ូតូឌុប រីឯឈ្មោះ [redacted] ជាម៉ូយម៉ូតូរបស់ខ្លួន ។ លុះស្គាល់គ្នាយូរទៅ ខ្លួននិងឈ្មោះ [redacted] ក៏មានទំនាក់ទំនងស្និតស្រៀវជាមួយគ្នា ដោយខ្លួន និងឈ្មោះ [redacted] ធ្លាប់ទៅដេកជាមួយគ្នានៅផ្ទះសំណាក់ ។ លុះដល់អំឡុងខែ០៦ ឆ្នាំ២០១៨ ឈ្មោះ [redacted] បានជួលផ្ទះមួយនៅភូមិថ្មី ក្នុងតម្លៃ ១៨ ម៉ឺនរៀល ដើម្បីទុកជួបជាមួយខ្លួនពិតមែន ។ ហើយខ្លួនក៏ធ្លាប់ដឹងថាប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] បានទូរស័ព្ទទៅឈ្មោះ [redacted] អំពីទំនាក់ទំនងរវាងខ្លួននិងប្រពន្ធគាត់ដែរ ។ ហើយប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] មិនដែលរករឿងឡូឡា ដាក់ខ្លួន និងឈ្មោះ [redacted] នៅកន្លែងធ្វើការ រឺស្ថានការណ៍ណាឡើយ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: កាលពីអំឡុងឆ្នាំ២០១៥ ខ្លួនពិតជាបានទូរស័ព្ទទៅឈ្មោះ [redacted] ដោយបានប្រាប់ថាឈ្មោះ [redacted] ជា ប្រពន្ធរបស់គាត់ មានទំនាក់ទំនងជាមួយប្ដីរបស់ខ្លួន និងឲ្យគាត់ប្រាប់ប្រពន្ធគាត់ កុំឲ្យទាក់ទងជាមួយនិងប្ដីរបស់ខ្លួនទៀតប្រាកដមែន ។ ក្រោយមកកាលពីអំឡុងឆ្នាំ ២០១៥ នោះដែរ ខ្លួនបានជួបឈ្មោះ [redacted] ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] នៅផ្សារភូមិថ្មី ស្ថិតនៅក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ពេលនោះ ខ្លួនបានសួរគាត់ថា "ហេតុអ្វីក៏នៅតែទាក់ទងជាមួយគ្រួសារខ្ញុំអីចឹង?" ពេលនោះដែរឈ្មោះ [redacted] តបវិញថា "គាត់មិនបានទាក់ទងអ្វីទៀតទេ" ។ នៅពេលដែលខ្លួនសួរគាត់នោះ គឺមានតែខ្លួន និងឈ្មោះ [redacted] តែប៉ុណ្ណោះ ពួកខ្លួននិយាយគ្នាមិនដល់ប្រាំនាទីផងក៏បែកគ្នា ។ ខ្លួននិង ឈ្មោះ [redacted] និយាយគ្នាដោយធម្មតាទេ មិនមានការស្រែកឡូឡាផ្អើលដល់អ្នកណាទេ ។

-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃកើតហេតុនោះខ្ញុំបានទៅផ្សារភូមិថ្មីជាមួយកូនប្រុសឈ្មោះ [redacted] ដោយពេលនោះកូនស្រីរបស់ខ្លួនកំពុងឈរទិញឆាហ៊ាន់ស្រាប់តែមានមនុស្សស្រីម្នាក់ បានហៅកូនស្រីខ្ញុំទៅនិយាយគ្នា ដោយខ្លួននៅចម្ងាយប្រហែលជា ២ ទៅ៣ម៉ែត្រ ពីពួកគេ ។ ខ្លួនបានលឺគេសួរកូនស្រីខ្លួនថាឈ្មោះ [redacted] រឺមិនមែន? កូនខ្លួនឆ្លើយថា "ចាស" ដោយឆ្លើយហើយ មនុស្សស្រីម្នាក់នោះបាននិយាយថា កុំឲ្យកូនខ្លួនទាក់ទងប្ដីគេទៀត ដោយប្រើសម្លេងៗ ធ្វើឲ្យអ្នកនៅផ្សារងើលមើលមកគ្រប់គ្នា ។ ខ្លួននឹក ឃើញថា ពីមុនធ្លាប់មានមនុស្សស្រីម្នាក់បានតេមកខ្លួន ដោយនិយាយប្រាប់ខ្លួនថា កូនស្រីរបស់ខ្លួនបានទាក់ទងប្ដីរបស់គេ ដោយបញ្ជាក់ថា មនុស្សនៅកន្លែងធ្វើការ អ្នកណាក៏គេនិយាយប្រាប់ចឹងដែរ តែខ្លួនប្រកែកដោយចាំខ្ញុំ សួរកូនរបស់ខ្លួនសិន ហើយពេលនោះខ្លួនបាននិយាយរឿងនេះជាមួយកូនប្រសារខ្លួន ទើបកូនប្រសារខ្ញុំមកដាក់ពាក្យបណ្ដឹងព្រោះខ្លាចមានរឿងមិនល្អណាមួយកើតឡើងលើកូនស្រីរបស់ខ្លួន ព្រោះមនុស្សស្រីម្នាក់នោះកំពុងតែឹងប្រចណ្ឌ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានទោសថា: មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទ: បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។ តាងនាមតំណាងអយ្យការ សូមរក្សាបទចោទប្រកាន់ទុកជាបានការពេញទាំងមូលដដែល និងស្នើសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សីឈ្មោះ [redacted]
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សម្ដី និងសំណូមពរចុងក្រោយបង្អស់របស់ជនជាប់ចោទ

<u>ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>

<u>សាលាដំបូងខេត្តកោះកុង</u>

<u>យល់ឃើញថា:</u>

-កាលពីថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៥ វេលាម៉ោង ១០,៤៥នាទី នៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ពិតជាមានអំពើ បរិហារកេរ្តិ៍ជាសាធារណៈ ប្រាកដមែន ហើយអំពើនេះត្រូវបានច្បាប់ចែងជាបទល្មើសព្រហ្មទណ្ឌ តាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះបានឆ្លើយគ្រប់ពេលវេលាមានភាពស៊ីសង្វាក់គ្នា ដែលអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ពិតជាបានទូរស័ព្ទជាមួយឈ្មោះ [redacted] និយាយក្នុងផ្សារកីឡូថាជានិយាយក្នុងហ្វេសប៊ុកថា ប្រពន្ធរបស់ឈ្មោះ [redacted] មានទំនាក់ទំនងស្នេហាជាមួយប្តីរបស់ខ្លួន។

-តាមការអះអាងរបស់ឈ្មោះ [redacted] ខ្លួននិងប្រពន្ធទោះបីរស់នៅជាប់គ្នាក៏ដោយ តែពុំធ្លាប់មានទំនាក់ទំនងគ្នារហូតតាមរយៈទូរស័ព្ទ និងជួបផ្តាំថ្ងៃសម្រាប់ពីការងារ ។

-ចម្លើយនេះស៊ីចង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ [redacted] ដែលថាខ្លួនមិនដែលមានទំនាក់ទំនងស្នេហាជាមួយឈ្មោះ [redacted] ទេ ។

-អំពើរបស់ឈ្មោះ [redacted] មានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើស បរិហារកេរ្តិ៍ជាសាធារណៈ ដែលមានចែងក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

-សេចក្តីសន្និដ្ឋានចោទប្រកាន់របស់តំណាងអយ្យការ សុំរក្សាការចោទប្រកាន់ និងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ សុំឲ្យតុលាការវិនិច្ឆ័យតាមច្បាប់។

-សេចក្តីសន្និដ្ឋានចោទប្រកាន់របស់អយ្យការ និងសម្តីចុងក្រោយរបស់ជនជាប់ចោទ គប្បីតុលាការពិចារណា។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ពីបទ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

<u>ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង</u>

<u>វិនិច្ឆ័យសេចក្តី</u>

១/- <u>ផ្តន្ទាទោសជនជាប់ចោទ</u> ឈ្មោះ [redacted] ភេទស្រី អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១.០០០.០០០ "មួយលាន"រៀល ពីបទៈ បរិហារកេរ្តិ៍ជាសាធារណៈ ប្រព្រឹត្តនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១៥ បទល្មើសដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ ។

២/-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ១០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ហត្ថលេខានិងត្រា [redacted]

ហត្ថលេខានិងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កោះកុង ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៧
ក្រឡាបញ្ជីសវនាការ

[redacted]

[redacted]